សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អភិបាលកិច្ចល្អខណ្ឌចំការមន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១   ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហួរ ណារ៉ុង**

**ស្រ៊ី ពេញចិត្ត**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សភក្កដា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# អភិបាលកិច្ចល្អខណ្ឌចំការមន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១   ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហួរ ណារ៉ុង**

**ស្រី ពេញចិត្ត**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហូរ ណារ៉ុង** និងខ្ញុំបាទឈ្មោះ **ស្រ៊ី ពេញចិត្ត** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាល-សាធារណៈ ជំនាន់ទី ១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧ - ២០២១៖

ជាបឋមយើងខ្ញុំទាំងពីររូបសូមគោរព និងសម្តែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះលោកអ្នកមានគុណទាំងពីរគឺ **លោកឪពុក និងអ្នកម្តាយ** ដែលមានឧបការគុណយ៉ាងខ្ពង់ខ្ពស់បំផុតដែលលោកទាំងពីរបានផ្តល់នូវកំណើត ព្រមទាំងទទួលខុសត្រូវប្រកបដោយ ព្រហ្មវិហាធម៌ក្នុង ការចិញ្ចឹមបីបាច់ថែរក្សារូបកូនតាំងពីតូច រហូតដល់ធំដឹងក្តីដោយមិនគិតពី ការនឿយហត់ និងបានអប់រំ ទូន្មានប្រៀនប្រដៅយ៉ាងយកចិត្តទុកដាក់ទំនុកបំរុង និងផ្តល់ភាពកក់ក្តៅសព្វបែបយ៉ាងដល់រូបកូន ផ្តល់កម្លាំងចិត្ត និងបានជម្រុញឱ្យកូនបានសិក្សាខ្ពង់ខ្ពស់ ដើម្បីឱ្យកូនក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម។

ជាបន្ទាប់យើងខ្ញុំសូមសម្តែងនូវក្តីអំណរអរគុណ យ៉ាងក្រៃលែងបំផុតចំពោះ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក/លោកស្រី សាស្ត្រាចារ្យ** ទាំងអស់ដែលខិតខំប្រឹងប្រែងដឹកនាំ និងគ្រប់គ្រងឱ្យដំណើរការប្រព័ន្ធអប់រំនៅទីនេះមានភាពប្រសើរដោយក្នុងគោលបំណង បណ្តុះបណ្តាលមូលធនផ្នែកបញ្ញាស្មារតី និងធនធានមនុស្សរបស់ប្រទេសកម្ពុជាឱ្យមានចំណេះដឹង បទពិសោធន៍ ប្រកបដោយ សីលធម៌ និងព្រហ្មវិហាធម៌ ដើម្បីក្លាយជាសរសរទ្រូងស្របតាមកាលានុវត្តភាព នៃការអភិវឌ្ឍន៍របស់ប្រទេសជាតិ។

ជាពិសេសយើងខ្ញុំទាំងពីររូបសូមអរគុណ **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃ និងមមាញឹកពីការបង្រៀន ដើម្បីធ្វើការដឹកនាំកែលម្អ ចង្អុលបង្ហាញតម្រង់ទិសបង្ហាញគន្លឹះ និងផ្តល់យោបល់ល្អៗ ទាក់ទងនឹងប្រធានបទសារណារបស់ខ្ញុំបាទ ដោយមិនខ្លាចនឿយហត់តាំងពីចាប់ផ្តើម រហូតដល់សារណាមួយនេះបានបញ្ចប់ដោយជោគជ័យ។

ជាចុងក្រោយ ខ្ញុំបាទទាំងពីររូបមានកិត្តិយស សូមសេចក្តីអនុញ្ញាត គោរពជូនពរដល់ អ្នកមានគុណទាំងអស់ សូមមេត្តាទទួលយកដោយក្តីអនុគ្រោះបំផុត នូវភក្តីភាព សេចក្តីគោរពស្រឡាញ់ ក្នុងភាពសុចរិតដែលប្រកបដោយគុណតម្លៃដ៏ឧត្តុងឧត្តម នៃសេចក្តីថ្លៃថ្នូរ ភាពចុំច្រើន កិត្តិគុណដ៏ខ្ពង់ខ្ពស់ ព្រមទាំងកត្តញ្ញូតាធម៌។

ជាចុងបញ្ចប់ខ្ញុំទាំងពីររូប សូមគោរពប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គល កើតមានដល់ លោកអ្នកមានគុណទាំងអស់ សូមឱ្យលោកជួបប្រទះនូវពុទ្ធពរទាំងឡាយ បួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្រោយពីយើងខ្ញុំទាំងពីររូបបានបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ៣ឆ្នាំកន្លងមកនេះ ខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើនទាំងផ្នែកទ្រឹស្តី និងការអនុវត្តនៅក្នុងផ្នែកនេះ។ ស្ថិតនៅក្នុងដំណាក់កាលឆ្នាំទី៤ របស់យើងខ្ញុំទាំងពីររូប ដោយផ្អែកតាមលទ្ធភាព ចំណេះដឹង នៃការសិក្សាទាំងអស់នេះហើយជាកត្តាយ៉ាងសំខាន់ដែលជម្រុញឱ្យខ្ញុំទាំងពីររូបមានឱកាសក៏ដូចជា លទ្ធភាពដែលអាចសរសេរសារណាបញ្ចប់ការសិក្សាមួយទុកសម្រាប់ ជាឯកសារជំនួយស្មារតីដល់និស្សិត សិស្សប្អូនជំនាន់ក្រោយ។ ហើយការចងក្រងសារណាបញ្ចប់ការសិក្សាមួយនេះជាឱកាសដ៏ល្អមួយដែលអាច ស្វាបស្ទង់បន្ថែមនូវ ចំណេះដឹងរបស់ខ្ញុំបាទទាំងពីររូបដែលមានពីមុនមក និងការធ្វើការសិក្សាស្រាវជ្រាវបន្ថែម។ បរិបទបែបនេះហើយដែលជាហេតុបណ្តាលខ្ញុំបាទទាំងពីរនាក់បានជ្រើសរើសយកប្រធានបទមួយ ដែលស្តីពី **អភិបាលកិច្ចល្អខណ្ឌចំការមន** មកធ្វើជាប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។

កម្មវត្ថុសំខាន់មួយទៀតនោះ គឺចង់ឱ្យ សិស្សនិស្សិតជំនាន់ក្រោយ និងសាធារណៈជន បានសិក្សា និង ស្វែងយល់បន្ថែម អំពីដំណើរការ នៃអភិបាលកិច្ចល្អ នៃខណ្ឌចំការមន ព្រមទាំងបើកបង្ហាញនូវ ការគ្រប់គ្រងរដ្ឋបាល ដែលមានអភិបាលកិច្ចល្អជាស្នូលដែលនាំឱ្យមានការអភិវឌ្ឍ និងរីកចម្រើនយ៉ាងខ្លាំងក្លា នៃរដ្ឋបាលថ្នាក់ខណ្ឌ។ លើសពីនេះទៅទៀត យើងខ្ញុំទាំងពីររូបមានគោលបំណង បង្ហាញឱ្យឃើញពីកំណែទម្រង់រដ្ឋបាលស៊ីជម្រៅដោយ ប្តូរពីឥរិយាបទអ្នកគ្រប់គ្រងមកជាឥរិយាបទអ្នកផ្តល់សេវាវិញ។

មុននឹងបញ្ចប់ ខ្ញុំបាទទាំងពីរនាក់ សូមគោរពទទួលយកនូវរាល់កំហុសខុសឆ្គងណាមួយដោយចេតនាក្តី ដោយអចេតនាក្តី ឬនៅមានភាពខ្វះខាតចន្លោះត្រង់កន្លែងណាមួយ សូមមេត្តាខន្តី អភ័យទោសប្រកបដោយ សេចក្តីគោរពដល់ខ្ពង់ខ្ពស់បំផុតពីសំណាក់ខ្ញុំបាទទាំងពីររូប ហើយយើងខ្ញុំទាំងពីររូបនឹងទទួលរង់ចាំ នូវរាល់ មតិរិះគន់ កែលម្អ រាល់ចំណុះខ្វះខាតទាំងឡាយក្នុងន័យស្ថាបនាដើម្បីឱ្យការស្រាវជ្រាវមួយនេះមានន័យគ្រប់គ្រាន់ បន្ថែមទៀត។

ជាទីបញ្ចប់ខ្ញុំបាទទាំងពីរ សូមគោរពជូនពរដល់ មិត្តនិស្សិត មិត្តអ្នកអានទាំងអស់គ្នា ឱ្យទទួលបាននូវ ភាពជោគជ័យគ្រប់ភារកិច្ច និងមានកម្លាំងពលមាំមួន ខ្លាំងក្លា ប្រាជ្ញាវាងវៃ មានអាយុយឺនយូរ ជៀសផុតពីជំងឺ ទាំងឡាយទាំងពួង រកស៊ីមានបានគ្រប់គ្នា ព្រមទាំងជួបនូវពុទ្ធពរទាំង បួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម** ............ ១

## ជំពូកទី១
## ស្ថានភាពទូទៅនៅក្នុងខណ្ឌចំការមន

**១.១ ទិដ្ឋភាពទូទៅក្នុងខណ្ឌចំការមន** ............ ៤

**១.១.១. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ** ............ ៤

១.១.១.១. ប្រវត្តិរបស់សាលាខណ្ឌចំការមន ............ ៤

១.១.១.២. ស្ថានភាពភូមិសាស្ត្ររបស់ខណ្ឌ ............ ៥

១.១.១.៣. ស្ថានភាពប្រជាសាស្ត្រ ............ ៥

**១.១.២. សន្តិសុខ និងសណ្ដាប់ធ្នាប់ខណ្ឌ** ............ ៥

១.១.២.១. សុវត្ថិភាពបុគ្គល ............ ៦

១.២.២.២. សុវត្ថិភាពសម្ភារៈ ............ ៧

១.១.២.៣. សុវត្ថិភាពចំណីអាហារ ............ ៨

**១.២. រចនាសម្ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាលខណ្ឌ** ............ ៩

**១.២.១. រចនាសម្ព័ន្ធគ្រប់គ្រង** ............ ១០

១.២.១.១. ក្រុមប្រឹក្សាខណ្ឌ ............ ១០

១.២.១.២. គណៈអភិបាលខណ្ឌ និងនាយករដ្ឋបាល ............ ១៤

១.២.១.៣. គណៈកម្មាធិការ និងការិយាល័យប្រជាពលរដ្ឋ ............ ១៦

១.២.១.៤. ការិយាល័យ និងអង្គភាពចំណុះ ............ ១៨

**១.២.២. ការគ្រប់គ្រងរដ្ឋបាល** ............ ២៤

១.២.២.១. មុខងារ ............ ២៥

១.២.២.២. ការគ្រប់គ្រងបុគ្គលិក ............ ២៦

១.២.២.៣. ការងារហិរញ្ញវត្ថុ ............ ២៩

១.២.២.៤. ការគ្រប់គ្រងទ្រព្យសម្បត្តិ ............ ៣០

## ជំពូកទី២
## អភិបាលកិច្ចល្អក្នុងខណ្ឌចំការមន

**២.១. អភិបាលកិច្ចល្អ** ........ ៣៣
**២.១.១.និយមន័យ និងគោលបំណងអភិបាលកិច្ចល្អ** ........ ៣៣
**២.១.២. គោលការណ៍អភិបាលកិច្ចល្អ** ........ ៣៤
**២.១.៣. តួអង្គសំខាន់ៗ ក្នុងអភិបាលកិច្ចល្អ** ........ ៣៨
**២.១.៤. អភិបាលកិច្ចល្អ នៃរដ្ឋបាលខណ្ឌចំការមន** ........ ៣៨
**២.២. សមិទ្ធផលការងារដែលសម្រេចបានរបស់រដ្ឋបាលខណ្ឌ** ........ ៣៩
**២.២.១. សមិទ្ធផលនៃការគ្រប់គ្រងរដ្ឋបាល** ........ ៤០
២.២.១.១. ការងាររដ្ឋបាល ........ ៤០
២.២.១.២. ការងារផែនការ និងការគាំទ្រឃុំសង្កាត់ ........ ៤១
២.២.១.៣. ការគ្រប់គ្រង់បុគ្គលិកបច្ចុប្បន្ន ........ ៤២
២.២.១.៤. ការងារអន្តរវិស័យ ........ ៤៣
២.២.១.៥. ការងារហិរញ្ញវត្ថុ ........ ៤៤
២.២.១.៦. ការងារលទ្ធកម្ម ........ ៤៥
**២.២.២. សមិទ្ធផលរបស់ការិយាល័យ** ........ ៤៥
២.២.២.១. វិស័យសេដ្ឋកិច្ច ........ ៤៥
២.២.២.២. វិស័យសង្គមកិច្ច ........ ៤៨
២.២.២.៣.ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ ........ ៥១
២.២.២.៤. រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៥៤
**សេចក្តីសន្និដ្ឋាន** ........ ៥៦
**អនុសាសន៍** ........ ៥៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា បន្ទាប់ពីឆ្លងកាត់ស្បែអន្ធការយ៉ាងខ្មៅងងឹតអស់រយៈពេលជាច្រើនឆ្នាំកន្លងដែលធ្វើឱ្យមានការខូចខាតផ្នែក ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក៏បានប្រែមុខមាត់ថ្មី ដោយមានការរីកចម្រើន និងអភិវឌ្ឍន៍ជាលំដាប់គួរឱ្យកត់សម្គាល់នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ចាប់ផ្តើមពីចំនុចសូន្យរហូតដល់មានការអភិវឌ្ឍដូចសព្វថ្ងៃនេះ ដោយអនុវត្តនូវគោលនយោបាយ ឈ្នះ-ឈ្នះ របស់ប្រមុខរាជរដ្ឋាភិបាល និងមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋទូទាំងប្រទេស យើងសង្កេតឱ្យឃើញថាប្រទេសកម្ពុជា កំពុងតែមានការអភិវឌ្ឍរីកចម្រើនគ្រប់វិស័យមិនថាវិស័យរដ្ឋ ឬឯកជន។ ទន្ទឹមនឹងនេះផងដែររាជរដ្ឋាភិបាលកម្ពុជាតែងតែផ្តោតទៅលើការលើកទឹកចិត្តយ៉ាងខ្លាំង ដល់ប្រជាពលរដ្ឋឱ្យមានការអភិវឌ្ឍបែបប្រជាធិបតេយ្យស្របពេលដែលនយោបាយមានស្ថេរភាព និងរចនាសម្ព័ន្ធតាមបែបប្រជាធិបតេយ្យត្រូវបានពង្រឹងទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ក្នុងនោះផងដែររាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ក្នុងពេលដែលប្រទេសកម្ពុជា ស្ថិតនៅក្នុងប្រទេសអភិវឌ្ឍន៍ ដោយរាជរដ្ឋាភិបាលកំពុងធ្វើកំណែទម្រង់ទៅលើគ្រប់វិស័យ ជាពិសេសនៅក្នុងកំណែទម្រង់គ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដែលការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកូនសោរដ៏សំខាន់មួយក្នុងចំណោមកូនសោរដទៃទៀតនៅក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន។ ដោយសារឃើញពីសក្តានុពលនៃ ការគ្រប់គ្រងរដ្ឋបាលរបស់ខណ្ឌចំការមន ទើបក្រុមខ្ញុំបាទ បានលើកយកប្រធានបទដែលស្តីអំពី អភិបាលកិច្ចល្អខណ្ឌចំការមន ហើយខណ្ឌនេះផងដែលជាតំបន់ដែលមាន សក្តានុពល និងមានការរីកចម្រើនលើគ្រប់វិស័យ នៅក្នុងរាជធានីភ្នំពេញផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជាស្ពានឈានដល់ ការបកស្រាយលើប្រធានបទខាងលើឱ្យបានស៊ីជម្រៅ ក៏ដូចជាឱ្យមានភាពច្បាស់លាស់បន្ថែមទៀតនោះ យើងខ្ញុំទាំងពីររូបបានលើកយកចំណោទបញ្ហាមួយចំនួន មកធ្វើការបកស្រាយដែលបញ្ហាទាំងអស់នោះរួមមាន៖ តើសាលាខណ្ឌចំការមនមានរចនាសម្ព័ន្ធគ្រប់គ្រងដូចម្តេចខ្លះ? តើអ្វីទៅជាអភិបាលកិច្ចល្អរបស់ខណ្ឌចំការមន? តើសាលាខណ្ឌចំការមនសម្រេចបានលទ្ធផលអ្វីខ្លះនៅក្នុងឆ្នាំ ២០២០?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ក្នុងគោលបំណងកំណត់យក ប្រធានបទទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាលរបស់សាលាខណ្ឌស្តីអំពី **អភិបាលកិច្ចល្អ នៃខណ្ឌចំការមន** យកសរសេរជា ប្រធានបទសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែក **រដ្ឋបាលសាធារណៈ** នេះគឺមានគោលបំណងចង់បង្ហាញអំពីសក្តានុពល នៃការគ្រប់គ្រងរដ្ឋបាលរបស់

ខណ្ឌចំការមននាពេលបច្ចុប្បន្ននេះ ដែលធ្វើឱ្យមានការអភិវឌ្ឍជឿនលឿនពីព្រោះថានាពេលបច្ចុប្បន្នក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខណ្ឌចំការមន គឺមានការវិនិយោគជាច្រើនក្នុងនោះផងដែរ មិនថាហេដ្ឋារចនាសម្ព័ន្ធនានា សំណង់អគារទំនើបៗ លំនៅដ្ឋានប្រណិតៗ ផ្សាររដ្ឋ ផ្សារទំនើប សាលារៀន មន្ទីរពេទ្យ និងកន្លែងកំសាន្តនានា សុទ្ធតែទៅតាមស្តង់ដារជាតិ និងអន្តរជាតិដែលបានបម្រើដល់សេវាដល់ភ្ញៀវជាតិ និងអន្តរជាតិ ក៏ដូចជាប្រជាជននៅក្នុងតំបន់មួយនេះឱ្យមានការរស់នៅកាន់តែប្រសើរឡើង។

ជាងនេះទៅទៀត គោលបំណងនៃការបង្កើតនូវស្នាដៃនៃការសិក្សាស្រាវជ្រាវលើប្រធានសារណាមួយនេះឡើង គឺមាននូវគោលបំណងក្នុង ការបង្ហាញអំពីការគ្រប់គ្រងរដ្ឋបាល របស់រដ្ឋបាលខណ្ឌចំការមន ទៅតាមគោលនយោបាយ អភិបាលកិច្ចល្អ ដែលធ្វើឱ្យខណ្ឌចំការមន ប្រែក្លាយទៅជាទីក្រុងមួយ ដែលប្រកដដោយគុណភាពក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក៏ដូចជាភ្ញៀវអន្តរជាតិ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

រាល់ស្នាដៃនៃការស្រាវជ្រាវទាំងអស់ គឺសុទ្ធតែមានគោលបំណងសំខាន់ៗនៅក្នុងការស្រាវជ្រាវ។ ចំណែកការសិក្សាស្រាវជ្រាវប្រធានបទស្តី អភិបាលកិច្ចល្អ នៃរដ្ឋបាលខណ្ឌចំការមន គឺយើងខ្ញុំចង់បកស្រាយ និងបើកបង្ហាញឱ្យបានដឹងនៅ ការគ្រប់គ្រងការងាររដ្ឋបាលរបស់សាលាខណ្ឌដែលធ្វើឱ្យកើតមានឡើងនៅអភិបាលកិច្ចល្អនៅក្នុងខណ្ឌចំការមន តាមរយៈការប្រតិបត្តិទៅតាមតួនាទី និងភារកិច្ចនីមួយៗដែលស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាលក្នុងគោលបំណង និងទស្សនៈវិស័យរួមគ្នាតែមួយ គឺបម្រើផលប្រយោជន៍ជាសាធារណៈដោយមិនមានការបម្រើផលប្រយោជន៍ចំពោះបុគ្គលណាម្នាក់ឡើយ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើអត្ថបទសារណាមួយនេះ គឺមានគោលបំណងសំខាន់ដើម្បីផ្តល់សារៈប្រយោជន៍ដល់មិត្តនិស្សិត មិត្តអ្នកអាន មិត្តអ្នកស្រាវជ្រាវ និងសាធារណៈជនទាំងអស់ឱ្យបានយល់ដឹងឱ្យកាន់តែច្បាស់ និងស៊ីជម្រៅអំពីផែនការសកម្មភាពនៃ ការគ្រប់គ្រងរបស់រដ្ឋបាលខណ្ឌចំការមន ជាមួយនឹងការអភិវឌ្ឍលើវិស័យផ្សេងៗមិនថាហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគបច្ចេកទេស នៃការសាងសង់ និងការរៀបចំសំណង់ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធទាំងអស់ដែលអាចធ្វើឱ្យខណ្ឌចំការមនមានការរីកចម្រើនលើគ្រប់វិស័យ។ មិនត្រឹមតែប៉ុណ្ណោះ អត្ថបទសារណាមួយនេះក៏បានចូលរួមចំណែកក្នុងការបង្ហាញ នៃការជម្រុញឱ្យមាននូវការអភិវឌ្ឍថ្មីៗ បន្ថែមទៀតផងដែរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវ ចំពោះប្រធានបទសារណាមួយនេះ គឺខ្ញុំបាទទាំងពីរនាក់ បានស្វែងរកតាមរយៈបណ្តាឯកសារ ដែលពាក់ព័ន្ធទៅ នឹងប្រធានបទសារណា នៅសាលាខណ្ឌចំការមន ក្នុងបណ្ណាល័យ

អេឡិចត្រូនិក នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច តាមរយៈប្រព័ន្ធអ៊ីនធឺណិត និងគេហទំព័រផ្សេងៗ ដោយក្នុងនោះយើងខ្ញុំបានប្រមូល ឯកសារទាំងនោះយកមកវិភាគ និងសរសេរជាសារណាបញ្ចប់ការសិក្សារបស់ យើងខ្ញុំបាទទាំងពីរនាក់។

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖**

សារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទទាំងពីរ ត្រូវបានបែងចែកជា ២ជំពូកគឺ៖

- **ជំពូកទី១ "ស្ថានភាពទូទៅនៅក្នុងខណ្ឌចំការមន"** ៖ នៅក្នុងជំពូកនេះខ្ញុំបាទ នឹងបែងចែកជាពីរចំណុចបន្ថែមទៀត ដោយចំណុចទី១ និយាយអំពី ទិដ្ឋភាពទូទៅក្នុងខណ្ឌចំការមន និងចំណុចទី២ បង្ហាញអំពីរចនាសម្ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាលខណ្ឌ ។
- **ជំពូកទី២ "អភិបាលកិច្ចល្អក្នុងខណ្ឌចំការមន"** ៖ នៅក្នុងជំពូកនេះខ្ញុំបាទនឹងបែងចែកជាពីរចំណុចចបន្ថែមទៀត ដោយចំណុចទី១ និយាយអំពី អភិបាលកិច្ចល្អ និងចំណុចទី២ បង្ហាញអំពី សមិទ្ធផលការងារដែលសម្រេចបានរបស់រដ្ឋបាលខណ្ឌ ។

# ជំពូកទី១
# ស្ថានភាពទូទៅនៅក្នុងខណ្ឌចំការមន

# ជំពូកទី១

# ស្ថានភាពទូទៅនៅក្នុងខណ្ឌចំការមន

## ១.១. ទិដ្ឋភាពទូទៅក្នុងខណ្ឌចំការមន

ខណ្ឌចំការមន គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងកើតទល់នឹងខណ្ឌច្បារអំពៅ ដោយដងទន្លេបាសាក់ ខាងលិចទល់នឹងខណ្ឌបឹងកេងកង ខាងត្បូងទល់នឹងខណ្ឌមានជ័យ ខាងជើងទល់នឹងខណ្ឌដូនពេញ។ ក្នុងនោះផងដែរខណ្ឌចំការមន មាន៥សង្កាត់ដូចជា សង្កាត់ទន្លេបាសាក់ សង្កាត់ទួលទំពូងទី១ សង្កាត់ទួលទំពូងទី២ សង្កាត់បឹងត្របែក និងសង្កាត់ផ្សារដើមថ្កូវ។[1]

### ១.១.១. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ

ភូមិសាស្ត្រ និងប្រជាសាស្ត្រ គឺជាកត្តាដ៏សំខាន់ក្នុងការបង្កើតផែនការ ឬទិសដៅសកម្មភាព ផ្សេងៗរបស់រដ្ឋបាលខណ្ឌ ដែលមានសមត្ថកិច្ចពាក់ព័ន្ធ។ ព្រោះថាការស្វែងយល់ពីកត្តាទាំងនេះអាចឱ្យថ្នាក់ដឹកនាំ ឬអ្នកទទួលភារកិច្ចនោះបានដឹង និងស្វែងយល់បានអំពីតម្រូវការជាក់ស្តែង និងបញ្ហាបានដែលកើតមានឡើងក្នុងភូមិសាស្ត្រនោះអាចត្រៀម ឬលើកផែនការដើម្បីឆ្លើយតបជាមួយសភាពការណ៍ទាំងនោះក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធិភាព។

ដូច្នេះការស្វែងយល់ឱ្យបានស៊ីជម្រៅអំពីផ្នែកភូមិសាស្ត្រ និងប្រជាសាស្ត្រនៃតំបន់មួយគឺពិតជា មានសារៈសំខាន់ និងមិនអាចមើលរំលងបានឡើយ។ យ៉ាងណាមិញប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន គឺមានបញ្ហាផ្សេងៗគ្នា តម្រូវការចាំបាច់ផ្សេងគ្នា ចំណេះដឹងខុសៗគ្នា ការប្រកបមុខរបរចិញ្ចឹមជីវិតខុសៗគ្នាកម្រិតជីវភាព និងការទទួលផលប្រយោជន៍ពីការរីកចម្រើនរបស់ខណ្ឌខុសៗគ្នាទាំងអស់។

#### ១.១.១.១. ប្រវត្តិរបស់សាលាខណ្ឌចំការមន

ខណ្ឌចំការមន ត្រូវបានបែងចែកទៅ ជា ១២ សង្កាត់ និង ៨៥ ភូមិ។ ដែលសង្កាត់ទាំងនោះមានដូចជា សង្កាត់ទន្លេបាសាក់ សង្កាត់បឹងកេងកងទី១ សង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់អូឡាំពិក សង្កាត់ទួលស្វាយព្រៃទី១ សង្កាត់ទួលស្វាយព្រៃទី២ សង្កាត់ទំនប់ទឹក សង្កាត់ទួលទំពូងទី១ សង្កាត់ទួលទំពូងទី២ សង្កាត់បឹងត្របែក សង្កាត់ផ្សារដើមថ្កូវ។ ខណ្ឌនេះមានផ្ទៃក្រឡាសរុប ១០,៧៨ គ.ម$^{២}$។ តាមរយៈជំរឿនឆ្នាំ ១៩៩៨ របស់ប្រទេសកម្ពុជា ខណ្ឌនេះមានប្រជាជន ១៨៧,០០៤នាក់។ ឈ្មោះខណ្ឌ ត្រូវបានគេសរសេរជាអក្សរឡាតាំងថា **Chamka Morn** តាមរយៈប្រព័ន្ធឡាតាំងយានកម្មដែលបានប្រើប្រាស់ក្នុងកំឡុងឆ្នាំ ១៩៥០ និងឆ្នាំ

[1] ដកស្រង់ចេញពីគេហទំព័រ http://freshnewsasia.com/index.php/en/localnews ដកស្រង់នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២១

១៩៦០។ អាសយដ្ឋានទំនាក់ទំនង សាលាខណ្ឌចំការមនចាស់ នៅ ផ្ទះលេខ១៦៩, ១៧១, ១៧៣, ១៧៥ មហាវិថីម៉ៅសេទុង សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ក្បែរស្តុបទួលទំពូង។[2]

ខណ្ឌចំការមនត្រូវបានបំបែកជា២ យោងតាមអនុក្រឹត្យ លេខៈ ០៣ អនក្រ.បក ចុះ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតខណ្ឌបឹងកេងកងថ្មី នៃរាជធានីភ្នំពេញដែលបានយកទីតាំងសាលាខណ្ឌចំការមន ជាទីតាំងសាលាខណ្ឌបឹងកេងកងថ្មី និង ទីតាំងសាលាខណ្ឌចំការមនថ្មី ត្រូវស្ថិតនៅសង្កាត់ទន្លេបាសាក់។[3]

#### ១.១.១.២. ស្ថានភាពភូមិសាស្រ្តរបស់ខណ្ឌ

ខណ្ឌចំការមន គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងកើតទល់នឹងខណ្ឌច្បារអំពៅ ដោយដងទន្លេបាសាក់ ខាងលិចទល់នឹងខណ្ឌបឹងកេងកង ខាងត្បូងទល់នឹងខណ្ឌមានជ័យ ខាងជើងទល់នឹងខណ្ឌដូនពេញ ដែលមានផ្ទៃដីសរុបមានទំហំ ៧,១៥១,៤២៤.៥៧ ម៉ែត្រការ៉េស្មើនឹង ៧១៥ហិកតា ១៤អា និង២៤សង់ទីអា។[4] ដោយការបង្កើតខណ្ឌបឹងកេងកងថ្មី បានបន្សល់ទុកឱ្យខណ្ឌចំការមនមានតែ៥សង្កាត់ ដូចជា សង្កាត់ទន្លេបាសាក់ សង្កាត់ទួលទំពូងទី១ សង្កាត់ទួលទំពូងទី២ សង្កាត់បឹងត្របែក និងសង្កាត់ផ្សារដើមថ្កូវ និងខណ្ឌបឹងកេងកង មានចំនួន០៧សង្កាត់គឺ សង្កាត់បឹងកេងកងទី១ សង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់អូឡាំពិក សង្កាត់ទួលស្វាយព្រៃទី១ សង្កាត់ទំនប់ទឹក និងសង្កាត់ទួលស្វាយព្រៃទី២ ។

#### ១.១.១.៣. ស្ថានភាពប្រជាសាស្រ្ត

ប្រជាពលរដ្ឋនៅក្នុងខណ្ឌចំការមន មានចំនួន ៩,៤៤២គ្រួសារ ដោយមានគ្រួសារអចិន្ត្រៃយ៍ចំនួន ៧,៣៣៨ គ្រួសារ និងគ្រួសារបណ្តោះអាសន្ន មានចំនួន ១,៩៦៥គ្រួសារ ដែរនៅក្នុងមានប្រជាពលរដ្ឋសរុបចំនួន ៤៧,០៥៣នាក់ ប្រជាពលរដ្ឋជាស្រ្តី មានចំនួន ២២,៦១២ ហើយប្រជាពលរដ្ឋខ្មែរ អាយុ ១៨ឆ្នាំឡើង មានចំនួន ៣០,៣៦៩ នាក់។[5]

### ១.១.២. សន្តិសុខ និងសណ្តាប់ធ្នាប់ខណ្ឌ

នៅក្នុងខណ្ឌមួយ ដែលមានការរស់នៅប្រកបទៅដោយចីរភាពបានលុះត្រាតែថា នៅក្នុងភូមិសាស្រ្តមួយនោះប្រកបដោយសន្តិសុខ និងសណ្តាប់ធ្នាប់។ ដែលនៅក្នុងសន្តិសុខត្រូវ បានកំណត់នៅក្នុងគោលដៅសំខាន់៣យ៉ាង រួមមានៈ

---

[2] គេហទំព័រ http://freshnewsasia.com/index.php/en/localnews ដកស្រង់ នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២១

[3] មាត្រា៣ នៃអនុក្រឹត្យលេខ ០៣ អនុក្រ.បក ស្តីពី ការបង្កើតខណ្ឌបឹងកេងកងនៃរាជធានីភ្នំពេញ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩

[4] របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី១

[5] របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី៣

- សុវត្ថិភាពបុគ្គល
- សុវត្ថិភាពសម្ភារៈ
- សុវត្ថិភាពចំណីអាហារ។[6]

**១.១.២.១. សុវត្ថិភាពបុគ្គល**

ការរស់នៅរបស់បុគ្គលម្នាក់ៗ ក្នុងសហគមន៍មួយក៏ដូចជា សង្គមជាតិមួយដែលប្រកបដោយសុខសាន្ត ជាមួយគ្នានេះផងដោយឈរលើ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដែលបានដាក់ចេញឱ្យអនុវត្តន៍ ដោយក្រសួងមហាផ្ទៃ ក៏បានចូលរួមយ៉ាងសកម្មក្នុងការការពារសុវត្ថិភាពបុគ្គល គឺគេហៅថា សុវត្ថិភាពបុគ្គល ។ ហើយ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព នេះលក្ខណៈសម្បត្តិ ៧ យ៉ាង រួមមាន៖

ទី១- ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាល ប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។

ទី២- គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

ទី៣- មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។

ទី៤- គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។

ទី៥- ដោះស្រាយវិវាទការនៅមូលដ្ឋាន ក្រៅប្រព័ន្ធតុលាការ ប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ទី៦- មានអនាម័យ មានសោភ័ណ្ឌភាពល្អ និងមានបរិស្ថានល្អ។

ទី៧- ឆ្លើយតបបានទាន់ពេលវេលា ចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាត កាចសាហាវ ប្រកបដោយប្រសិទ្ធភាព។[7]

ដើម្បីឆ្លើយតបទៅ នឹងស្ថានភាពបច្ចុប្បន្ន និងកៀរគរឲ្យមាន ការចូលរួមគាំទ្រ កាន់តែច្រើនថែមទៀត រាជរដ្ឋាភិបាលសម្រេចកែលម្អលក្ខណៈសម្បត្តិ នៃគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ព្រមទាំងលើកកម្រិតគោលនយោបាយនេះជារបស់រាជរដ្ឋាភិបាល ដែលមានគោលបំណង និងសំណូមពរ ដូចខាងក្រោម៖

ទី១- បន្តកសាង និងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គមលើកកម្ពស់អនាម័យ បរិស្ថាន សុខមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឲ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

---

[6] សៀវភៅ នីតិរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពផ្សាយឆ្នាំ ២០១៩ ទំព័រទី១

[7]គេហទំព័រ https://interior.gov.kh/news/detail/2225 ដកស្រង់ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០២១

ទី២- កសាងបានជា កម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដោយបំផុសឲ្យមានកិច្ចសហការចូលរួម ជាមួយសមត្ថកិច្ចពីវិស័យសាធារណៈវិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។[8]

ទោះជាទទួលបានលទ្ធផលគួរជាទីមោទនៈក៏ពិតមែន ប៉ុន្តែការប្រព្រឹត្តទៅនៃចលនាអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពនៅមានបញ្ហាប្រឈម ជាច្រើនដែលពាក់ព័ន្ធ ដល់ការងារពង្រឹងតួនាទីដឹកនាំការផ្សព្វផ្សាយគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ការកសាងកម្លាំងប្រជាការពារ ការរៀបចំវេទិកាសាធារណៈពិសេសការបំផុសចលនាប្រឡងប្រណាំង នៅមិនទាន់ស៊ីជម្រៅដែលមានលក្ខណៈ ស្មុគស្មាញ និងបន្ទុកការងារកាន់តែច្រើន។ ដូចនេះ គណៈបញ្ជាការឯកភាព ក្រុង ខណ្ឌ កងកម្លាំងមានសមត្ថកិច្ច ព្រមទាំងមាននូវ អាជ្ញាធរពាក់ព័ន្ធត្រូវបន្តប្រកាន់ខ្ជាប់នូវទស្សនៈ ភូមិ-ឃុំ មានសុវត្ថិភាព ជាភារកិច្ចសំខាន់សម្រាប់កិច្ចការប្រចាំថ្ងៃរបស់ខ្លួន។ ត្រូវបង្កើនការប្រមូលផ្តុំដឹកនាំ ក្នុងមូលដ្ឋានឱ្យចូលរួមយ៉ាងសកម្ម ក្នុងការរក្សាសន្តិសុខសណ្តាប់ធ្នាប់ សាធារណៈតាមរយៈការកសាងផែនការប្រើប្រាស់កម្លាំងសរុបវិធានការសរុប និងមធ្យោបាយសរុបព្រមទាំង មានកម្មវិធីប្រជុំបូកសរុប ដកពិសោធន៍តាមដំណាក់កាលនីមួយៗ សំដៅកែលម្អបង្កើនប្រសិទ្ធភាពថែមទៀត សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់ខ្លួន។ បង្កើនការរៀបចំ នូវវេទិកាសាធារណៈឱ្យកាន់តែសកម្មបន្ថែមទៀត ដោយយកចិត្តទុកដាក់ខ្ពស់អំពីគុណភាព នៃការទទួលបានព័ត៌មាន អំពីទុក្ខកង្វល់របស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ ព្រមទាំងបានខិតខំដោះស្រាយនូវរាល់សំណូមពរដែលប្រជាពលរដ្ឋបានលើកឡើងឱ្យរួសរាន់ ប្រកបដោយស្មារតីទទួលខុសត្រូវ គឺសំដៅដល់ការធ្វើឱ្យវេទិកាសាធារណៈមួយឱ្យទទួលបាននូវគុណប្រយោជន៍ ពិតៗ ហើយគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ក្នុងរាជធានី/ខេត្ត ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឱ្យការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ទទួលបានលទ្ធផលល្អធានាការពារសន្តិសុខ និងសណ្តាប់ធ្នាប់ជូនដល់ប្រជាពលរដ្ឋគ្រប់ទីកន្លែង ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ។[9]

### ១.២.២.២. សុវត្ថិភាពសម្ភារៈ

សុវត្ថិភាពសម្ភារៈ គឺចង់សំដៅដល់ការគ្រប់គ្រងសម្ភារៈរួមរបស់ប្រជាពលរដ្ឋនៅក្នុងខណ្ឌមួយដោយមិនមានភាពចលាចរនៅក្នុងខណ្ឌ ដូចជាមិនមានការលួចសម្ភារៈ ឬគាស់ផ្ទះរបស់ប្រជាជន មិនមានក្មេងទំនើងមិនមានការប្រព្រឹត្តអំពើអនាចារ មិនមានអំពើល្បែងស៊ីសង មិនមានអំពើលួច ឬបំផ្លិចបំផ្លាញវត្ថុសាធារណៈមិនមានការប្លន់ ឬគាស់ទូរធនាគារ ឬអំពើចារកម្មផ្សេងៗដែលនាំឱ្យមានភាពអសន្តិសុខ ដែលធ្វើឱ្យមានភាព

[8] គេហទំព័រ https://interior.gov.kh/news/detail/2225 ដកស្រង់ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០២១

[9] គេហទំព័រ https://www.interior.gov.kh/report/detail/2325 ដកស្រង់ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០២១

ភ័យខ្លាចដល់ការរស់នៅរបស់ប្រជាជននៅតាមតំបន់ផងដែរ។ ជាមួយគ្នានេះផងដែរ ក៏ត្រូវមានសន្តិសុខ សុវត្ថិភាពដោយមានយកចិត្តទុកដាក់ពីសំណាក់មន្ត្រីជំនាញ ឬមន្ត្រីដែលពាក់ព័ន្ធបន្ថែមសម្រាប់ផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋជាមួយនឹងការការពារ ដោយការយកចិត្តទុកដាក់ខ្ពស់ជាមួយ នឹងបញ្ហាសន្តិសុខដោយអនុវត្តតាមគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព។ លើសពីនេះទៅទៀត តាមរយៈសុវត្ថិភាពសម្ភារៈនេះផងដែលធ្វើឱ្យមានការអភិវឌ្ឍ និងការវិនិយោគជាច្រើនដែលធ្វើឱ្យប្រជាពលរដ្ឋនៅក្នុងតំបន់ មានឱកាសទទួលបានការងារ និងជម្រុញឱ្យមានសេដ្ឋកិច្ចនៅក្នុងគ្រួសារកាន់តែកើនឡើង។

### ១.១.២.៣. សុវត្ថិភាពចំណីអាហារ

ចំណីអាហារ គឺជាវត្ថុមួយដែលគេបរិភោគ និងផឹកដើម្បីទទួលបាននូវសារធាតុចិញ្ចឹមនានា និងផ្តល់ថាមពលដែលសម្រាប់លូតលាស់ និងធ្វើសកម្មភាពនានា។

សុវត្ថិភាពចំណីអាហារនៅកម្ពុជា មិនទាន់ស្របទៅតាមស្តង់ដារសុវត្ថិភាព ទៅតាមការចង់បានរបស់ភ្ញៀវទេសចរណ៍នៅឡើយទេនិយាយជារួម និងនិយាយដោយឡែកសម្រាប់អ្នកធ្វើការក្នុងវិស័យទេសចរណ៍នៅកម្ពុជា។[10] ហើយបច្ចុប្បន្ននេះទាំងអាជ្ញាធរកាំកុងត្រូ រដ្ឋាភិបាល ក៏ដូចជាមន្ត្រីពាក់ព័ន្ធផ្សេងៗបានខិតខំព្យាយាមទប់ស្កាត់ បន្លែ ផ្លែឈើ សាច់ ត្រី គ្រឿងសមុទ្រ និងចំណីអាហារកំប៉ុង ដែលមិនមានគុណភាព ដែលកំពុងមានការចែកចាយនៅក្នុងទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះដែល ដោយសារតម្រូវការចំណីអាហារនៅក្នុងច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចនេះដើម្បីបំពេញតម្រូវការឱ្យគ្រប់នូវការប្រើប្រាស់នេះត្រូវទាមទារឱ្យមានចូលរួមពីប្រជាពលរដ្ឋក្នុងការដាំដំណាំ បន្លែផ្លែឈើ គ្មានសារជាតិ គីមីដោយខ្លួនឯង ទុកប្រើប្រាស់ផងនិងដាក់លក់នៅលើទីផ្សារផង ដើម្បីផ្តល់សុវត្ថិភាពដល់ខ្លួនឯង ក្រុមគ្រួសារ និងសង្គមជាតិផងដែរ។ ក្នុងនោះដែល ចំពោះអ្នកផលិតម្ហូបអាហារដើម្បីចូលរួម ក្នុងការបម្រើដល់សុខភាព របស់អ្នកប្រើប្រាស់ត្រូវមានគុណធម៌សច្ចធម៌ មានបច្ចេកទេសខ្ពស់ កុំដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់អ្នកដទៃតាមរយៈការលក់ របស់ដែលមិនមានគុណភាពទៅឱ្យអតិថិជន។ ចំពោះអ្នកប្រើប្រាស់ក៏គួរគប្បីស្វែងយល់ឱ្យបានច្រើននូវរាល់ ផលិតផលណាដែលគួរប្រើប្រាស់ និងមិនគួរប្រើប្រាស់ដូចគ្នាផងដែរ។ សម្រាប់អ្នកប្រើប្រាស់ទាំងអស់ ដើម្បីទទួលបានសុវត្ថិភាពចំណីអាហារ បើអាចពិនិត្យលើគុណភាព ចំណីអាហារ ក៏គួរគប្បីមុននឹងទិញផលិតផលយកទៅប្រើប្រាស់ យ៉ាងហោចណាស់ក៏បានពិនិត្យមើលទៅលើ កាលបរិច្ឆេទផុតកំណត់ឱ្យបានមួយចំណុចមុនសិនដែរ។ ដើម្បីធានាឱ្យដឹងថាផលិតផលនោះនៅអាចប្រើប្រាស់បាន ហើយបើកន្លែងបរិច្ឆេទផុតកំណត់មានការកោសលុប ឬមានជាន់គ្នានោះ យើងមិនត្រូវទិញយកទៅប្រើ ប្រាស់នោះឡើយ។

[10] គេហទំព័រ https://www.moeys.gov.kh/index.php/kh ដកស្រង់ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០២១

ជារួមអាហារដែលមានសុវត្ថិភាព គឺយើងត្រូវពិនិត្យទៅលើបញ្ហាមួយចំនួនដែលជាកត្តាចាំបាច់ដូចជាៈ កាលបរិច្ឆេទនៃការផុតកំណត់ អនាម័យ ការវេចខ្ចប់ ការទទួលស្គាល់ជាលក្ខណៈស្តង់ដារ ជាពិសេសជាងនេះទៅទៀតចំពោះស្ថាប័នដែលពាក់ព័ន្ធខាងផ្នែកចំណីអាហារ គឺត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងថែរក្សាសុខភាពប្រជាជន និងអនុវត្តយ៉ាងតឹងរឹងតាមរយៈការចុះត្រួតពិនិត្យទំនិញខុសច្បាប់ និងដាក់ទោសជនដែលនាំចូល ឬលក់ផលិតផលចំណីអាហារដែលខូចគុណភាព ដែលនាំឱ្យមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់។ ជាមួយគ្នានេះផងដែរ ប្រជាពលរដ្ឋដែលលក់ចំណីអាហារក៏ត្រូវចូលរួមចំណែកដូចគ្នា ក្នុងការថែរក្សាអនាម័យចំណីអាហារដើម្បីសុខភាពអ្នកបរិភោគ។

បើយោងតាមរយៈសេចក្តីណែនាំលេខ១៨ អយក.សណន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដែលត្រូវបានហាមឃាត់មាន៦ប្រភេទ ដូចខាងក្រោមៈ

- ចំណីអាហារគ្រប់ប្រភេទដែលហួសកំណត់កាលបរិច្ឆេទ
- គ្រឿងស្រវឹង និងផលិតផលថ្នាំជក់គ្រប់ប្រភេទ
- ចំណីអាហារដែលមិនមានប្រភពច្បាស់លាស់
- ភេសជ្ជៈប៉ូវកម្លាំង ភេសជ្ជៈផ្អែមខ្លាំង កាហ្វេ កាហ្វេអ៊ីន ទឹកស៊ីរ៉ូហ៍គ្រប់ប្រភេទ
- ស្ករសូកូឡា ស្ករគ្រាប់ និងស្ករកៅស៊ូគ្រប់ប្រភេទ
- ចាហួយគ្រប់ប្រភេទ នំដូណាត់ នំផ្អែមខ្លាំងៗ។[11]

តាមការលើកឡើងរបស់ លោកប្រធានសហព័ន្ធសហជីពកម្មករនិយោជិកវិស័យទេសចរណ៍ និងសេវាកម្មកម្ពុជា ខណៈពេលដែលរដ្ឋាភិបាលកំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពី «សុវត្ថិភាពម្ហូបអាហារ»។ ហើយសេចក្តីព្រាងច្បាប់ស្តីពី សុវត្ថិភាពម្ហូបអាហារ ដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២១។[12]

## ១.២. រចនាសម្ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាលខណ្ឌ

ការគ្រប់គ្រងមួយអាចប្រកបទៅដោយប្រសិទ្ធភាព គឺអាស្រ័យទៅលើថ្នាក់ដឹកនាំរបស់ខ្លួនដែលមានសមត្ថភាពក្នុងការដឹកនាំត្រូវបានធ្វើការបែងចែកនូវតួនាទីភារកិច្ច ទៅតាមផ្នែកជំនាញបច្ចេកទេសរបស់បុគ្គលិក។ ម្យ៉ាងទៀតការគ្រប់គ្រងរដ្ឋបាលវិញក៏មិនខុសគ្នាដែរ គឺត្រូវមានការបែងចែករចនាសម្ព័ន្ធ នៃការគ្រប់គ្រងហើយមានការកំណត់ពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចឲ្យបានច្បាស់លាស់។

---

[11] គេហទព័រ http://freshnewsasia.com/index.php/en/localnews/144518-2020-01-04-14-31-43.html ដកស្រង់ថ្ងៃ ០៨ ខែ មិថុនា ឆ្នាំ ២០២១

[12] គេហទំព័រ https://www.moeys.gov.kh/index.php/kh ដកស្រង់ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២១

ជាក់ស្តែងរដ្ឋបាលខណ្ឌដើម្បីឱ្យការគ្រប់គ្រងមានភាពងាយស្រួល និងឆាប់រហ័សនោះ ក្រុមប្រឹក្សាដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**១.២.១. រចនាសម្ព័ន្ធគ្រប់គ្រង**

អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ បានកំណត់រចនាសម្ព័ន្ធ នៃរដ្ឋបាលខណ្ឌគឺ ត្រូវបានគ្រប់គ្រងដោយ ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ នាយករដ្ឋបាល គណៈកម្មាធិការ ការិយាល័យប្រជាពលរដ្ឋ និងការិយាល័យ និងអង្គភាពចំណុះ។

**១.២.១.១. ក្រុមប្រឹក្សាខណ្ឌ**

ក្រុមប្រឹក្សាខណ្ឌត្រូវបានបង្កើតឡើង ដោយការបោះឆ្នោតអសកលស្របតាមនីតិវិធីដែលបានកំណត់ដោយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលមានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលក្រុមប្រឹក្សាថ្មីចូលកាន់ដំណែង។ ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខដំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធអនុវត្តតែកិច្ចការអនុវត្តប្រចាំថ្ងៃតែប៉ុណ្ណោះ។[13]

ក្រុមប្រឹក្សាខណ្ឌ គឺមានតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[14]

❖ សិទ្ធអំណាច

ក្រុមប្រឹក្សា មានសិទ្ធអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។ ក្រុមប្រឹក្សា ប្រើប្រាស់អំណាចបញ្ញត្តិ របស់ខ្លួនតាមរយៈការធ្វើដីកា និងប្រើប្រាស់អំណាចប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ហើយធានាថាសេចក្តីសម្រេចរបស់ខ្លួនអនុវត្តន៍។[15]

ក្រុមប្រឹក្សាអាចដាក់ចេញដីកា ដើម្បីកំណត់ហាមឃាត់ ត្រួតពិនិត្យលើសកម្មភាព ឬកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាព នៃតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួន ហើយក៏អាចកំណត់ការផាកពិន័យជាសាច់ប្រាក់ចំពោះការមិនគោរពតាមដីកានេះផងដែរ។[16] ទន្ទឹមនេះក្រុមប្រឹក្សាក៏អាចដាក់ចេញសេចក្តីសម្រេច

[13] មាត្រា១៤ និងមាត្រា១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[14] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ១១

[15] សៀវភៅស្តីពី នីតិរដ្ឋបាលទូទៅ រៀបរៀងដោយ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពឆ្នាំ២០១៧ ទំព័រទី ៦៦

[16] សៀវភៅស្តីពី នីតិរដ្ឋបាលទូទៅ រៀបរៀងដោយ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពឆ្នាំ២០១៧ ទំព័រទី ៦៧

របស់ក្រុមប្រឹក្សាមានពីរប្រភេទ គឺសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក្នុងអង្គប្រជុំក្រុមប្រឹក្សាដោយត្រូវកត់ត្រានៅក្នុងកំណត់ហេតុ នៃកិច្ចប្រជុំក្រុមប្រឹក្សា។[17]

ទន្ទឹមនេះ ក្រុមប្រឹក្សាអាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញពីដំណែង ក្នុងករណីអភិបាល អភិបាលរងនោះមានករណីណាមួយដូចខាងក្រោម៖

- បាត់បង់លក្ខណៈសម្បត្តិ
- អសមត្ថភាព
- បំពេញការងារមិនបានល្អ
- មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ
- បោះបង់ចោលការងារ
- ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។[18]

❖ តួនាទី និងភារកិច្ច

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើតជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ដែលបានប្រគល់ ឬ ដែលបានធ្វើប្រតិភូកម្ម ដោយមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

➢ ការងាររៀបចំកិច្ចប្រជុំក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងតិចចំនួន១២ដងក្នុងមួយឆ្នាំ ទៅតាមប្រតិទិនដែលបានអនុម័តដោយក្រុមប្រឹក្សា។ ក្រៅពីកិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់។[19]

➢ ការងាររៀបចំបទបញ្ជាផ្ទៃក្នុង

ក្រោយប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់វិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងតាម ទម្រង់ជាដីកា និងត្រូវអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ ដែលប្រព្រឹត្តទៅមិនឱ្យមុន ២៥ថ្ងៃ ឬលើសពី ៣៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១។[20]

[17] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ១២
[18] សៀវភៅស្តីពី នីតិរដ្ឋបាលទូទៅ រៀបរៀងដោយ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពឆ្នាំ២០១៧ ទំព័រទី ៨០
[19] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទព័រទី ១២
[20] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ១២

➢ ការងាររៀបចំវិធានគ្រប់គ្រងផ្ទៃក្នុង

ក្រុមប្រឹក្សានៃអាណត្តិនីមួយៗត្រូវរៀបចំ និងអនុម័តដីកាស្ដីពីវិធានគ្រប់គ្រងផ្ទៃក្នុង ដើម្បីធានានូវការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

➢ ការងាររៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

ក្រុមប្រឹក្សាត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ខ្លួន ក្នុងអំឡុងខែមិថុនា នៃឆ្នាំនីមួយៗដោយត្រូវធ្វើឡើងនៅតាមសង្កាត់នានាក្នុងខណ្ឌ ក្នុងគោលបំណងផ្តល់ឱកាសឱ្យក្រុមប្រឹក្សាដើម្បី៖

- ផ្តល់នូវព័ត៌មាន៖ ក្រុមប្រឹក្សារាយការណ៍អំពីសកម្មភាពរបស់ខ្លួននៅក្នុងឆ្នាំកន្លងមក និងបង្ហាញពីផែនការសម្រាប់ឆ្នាំខាងមុខ
- ផ្តល់ប្រឹក្សា៖ អ្នកចូលរួមពិភាក្សាអំពីលទ្ធផល ផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សាអំពីការងារ នៅក្នុងឆ្នាំកន្លងមក និងលើកជាសំណើសម្រាប់ឆ្នាំបន្ទាប់
- ជំរុញឱ្យមានការចូលរួម៖ អ្នកចូលរួមអាចរួមចំណែកនៅក្នុងដំណើរការ នៃការធ្វើសេចក្តីសម្រេចចិត្ត ដែលក្នុងនោះសំណើ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋត្រូវបានលើកយកមក ពិចារណានៅក្នុងការសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សា
- លើកកម្ពស់ការសហការ៖ ក្រុមប្រឹក្សាទទួលបានព័ត៌មានប្រសើរជាងមុនអំពីតម្រូវការរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍនៅមូលដ្ឋាន។ វេទិកា របស់ក្រុមប្រឹក្សាជម្រុញ និងលើកកម្ពស់កិច្ចសហការគ្នារវាង ក្រុមប្រឹក្សា និងប្រជាពលរដ្ឋ។ វេទិកានេះ ចូលរួមចំណែកក្នុងការបង្កើតនូវដំណោះស្រាយ ដែលផ្តល់ផលប្រយោជន៍ ដល់ប្រជាពលរដ្ឋ។[21]

➢ ការងារផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ក្រោយប្រកាសចូលកាន់តំណែង ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥)ឆ្នាំ យ៉ាងយូរត្រឹមឆ្នាំទី២ នៃអាណត្តិរបស់ក្រុមប្រឹក្សា។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(៥)ឆ្នាំត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមរយៈការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ។ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(៣) ឆ្នាំរំកិលប្រចាំឆ្នាំ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋប្រភេទក្រុមប្រឹក្សាផ្សេង និងអ្នកពាក់ព័ន្ធនានាដោយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម ៖

- ការចែករំលែកព័ត៌មាន

[21] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ១២

- តម្លាភាព
- សង្គតិភាព និងសុខដុមនីយកម្ម
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម
- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌។[22]

➢ ការអនុវត្តមុខងារ

ក្រុមប្រឹក្សាត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាថារាល់មុខងារដែលផ្ទេរទៅឱ្យក្រុមប្រឹក្សារួមទាំងមុខងារជាអាណត្តិទូទៅដែលក្រុមប្រឹក្សាបានសម្រេចជ្រើសរើសយកមកអនុវត្ត ត្រូវបានយកទៅអនុវត្តយ៉ាងពេញលេញប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន។ ទន្ទឹមនេះក្រុមប្រឹក្សាក៏ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងផ្តល់យោបល់ការអនុវត្តមុខងារទាំងនោះតាមរយៈការពិនិត្យ ពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដោយមានគណៈអភិបាលជាអ្នកធ្វើសេចក្តីរាយការណ៍ពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារទាំងនោះ។[23]

➢ ការងារគ្រប់គ្រងបុគ្គលិក

ក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួននៅរដ្ឋបាលខណ្ឌ ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តលើការងារសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ការរៀបចំផែនការបុគ្គលិក
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាល និងប្រធានការិយាល័យ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែល
- ការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិក។[24]

---

[22] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ១៣
[23] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ១៣
[24] សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ១៤

➢ ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

ក្រុមប្រឹក្សាត្រូវគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខ្លួនទៅតាមរបៀបដែលបើកចំហ និងមានតម្លាភាពចំពោះប្រជាពលរដ្ឋ របស់ខ្លួន។[25]

### ១.២.១.២. គណៈអភិបាលខណ្ឌ និងនាយករដ្ឋបាល

❖ គណៈអភិបាលខណ្ឌ

គណៈអភិបាលខណ្ឌចំការមនមានចំនួន ៥រូប ដែលមានអភិបាលខណ្ឌចំនួន ១រូប និងអភិបាលរងខណ្ឌចំនួន ៤រូប ក្នុងនោះមានស្ត្រី ១រូប ។[26] អភិបាលខណ្ឌ និងអភិបាលរងខណ្ឌ មិនមែនជាសមាជិកក្រុមប្រឹក្សាទេ។

គណៈអភិបាលខណ្ឌ មានភារៈកិច្ចផ្តល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាខណ្ឌ និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខណ្ឌទាំងសេចក្តីសម្រេចខាងនីតិបញ្ញត្តិ និងសេចក្តីសម្រេចខាងនីតិប្រតិបត្តិ ។

អភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិលទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង
- មានអាយុចាប់ពីសាមសិប (៣០) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចប្រាំ(៥)ឆ្នាំ ឬ/និងមានសញ្ញាបត្រ បរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេល នៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។[27]

ដោយឡែក អភិបាលរង ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិលទាំងពីរភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង
- មានអាយុចាប់ពីម្ភៃប្រាំ (២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

[25] សៀវភៅស្តីពី នីតិរដ្ឋបាលទូទៅ រៀបរៀងដោយ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពឆ្នាំ២០១៧ ទំព័រទី ៦៩

[26] របាយការប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី ៨

[27] មាត្រា១៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- មានបទពិសោធជន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចបី(៣)ឆ្នាំ ឬ/និងមានសញ្ញាបត្រ បរិញ្ញាបត្ររង ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេល នៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។[28]

គណៈអភិបាល មានតួនាទីពីរប្រភេទគឺតួនាទីផ្តល់យោបល់ និងរាយការណ៍ និងតួនាទីគ្រប់គ្រង។ តួនាទីផ្តល់យោបល់ និងរាយការណ៍ គឺដើម្បីផ្តល់សេចក្តីអធិប្បាយ និងមតិយោបល់ជូនក្រុមប្រឹក្សា និងរាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សា។ ដោយឡែកតួនាទីគ្រប់គ្រង គឺគាំទ្រក្រុមប្រឹក្សាក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ហើយគណៈអភិបាល អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឬ ធានាឱ្យបានថាមន្ត្រី បុគ្គលិក និងអង្គភាពរបស់ក្រុមប្រឹក្សា អនុវត្តសេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាយ៉ាងមានប្រសិទ្ធភាព។[29]

❖ នាយករដ្ឋបាល

នាយករដ្ឋបាល ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឲ្យបំពេញការងារជាមួយក្រុមប្រឹក្សា។ នាយករដ្ឋបាលនេះ មានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។ នាយករដ្ឋបាល ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។

នាយករដ្ឋបាល មានតួនាទីយ៉ាងសំខាន់នៅក្នុងរដ្ឋបាលថ្មីគឺៈ

- ទទួលខុសត្រូវលើការពិនិត្យមើលថា សេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា និងគណៈអភិបាលត្រូវបានអនុម័ត
- ធានាឱ្យបានថា ប្រធានហិរញ្ញវត្ថុបំពេញ ការងាររបស់ខ្លួនបានត្រឹមត្រូវ
- អនុវត្តកិច្ចការប្រចាំថ្ងៃ
- គណៈអភិបាល អាចធ្វើប្រតិភូកម្មការងារទៅឱ្យនាយករដ្ឋបាលដើម្បីលើកយោបល់ជូនគណៈអភិបាលសម្រេច។

ទោះជាយ៉ាងណាក៏ដោយ នាយករដ្ឋបាលមិនគ្រាន់តែអនុវត្ត សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលប៉ុណ្ណោះទេថែមទាំងដើរតួនាទីយ៉ាងសកម្មនៅក្នុងការគ្រប់គ្រងរដ្ឋបាលផងដែរ។

- នាយករដ្ឋបាល ត្រូវចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក៏ប៉ុន្តែពុំមានសិទ្ធបោះឆ្នោតឡើយ

[28] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទព័រទី ១៩
[29] សៀវភៅស្តីពី នីតិរដ្ឋបាលទូទៅ រៀបរៀងដោយ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពឆ្នាំ២០១៧ ទំព័រទី ៨០

- នាយករដ្ឋបាល ត្រូវផ្ដល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានា របស់ក្រុមប្រឹក្សាដើម្បីក្រុមប្រឹក្សា សម្រេចបាននូវគោលបំណងក្នុងការបង្កើតការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- នាយករដ្ឋបាល ផ្ដល់យោបល់ដល់គណៈអភិបាលដើម្បីគណៈអភិបាលអនុវត្តន៍ មុខងារ និងភារកិច្ចរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។[30]

រដ្ឋបាលខណ្ឌនីមួយៗ មាននាយករដ្ឋបាល ១រូប និងនាយករងរដ្ឋបាលយ៉ាងច្រើន ២រូប ជាជំនួយការ។ នាយករដ្ឋបាល គឺជាបុគ្គលិកមានឋានន្តរស័ក្តិទាបបំផុតត្រឹមក្រមការដើមខ្សែ (ក្របខ័ណ្ឌ ខ២) ដែល តែងតាំងឱ្យទៅបំពេញការងារ ជាមួយក្រុមប្រឹក្សាតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ តួយ៉ាង នាយករដ្ឋបាល មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សាខណ្ឌ និងអភិបាលខណ្ឌ និងអភិបាលរងខណ្ឌ ក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខណ្ឌ ។

**១.២.១.៣. គណៈកម្មាធិការ និងការិយាល័យប្រជាពលរដ្ឋ**

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ឱ្យក្រុមប្រឹក្សាមានគណៈកម្មាធិការកាតព្វកិច្ចចំនួនបីគឺ៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម

ក្រៅពីគណៈកម្មាធិការ ជាកាតព្វកិច្ចទាំងបីខាងលើក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារបន្ថែមផ្សេងទៀតតាមការចាំបាច់ ប៉ុន្តែមិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយតួនាទីភារកិច្ចរបស់គណៈកម្មាធិការទាំងបី ឬតួនាទីភារកិច្ចរបស់គណៈអភិបាលឡើយ។[31]

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាខណ្ឌដឹកនាំដោយអភិបាល និងមានតួនាទីភារកិច្ចផ្ដល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលលើកិច្ចការសំខាន់ៗដូចខាងក្រោម ៖

- ការរៀបចំផែនការអភិវឌ្ឍ និងថវិកា
- ការសម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាជាមួយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ន ការធ្វើកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខណ្ឌ

[30] សៀវភៅស្តីពី នីតិរដ្ឋបាលទូទៅ រៀបរៀងដោយ សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពឆ្នាំ២០១៧ ទំព័រទី ៩៧
[31] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ១៥

- ការធ្វើកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាខណ្ឌជាមួយក្រុមប្រឹក្សាសង្កាត់ នៅក្នុងខណ្ឌ
- ការធ្វើកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាខណ្ឌជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត
- ការងារគ្រប់គ្រង និងចាត់ចែងមុខងារ និងធនធាន។[32]

❖ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៃរដ្ឋបាលខណ្ឌដឹកនាំដោយ សមាជិកក្រុមប្រឹក្សា ០១រូបជាស្ត្រី ឬអភិបាលរង០១រូបជាស្ត្រី និងមានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាល ពាក់ព័ន្ធការងារយេនឌ័រ ស្តីពី យុវវ័យ និងកុមារ។[33]

❖ គណៈកម្មាធិការលទ្ធកម្ម

គណៈកម្មាធិការលទ្ធកម្មដឹកនាំដោយអភិបាល និងមានតួនាទី ភារកិច្ចក្នុងការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំការប្រជុំបើកសំណើដេញថ្លៃ និងការប្រជុំវាយតម្លៃប្រគល់កិច្ចសន្យាជាដើម។[34]

❖ ការិយាល័យប្រជាពលរដ្ឋ

យោងអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការិយាល័យប្រជាពលរដ្ឋ គឺជាយន្តការអព្យាក្រឹតមួយដែលត្រូវបង្កើតឡើងនៅរដ្ឋបាលខណ្ឌនីមួយៗសម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ខណ្ឌ និងសង្កាត់។[35]

ការិយាល័យប្រជាពលរដ្ឋដឹកនាំដោយ ប្រធានមួយ(១)រូប ដែលកើតឡើងពីការបោះឆ្នោត និងមានបុគ្គលិកមួយចំនួនជាជំនួយការ។ ប្រធានការិយាល័យប្រជាពលរដ្ឋមានអាណត្តិការងារប្រាំ (៥) ឆ្នាំ។ [36]

មានតួនាទីជាអង្គភាពធ្វើសកម្មភាព ដោយអព្យាក្រឹត្យក្នុងការទទួលពាក្យបណ្តឹងតវ៉ាពីប្រជាពលរដ្ឋអំពីរដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងតវ៉ាទាំងនោះ។ ពាក្យបណ្តឹងតវ៉ា អាចលើកឡើងអំពីករណីណាមួយដូចខាងក្រោម៖

- ការសម្រេចចិត្ត ឬអាកប្បកិរិយាដែលផ្ទុយនឹងគោលការណ៍ច្បាប់
- ការបដិសេធ ឬការស្ទាក់ស្ទើរក្នុងការទទួលយកពាក្យស្នើសុំត្រឹមត្រូវតាមច្បាប់របស់ប្រជាពលរដ្ឋ

---

[32] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ១៥

[33] ប្រការ៣ ប្រកាសលេខ៤២៧៥ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

[34] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី១៥

[35] មាត្រា៣១ អនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យ ប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

[36] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី១៦

- មិនបានផ្តល់លទ្ធផល ឬដំណោះស្រាយសមស្របតាមពេលវេលាមួយដែលបានកំណត់
- មានឥរិយាបទមិនអាចទទួលយកបានដូចជា ការបំភិតបំភ័យ ឬការប្រមាថមាក់ងាយដល់ប្រជាពលរដ្ឋ ឬតំណាងសហគ្រាសនានា។[37]

### ១.២.១.៤. ការិយាល័យ និងអង្គភាពចំណុះ

រដ្ឋបាលខណ្ឌត្រូវបានកំណត់ឱ្យមានការិយាល័យចំណុះចំនួន១០ និងអង្គភាពចំណុះចំនួន១ ដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល និងបុគ្គលិក
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។[38]

ការិយាល័យ និងអង្គភាពនីមួយៗត្រូវដឹកនាំដោយប្រធានមួយ (០១)រូប និងមានអនុប្រធានយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ។ ប្រធានការិយាល័យមានឋានន្តរស័ក្តិទាបបំផុតត្រឹមក្រមការដើមខ្សែ (ក្របខ័ណ្ឌ ខ២) និងអនុប្រធានការិយាល័យមានឋានន្តរស័ក្តិទាបបំផុតត្រឹមក្រមការ (ក្របខ័ណ្ឌខ៣) ត្រូវតែងតាំងដោយដីការបស់រដ្ឋបាលរាជធានី។ ដោយឡែកចំពោះប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ និងប្រធានអង្គភាពលទ្ធកម្មមុនចេញដីកាតែងតាំង ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ [39]

---

[37] សៀវភៅ ស្តីពី ការិយាល័យប្រជាពលរដ្ឋ បោះពុម្ពលើកទី២ ឆ្នាំ២០១០ ទំព័រទី២

[38] មាត្រា៧ នៃអនុក្រឹត្យលេខ១៨៣ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធ រដ្ឋបាលខណ្ឌ

[39] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទព័រទី២៤

❖ ការិយាល័យរដ្ឋបាល និងបុគ្គលិក

ការិយាល័យរដ្ឋបាល និងបុគ្គលិក ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងាររដ្ឋបាល និងបុគ្គលិក និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងការងារសហ ប្រតិបត្តិការអន្តរជាតិ
- ការងារអត្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលខណ្ឌ
- ការពិនិត្យ និងលើកយោបល់លើការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ
- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលខណ្ឌតាមការផ្ទេរសិទ្ធិពីរដ្ឋបាលរាជធានី
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលខណ្ឌ
- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំរបស់រដ្ឋបាលខណ្ឌ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។[40]

នីតិវិធីរដ្ឋបាលត្រូវអនុវត្តតាម សៀវភៅណែនាំកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមទាំងការងារជំនាញដែលពីមុនធ្លាប់ធ្វើឡើង ដោយប្រធានការិយាល័យជំនាញទៅ ប្រធានមន្ទីរ អង្គភាពជំនាញថ្នាក់រាជធានី ត្រូវធ្វើតាមនីតិវិធីរដ្ឋបាលរបស់រដ្ឋបាលខណ្ឌ។

❖ ការិយាល័យផែនការ និងហិរញ្ញវត្ថុ

ការិយាល័យផែនការ និងហិរញ្ញវត្ថុ ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារផែនការ និងហិរញ្ញវត្ថុ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល
- ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលខណ្ឌ
- ការសិក្សា ការរៀបចំ និងការអនុវត្តគម្រោងនានារបស់រដ្ឋបាលខណ្ឌ
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលខណ្ឌ
- ការងារស្ថិតិប្រជាជន
- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ខណ្ឌតាមការកំណត់

[40] មាត្រា១៣ អនុក្រឹត្យលេខ១៨៣ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ខណ្ឌ
- ការងារហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលខណ្ឌ ការងាររបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលខណ្ឌ
- ការគាំទ្រដល់រដ្ឋបាលសង្កាត់ក្នុងខណ្ឌតាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។[41]

❖ អង្គភាពលទ្ធកម្ម

អង្គភាពលទ្ធកម្ម ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារលទ្ធកម្មសាធារណៈ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្តល់ឯកសារ ទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើ ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។[42]

❖ ការិយាល័យលេខាធិការក្រុមប្រឹក្សា

ការិយាល័យលេខាធិការក្រុមប្រឹក្សា ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារលេខាធិការដ្ឋានជូនក្រុមប្រឹក្សា និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា
- ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានារបស់ក្រុមប្រឹក្សា

[41] មាត្រា១៤ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ
[42] មាត្រា១៥ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា និងអភិបាលខណ្ឌ។[43]

❖ ការិយាល័យអប់រំ យុវជន និងកីឡា

ការិយាល័យអប់រំ យុវជន និងកីឡា ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារអប់រំ យុវជន និងកីឡា និងមានភារកិច្ចគ្រប់គ្រង គាំទ្រ សម្របសម្រួល និងតាមដាន ត្រួតពិនិត្យ វាយតម្លៃ លើមុខងារមួយចំនួនដូចខាងក្រោម៖

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា
- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយ និងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។[44]

❖ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- សំណង់
- ការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារលំនៅឋាន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។[45]

[43] មាត្រា១៦ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

[44] មាត្រា១៧ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកចុះ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

[45] មាត្រា១៨ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកចុះថ្ងៃ ទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

❖ ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន

ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារនីតិកម្ម និងការសម្រុះសម្រួលវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការ និងមានភារកិច្ចចាត់ចែងលើការងារមួយចំនួនដូចខាងក្រោម៖

- ការសិក្សាស្រាវជ្រាវ ការរៀបចំ និងការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលខណ្ឌ
- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដល់មន្ត្រី បុគ្គលិក និងប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌ
- ការផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ
- ការរៀបចំការបណ្តុះបណ្តាលជំនាញសម្រុះសម្រួល និងច្បាប់ដល់រដ្ឋបាលសង្កាត់ ក្នុងខណ្ឌ
- ការទទួលពាក្យបណ្តឹង និងការសម្រុះសម្រួលវិវាទនៅមូលដ្ឋាន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌស្របតាមច្បាប់កំណត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។[46]

❖ ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ

ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសាធារណការ និងដឹកជញ្ជូន
- ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ការគ្រប់គ្រងផ្សែង សម្លេង ក្លិន និងការបំពុលបរិយាកាស
- ការដាំ ការគ្រប់គ្រង និងការថែទាំដើមឈើ និងសួនច្បារសាធារណៈ
- ការគ្រប់គ្រងភ្លើងបំភ្លឺទីសាធារណៈ
- ការគ្រប់គ្រងចំណតយានយន្តសាធារណៈ
- ការងារសណ្តាប់ធ្នាប់សាធារណៈ

[46] មាត្រា១៩ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកចុះថ្ងៃ ទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។[47]

❖ ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍

ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការអភិវឌ្ឍសេដ្ឋកិច្ច ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍសហគមន៍ និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារឧស្សាហកម្ម និងសិប្បកម្ម
- ការងាររ៉ែ និងថាមពល
- ការងារទេសចរណ៍
- ការងារពាណិជ្ជកម្ម
- ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការងារធនធានទឹក
- ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
- ការងារអភិវឌ្ឍន៍សហគមន៍
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។[48]

❖ ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម

ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គម និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការងារសុខាភិបាល
- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោះមហន្តរាយ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។[49]

---

[47] មាត្រា២០ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកចុះថ្ងៃ ទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

[48] មាត្រា២១ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកចុះថ្ងៃ ទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

[49] មាត្រា២២ អនុក្រឹត្យលេខ ១៨៣ អនក្រ.បកចុះថ្ងៃ ទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ

❖ ការិយាល័យច្រកចេញចូលតែមួយ

ការិយាល័យច្រកចេញចូលតែមួយ ជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ក្នុងនោះផងដែរ ការិយាល័យច្រកចេញចូលតែមួយ ត្រូវបានរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

➢ ផ្នែកជួរមុខ គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់នានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទដាក់ពាក្យស្នើសុំបង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

➢ ផ្នែកជួរក្រោយ គឺជាផ្នែកដែលទទួលខុសត្រូវទ្រទ្រង់ដ៏សំខាន់លើការងារបច្ចេកទេស។ ផ្នែកជួរក្រោយមានតួនាទី ពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើការផ្តល់សេវារដ្ឋបាលតាមវិស័យជំនាញ។[50]

ការិយាល័យច្រកចេញចូលតែមួយ មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារផ្តល់សេវារដ្ឋបាលនានា និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ផ្តល់សេវាកម្មដល់អតិថិជន ពលរដ្ឋ សហគ្រាស និងអង្គការទាំងឡាយដែលកំពុងធ្វើសកម្មភាពនៅក្នុងមូលដ្ឋាន ក្រុង ស្រុក ខណ្ឌ
- ផ្តល់ព័ត៌មានទូទៅជូនប្រជាពលរដ្ឋ និងអតិថិជននានាក្នុងខណ្ឌ អំពីកិច្ចការរដ្ឋបាលនៅថ្នាក់ រាជធានី ខណ្ឌ សង្កាត់ (ដោយផ្ទាល់មាត់ ឫតាមទូរស័ព្ទ ឫតាមសៀវភៅព័ត៌មាននានា ដែលបានបោះពុម្ពផ្សាយ)
- ផ្តល់ព័ត៌មានអំពីនីតិវិធីរដ្ឋបាល ដែលជាសមត្ថកិច្ច របស់ថ្នាក់ជាតិ និងថ្លៃសេវាសម្រាប់នីតិវិធីទាំងនោះ ដែលពាក់ព័ន្ធ និងវិស័យសេដ្ឋកិច្ច ដីធ្លី ផែនការប្រើប្រាស់ដីធ្លីរួមទាំងព័ត៌មានអំពីការគាំពារសុខភាព អប់រំ វប្បធម៌ និងបញ្ហាសង្គមផងដែរ។[51]

### ១.២.២. ការគ្រប់គ្រងរដ្ឋបាល

ការស្វែងយល់អំពីការគ្រប់គ្រងរដ្ឋបាលរបស់ស្ថាប័ន ឫអង្គភាពមួយបានធ្វើឲ្យប្រជាពលរដ្ឋយល់ដឹង និងបង្ហាញឱ្យឃើញពីការចូលរួម របស់ប្រជាពលរដ្ឋក្នុងការធ្វើឱ្យមានការគ្រប់គ្រងរដ្ឋបាលរបស់ខណ្ឌមួយប្រកបទៅដោយភាពរលូន តាមរយៈការតាមដានការប្រតិបត្តិការការងាររបស់ស្ថាប័ន ឫ អង្គភាពនេះ។ បច្ចុប្បន្នក្រុមប្រឹក្សាខណ្ឌមាននាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជម្រុញ និងការធ្វើឱ្យ មានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចរបស់ខ្លួន។

[50] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៣២

[51] សៀវភៅស្តីពី ការិយាល័យច្រកចេញចូលតែមួយ បោះពុម្ពលើកទី២ ឆ្នាំ២០១០ ទំព័រទី១៩

**១.២.២.១. មុខងារ**

មុខងារ គឺជាអំពើ ឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងៗទៀត។ រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារខ្លួនដើម្បីបង្កើតជម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មុខងាររបស់រដ្ឋបាលខណ្ឌរួមមាន មុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដែលបានប្រគល់ ឬប្រតិភូកម្មដោយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។[52]

❖ មុខងារជាជម្រើស

មុខងារជាជម្រើស គឺជាមុខងារទាំងឡាយដែលផ្តួចផ្តើមជ្រើសរើសដោយក្រុមប្រឹក្សាខណ្ឌ ដែលមុខងារទាំងនោះ មិនស្ថិតនៅក្រោមអាណត្តិនៃក្រសួង ស្ថាប័ន មន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាល ឬស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាល ប៉ុន្តែក្រសួងស្ថាប័ន មន្ទីរអង្គភាព ពាក់ព័ន្ធពុំជំទាស់ចំពោះរដ្ឋបាលខណ្ឌក្នុងការជ្រើសរើស និងការអនុវត្តនូវមុខងារទាំងនោះ។

រដ្ឋបាលខណ្ឌ សម្រេចប្រើប្រាស់ធនធានឆន្ទានុសិទ្ធិ របស់ខ្លួនក្នុងការអនុវត្តមុខងារជាជម្រើស។ រដ្ឋបាលខណ្ឌជ្រើសរើសអនុវត្តមុខងារជាជម្រើសរបស់ខ្លួនក្នុងគោលបំណង៖

- ឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- កែលម្អគុណភាព និងពង្រីកវិសាលភាព នៃសេវាសាធារណៈនៅមូលដ្ឋាន
- ការពារបរិស្ថាន និងសម្រេចឱ្យបាននូវការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព
- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។[53]

❖ មុខងារជាកាតព្វកិច្ច

មុខងារជាកាតព្វកិច្ច គឺជាមុខងារទាំងឡាយណាដែលបានប្រគល់ ឬប្រតិភូកម្មឱ្យទៅក្រុមប្រឹក្សាដោយក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងប្រភេទជា "មុខងារជាកាតព្វកិច្ច" ដោយភ្ជាប់មកជាមួយនូវធនធាន(បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ) សម្រាប់អនុវត្តមុខងារទាំងនោះ។

❖ ផែនការអនុវត្តមុខងារ

បែបផែននៃការអនុវត្តមុខងាររបស់រដ្ឋបាលខណ្ឌរួមមាន៖

- ការអនុវត្តផ្ទាល់ដោយការិយាល័យ អង្គភាពនានាចំណុះរដ្ឋបាលខណ្ឌទៅតាមធនធានដែលមាន

[52] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៣៣

[53] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៣៣

- ការអនុវត្តដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ឬក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ជំនាញពាក់ព័ន្ធនានា
- ការចុះកិច្ចសន្យាជាមួយផ្នែកឯកជន ឬអង្គការសង្គមស៊ីវិល
- ការស្នើសុំឱ្យមន្ទីរ អង្គភាពជំនាញ ឬរដ្ឋបាលរាជធានីអនុវត្ត។[54]

❖ ការជ្រើសរើសបែបផែនការអនុវត្តមុខងារ

ក្នុងការអនុវត្តមុខងាររបស់ខ្លួន រដ្ឋបាលខណ្ឌត្រូវសម្រេចជ្រើសរើសយកបែបផែនណាមួយ ឬបែបផែនមួយចំនួនរួមគ្នា ដូចបានបរិយាយខាងលើដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ការជ្រើសរើសនេះត្រូវបានលើកលែង ចំពោះមុខងារទាំងឡាយណាដែលបានផ្ទេរឱ្យទៅរដ្ឋបាលខណ្ឌ ហើយបានកំណត់ច្បាស់លាស់អំពីបែបផែននៃការអនុវត្តមុខងារទាំងនោះ នៅក្នុងលិខិតបទដ្ឋានគតិយុត្ត នៃការផ្ទេរ។[55]

**១.២.២.២. ការគ្រប់គ្រងបុគ្គលិក**

រដ្ឋបាលខណ្ឌត្រូវមានបុគ្គលិកគ្រប់គ្រាន់ទាំងបរិមាណ គុណភាព និងត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិកទាំងនោះ ប្រកបដោយផលិតភាព ប្រសិទ្ធភាព និងប្រសិទ្ធផលស្របតាមគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ពាក់ព័ន្ធនឹងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋបាលខណ្ឌត្រូវមានចំនួនបុគ្គលិកជាស្ត្រីសមស្រប ផ្អែកតាមតម្រូវការរបស់រដ្ឋបាលខណ្ឌនីមួយៗ និងផ្អែកតាមគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ព្រមទាំងលើកទឹកចិត្តដល់ជនពិការ។

❖ និយមន័យ

បុគ្គលិករបស់ក្រុមប្រឹក្សា គឺជាបុគ្គលិករាជការស៊ីវិល និងជាបុគ្គលិកដែលមិនមែនជាមន្ត្រីរាជការស៊ីវិល ក្នុងនោះរួមមាន៖

១) បុគ្គលិកដែលត្រូវបានជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សានៅពេលមានតម្រូវការធនធានមនុស្ស ។

២) បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញនិងផ្ទេរទៅឱ្យក្រុមប្រឹក្សា ក្នុងនោះរួមមាន ៖

- បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញតាមការធ្វើសមាហរណកម្មរចនាសម្ព័ន្ធ និងបុគ្គលិករាជការដែលមានបច្ចុប្បន្នទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលខណ្ឌ
- បុគ្គលិកដែលបានផ្ទេរពីក្រសួងស្ថាប័នទៅឱ្យក្រុមប្រឹក្សាតាមរយៈកិច្ចដំណើរការនៃការផ្ទេរមុខងារ និងធនធាន។

[54] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៣៤

[55] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៣៤

៣) បុគ្គលិកដែលត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិឱ្យទៅបំពេញ ការងារជាមួយក្រុមប្រឹក្សា ស្របតាមលិខិតបទដ្ឋានជាធរមាន។

បុគ្គលិកដែលមិនមែនជាបុគ្គលិករាជការស៊ីវិលរួមមាន មន្ត្រីជាប់កិច្ចសន្យា មន្ត្រីបណ្តែត និងទីប្រឹក្សាបច្ចេកទេសដែលជ្រើសរើស និងចុះកិច្ចសន្យាជាមួយរដ្ឋបាលរាជធានី សម្រាប់ជួយការងារដល់ការិយាល័យអង្គភាពនានានៃរដ្ឋបាលខណ្ឌ។ សមាជិកក្រុមប្រឹក្សាមិនមែនជាបុគ្គលិករបស់ក្រុមប្រឹក្សាឡើយ។

បុគ្គលិកក្រុមប្រឹក្សា មិនរាប់បញ្ចូលមន្ត្រីនៃក្រសួង ស្ថាប័ន មន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាលមន្ត្រីដទៃទៀតដែលអនុវត្តភារកិច្ចពាក់ព័ន្ធសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិ មនុស្ស និងបុគ្គលិករបស់គម្រោងកម្មវិធីនានា ដែលបញ្ជូនឱ្យមកបំពេញការងារនៅរដ្ឋបាលខណ្ឌឡើយ។[56]

❖ ការគ្រប់គ្រងបុគ្គលិក

រដ្ឋបាលខណ្ឌត្រូវគ្រប់គ្រងបុគ្គលិករបស់ខ្លួន ស្របតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បុគ្គលិករបស់រដ្ឋបាលខណ្ឌត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់គណៈអភិបាលក្នុងនាមជាក្រុមប្រឹក្សារបស់ខ្លួន។

បុគ្គលិករបស់រដ្ឋបាលខណ្ឌត្រូវបំពេញកិច្ចការប្រចាំថ្ងៃក្រោមការដឹកនាំផ្ទាល់របស់ប្រធានការិយាល័យអង្គភាពរបស់ខ្លួនដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។[57]

ការគ្រប់គ្រងបុគ្គលិកត្រូវបានកំណត់ចេញជាពីរ គឺការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលតម្រូវឱ្យមានការអនុម័ត និងដែលមិនតម្រូវឱ្យមានការអនុម័តដោយក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតម្រូវឱ្យមានការអនុម័ត ដោយក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមាន៖

- ការរៀបចំផែនការបុគ្គលិក
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាល និងនាយកទីចាត់ការ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលរាជធានី ខេត្តសម្រាប់រដ្ឋបាលរាជធានី ខេត្ត។
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាលនិងប្រធានការិយាល័យ ឬប្រធានអង្គភាពដែលមានម្នាក់ប្រហាក់ប្រហែលនេះរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

[56] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៣៥

[57] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៣៤

- ការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិក។[58]

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមិនតម្រូវឱ្យមានការអនុម័ត ដោយក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមាន៖

- ការជ្រើសរើសបុគ្គលិក
- ការធ្វើកម្មសិក្សា ការតាំងស៊ប់ និងការបញ្ឈប់កម្មសិក្សា
- ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងចាប់ពីនាយករងទីចាត់ការ ឬអនុប្រធានអង្គភាព ដែលមានថ្នាក់ប្រហាក់ប្រហែលរដ្ឋបាលរាជធានី ខេត្តក្រោមសម្រាប់រដ្ឋបាលរាជធានី ខេត្ត។ ដោយឡែកសម្រាប់រដ្ឋបាលរាជក្រៅពីមុខតំណែងខាងលើនេះត្រូវមបញ្ចូលទាំងមុខតំណែង ចាប់ពីនាយករងនៃរដ្ឋបាលខណ្ឌចុះក្រោម
- ការរតែងតាំង និងការបញ្ចប់ តំណែងគ្រប់គ្រងចាប់ពីអនុប្រធានការិយាល័យក្រុង ស្រុក ខណ្ឌ ឬអនុប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលចុះក្រោមសម្រាប់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ
- ការតំឡើងថ្នាក់ និងឋានន្តរស័ក្តិ
- ការផ្លាស់ប្តូរទីកន្លែងធ្វើការងារពីអង្គភាពមួយទៅអង្គភាពមួយ នៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬការដាក់ឱ្យនៅក្រៅតំណែង
- ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- ការដាក់ឱ្យចូលបម្រើការងារឡើងវិញ
- ការដាក់ឱ្យចូលនិវត្តន៍ ការដាក់ឱ្យបាត់បង់សម្បទាវិជ្ជាជីវៈ និងការស្នើសុំលាឈប់ពីការងារ
- ការដាក់ទណ្ឌកម្មខាងវិន័យ
- ការផ្ទេរពីរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៀត និងការផ្ទេររវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នថ្នាក់ជាតិ
- កិច្ចការពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកផ្សេងទៀត។[59]

---

[58] មាត្រា៥ អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពី ការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

[59] មាត្រា៦ អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពី ការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

❖ ការអភិវឌ្ឍសមត្ថភាព

រដ្ឋបាលខណ្ឌ ត្រូវអភិវឌ្ឍន៍សមត្ថភាពបុគ្គលិករបស់ខ្លួនឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទីភារកិច្ច របស់ខ្លួនប្រកបដោយសីលធម៌ មនសិការវិជ្ជាជីវៈ មានតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

រដ្ឋបាលខណ្ឌត្រូវចាត់ចែងឱ្យបុគ្គលិកគ្រប់រូបដែលជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរបស់ខ្លួនបានចូលរួមកម្មវិធីអភិវឌ្ឍន៍សមត្ថភាពជាកាតព្វកិច្ច ដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ និងចាត់ចែងឱ្យមន្ត្រីដែលមានមុនតំណែងនៅក្នុងរដ្ឋបាលរបស់ខ្លួនបានចូលរួមកម្មវិធីអភិវឌ្ឍន៍សមត្ថភាពទៃទៀតយ៉ាងតិចចំនួន ៣០ម៉ោងក្នុង ០១ឆ្នាំ ដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ រដ្ឋបាលខណ្ឌសាមី និងឬអង្គភាព ស្ថាប័នដទៃ។[60]

ការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលខណ្ឌ ត្រូវគេផ្ដោតចម្បងទៅលើតម្រូវការចាំបាច់របស់បុគ្គលិក ផ្អែកតាមធនធានរបស់ខ្លួន និងធនធានពីខាងក្រៅ ដើម្បីឱ្យមានការផ្លាស់ប្ដូរជាវិជ្ជមានទៅលើ សមត្ថភាពបុគ្គលិក ដែលរួមមានចំណេះដឹង ជំនាញ បទពិសោធន៍ អាកប្បកិរិយា និងឥរិយាបថរបស់បុគ្គលិកនៅក្នុងរដ្ឋបាលខណ្ឌ។[61]

**១.២.២.៣. ការខារហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាដល់ ការបង្កើតការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយផ្ដោតលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុត ដូចខាងក្រោមៈ

- តម្រូវការរបស់រដ្ឋបាលខណ្ឌក្នុងការរៀបចំសម្រាប់ទទួលមុខងារភារកិច្ច និងធនធានថ្មីៗ
- សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់
- ការកាត់បន្ថយភាពក្រីក្រ
- តម្រូវការផ្សេងៗរបស់ ស្ត្រី បុរស យុវវ័យ កុមារ ជនពិការ ជនចាស់ជរា ជនក្រីក្រ ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងទៀត។

ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាលដោយអនុវត្តតាមបទដ្ឋានវិធានប្រព័ន្ធ និងនីតិវិធីហិរញ្ញវត្ថុដែលបានកំណត់ជាធរមាន។

[60] ប្រការ៧ ប្រកាសលេខ ៦៦០៦ បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការអភិវឌ្ឍសមត្ថភាព របស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

[61] សៀវភៅណែនាំស្ដីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៣៧

ក្រុមប្រឹក្សាគ្មានសិទ្ធខ្ចីប្រាក់បោះផ្សាយសញ្ញាប័ណ្ណ និង/ឬមូលប័ត្រជានាគ្រប់កិច្ចសន្យា និងប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុណាមួយដែលនាំឱ្យកើតជាបំណុល។

ក្រុមប្រឹក្សា មានសិទ្ធទទួលបានចំណូលពីប្រភព នៅមូលដ្ឋានពីប្រភពនៅថ្នាក់ជាតិ និងពីប្រភពផ្សេងៗទៀត ដោយអនុលោមទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

❖ ចំណូលពីប្រភពនៅមូលដ្ឋាន

ចំណូលពីប្រភពនៅមូលដ្ឋានរបស់រដ្ឋបាលខណ្ឌ រួមមាន៖

➢ ចំណូលសារពើពន្ធនៅមូលដ្ឋានដែលជាចំណូលពន្ធ និងអាករ ដើម្បីជាគុណប្រយោជន៍ទាំង ស្រុងដល់ថវិការបស់រដ្ឋបាលខណ្ឌ

➢ ចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋាន រួមមានចំណូលដែលបានមកពី ៖

- ការជួលទ្រព្យសម្បត្តិ កម្រៃសេវា និងចំណូលផ្សេងៗរបស់រដ្ឋបាលខណ្ឌ
- ការបែងចែកចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានរវាងរដ្ឋបាលខណ្ឌ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗ
- អំណោយដែលបានមកពីប្រភពខាងក្នុង និងខាងក្រៅដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌ
- ចំណូលពីប្រភពផ្សេងៗដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត។

❖ ចំណូលពីថ្នាក់ជាតិ

ចំណូលពីថ្នាក់ជាតិរបស់រដ្ឋបាលខណ្ឌ រួមមាន៖

➢ ថវិកាខណ្ឌដែលជាផ្នែកមួយ នៃកញ្ចប់ថវិការាជធានីភ្នំពេញ

➢ មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ

➢ ចំណូលចែករំលែក

➢ ថ្លៃសេវាដែលបានមកពីការបំពេញមុខងារជាភ្នាក់ងារ។[62]

**១.២.២.៤. ការគ្រប់គ្រងទ្រព្យសម្បត្តិ**

ទ្រព្យសម្បត្តិរបស់រដ្ឋបាលខណ្ឌរួមមានពីរប្រភេទ៖

➢ ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ

➢ ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង រួមទាំងអំណោយផ្សេងៗ

[62] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៣៩

❖ ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ

រដ្ឋបាលខណ្ឌមានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ សម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយត្រូវថែរក្សាការពារឱ្យបានគង់វង្ស និងគ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ។

ក្រុមប្រឹក្សាអាចស្នើសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីកាត់ចេញពីបញ្ជីសារពើភ័ណ្ឌនូវទ្រព្យសម្បត្តិទាំងឡាយណាដែលរដ្ឋបានផ្ទេរឱ្យ ហើយលែងអាចប្រើប្រាស់បាន។ នៅពេលទទួលបាន ការអនុញ្ញាត ការកាត់ចេញនេះត្រូវធ្វើឡើង ជាសាធារណៈប្រកបដោយតម្លាភាព យុត្តិធម៌ និងការប្រកួតប្រជែង។[63]

❖ ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង

ទ្រព្យសម្បត្តិដែលរដ្ឋបាលខណ្ឌ រកបានដោយខ្លួនឯង គឺជាកម្មសិទ្ធិផ្ទាល់របស់រដ្ឋបាលខណ្ឌដែលរដ្ឋបាលខណ្ឌមានសិទ្ធិស្វ័យសម្រេចក្នុង ការគ្រប់គ្រង និងប្រើប្រាស់ ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួននៅក្នុងក្របខ័ណ្ឌដែលត្រូវបានកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិជាធរមាន។

រដ្ឋបាលខណ្ឌមានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង ដោយត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

- ក្រុមប្រឹក្សាខណ្ឌត្រូវបង្កើតគណៈកម្មការមួយដើម្បីដំណើរការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរ ការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិត្រូវធានាឱ្យមានតម្លាភាពនិងបើកទូលាយដល់ការប្រកួតប្រជែងគ្នាជាសាធារណៈ
- ក្នុងការលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិ អភិបាលខណ្ឌត្រូវសម្រេច ដោយផ្អែកតាមអនុសាសន៍របស់គណៈកម្មការក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។[64]

ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលខណ្ឌដែលបានមកពីអំណោយត្រូវគោរពទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងរវាងម្ចាស់អំណោយ និងរដ្ឋបាលខណ្ឌ។ ក្នុងករណីទ្រព្យដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯងជាកម្មសិទ្ធផ្ទាល់ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិ

[63] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៤០

[64] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទព័រទី ៤០

ស្វ័យសម្រេចក្នុងការគ្រប់គ្រង និងប្រើប្រាស់ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ នៅក្នុងក្របខ័ណ្ឌដែលត្រូវកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិដទៃទៀត។[65]

❖ ការរៀបចំបញ្ជីសារពើភណ្ឌ

រដ្ឋបាលខណ្ឌ ដោយមានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ជាសេនាធិការ ត្រូវធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិទាំងអស់ និងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំហើយត្រូវបញ្ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីដើម្បីបញ្ចូលក្នុងបញ្ជីសារពើភណ្ឌរួម នៃទ្រព្យសម្បត្តិរដ្ឋតាមនីតិវិធីជាធរមាន។[66]

[65] មាត្រា៥០ ច្បាប់ស្តីពី ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១១

[66] សៀវភៅណែនាំស្តីពី ការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ទំព័រទី ៤១

# ជំពូកទី២
# អភិបាលកិច្ចល្អក្នុងខណ្ឌចំការមន

# ជំពូកទី២
# អភិបាលកិច្ចល្អក្នុងខណ្ឌចំការមន

## ២.១. អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ ត្រូវបានកំណត់យ៉ាងទូលំទូលាយ នៅក្នុងក្របខណ្ឌផ្សេងៗគ្នាជាច្រើន ក្នុងនោះក៏មាននៅក្នុងក្របខណ្ឌនយោបាយ និងក្របខណ្ឌច្បាប់។ អភិបាលកិច្ចល្អនៅក្នុងក្របខណ្ឌច្បាប់ បានលើកបង្ហាញអំពីការគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានាដែល ប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋាននៅខណ្ឌរបស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

### ២.១.១.និយមន័យ និងគោលបំណងអភិបាលកិច្ចល្អ

❖ និយមន័យ

អភិបាលកិច្ចល្អ ត្រូវបានគេអោយនិយមន័យផ្សេងៗគ្នាជាច្រើនអាស្រ័យនិងស្ថានភាពជាក់ស្តែងដូចខាងក្រោម៖

យោងតាមការពន្យល់ក្នុងវចនានុក្រម **សម្តេចសង្ឃរាជ ជួន ណាត** ពាក្យអភិបាល គឺមានន័យថាជាការគ្រប់គ្រង ការបីបាច់ ការថែរក្សា ហេតុដូចនេះ អភិបាលកិច្ចល្អ គឺមានន័យថា ជាការគ្រប់គ្រងល្អ។[67] បើយើងនិយាយជាន័យរួមវិញ ពាក្យថាអភិបាលកិច្ចល្អ គឺបានសំដៅទៅលើវិធាន ឬបែបផែននៃការគ្រប់គ្រងដែលមានភាពល្អត្រឹមត្រូវ ច្បាស់លាស់ ដែលមានអង្គការចាត់តាំងត្រឹមត្រូវ មានទំនាក់ទនងល្អរវាងថ្នាក់លើ និងថ្នាក់ក្រោម មានប្រសិទ្ធភាពខ្ពស់ដែលស្ថិតក្រោមវិធានមួយពិតប្រាកដ តឹងរឹង ទន់ភ្លន់ និងច្បាស់លាស់។

យោងតាមសៀវភៅរបស់ក្រសួងមហាផ្ទៃដែលបោះពុម្ពផ្សាយលើកទី២ក្នុងខែតុលា ឆ្នាំ២០១០ បានឱ្យនិយមន័យចំពោះអភិបាលកិច្ចល្អមានន័យថា គឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសន្តិសុខដើម្បី បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ។[68]

ស្រដៀងគ្នានេះដែរកម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ (UNDP1997) បានឱ្យនិយមន័យលើពាក្យអភិបាលកិច្ចល្អ មានន័យថាជាការប្រើប្រាស់អំណាចខាងនយោបាយសេដ្ឋកិច្ច និងរដ្ឋបាលដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស។[69]

[67] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

[68] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ៣

[69] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ៣

អភិបាលកិច្ចល្អមានន័យថា "ជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ"។

❖ គោលបំណងអភិបាលកិច្ចល្អនៃខណ្ឌចំការមន

ដើម្បីធ្វើឱ្យ ការមានការគ្រប់គ្រងលើផ្នែក សេដ្ឋកិច្ច សង្គមកិច្ច និងវិបត្តិទាំងឡាយតាមមធ្យោបាយមួយដែលបានផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនបំផុតដល់ប្រជាពលរដ្ឋក្នុងការជំរុញ និងការគាំទ្រដំណើរការនៃការគ្រប់គ្រងរបស់សាលាខណ្ឌចំការមន នឹងការអភិវឌ្ឍមួយប្រកបដោយនិរន្តរភាព។ អភិបាលល្អ គឺជាការដឹកនាំប្រកបដោយប្រសិទ្ធភាព ហើយមានការឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍សង្គមជាតិទាំងមូល។ ក្នុងនោះគោលបំណង សម្រេចបាននូវអភិបាលកិច្ចល្អ គឺត្រូវទាមទារនូវការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តភាពចំពោះពលរដ្ឋ គឺត្រូវមានសេវាថែទាំសុខភាពមាំមួន និងមានអាយុវែងសម្រាប់រស់នៅដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់ចូលរួមយ៉ាងពេញលេញនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គមកិច្ច ហើយត្រូវមានសេវាអប់រំល្អសមស្របដែលគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីឱ្យប្រជាជនមានចំណេះដឹងគ្រប់គ្រាន់ជាមួយជំនាញពេញលេញក្នុងការបង្កើតឱកាសឱ្យបានច្រើន និងត្រូវបង្កើនឱកាសសម្រាប់ប្រជាពលរដ្ឋទូទៅសម្រាប់បំពេញតម្រូវការមូលដ្ឋានលើស្បៀងអាហារ សម្លៀកបំពាក់ ទីជម្រកជាដើមសម្រាប់ប្រជាពលរដ្ឋទាំងអស់នៅក្នុងសង្គមដើម្បីឱ្យមានការរីកចម្រើន។[70]

## ២.១.២. គោលការណ៍អភិបាលកិច្ចល្អ

ក្នុងនោះដែរការអនុវត្តនូវអភិបាលកិច្ចល្អ ជាមួយការគ្រប់គ្រងលើប្រព័ន្ធរដ្ឋបាល គឺត្រូវមានការអនុវត្តលើគោលការណ៍៩ ចំណុចសម្រាប់យកមកផ្តល់ឱ្យប្រជាជនក្នុងការអភិវឌ្ឍសង្គមជាតិអោយមានការរីកចម្រើនគ្រប់វិស័យជាពិសេសសណ្តាប់ធ្នាប់សង្គម និងអំពើពុករលួយដែលរួមមានដូចខាងក្រោមៈ

❖ ការចូលរួម គឺបានស្ថិតនៅក្នុងបរិបទ នៃអភិបាលកិច្ចដែលសម្តៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស និង ស្ត្រីដែលមានអាជ្ញាធរប្រជាពលរដ្ឋអង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងៗទៀតក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការធ្វើសេចក្តីសម្រេចចិត្តនោះដែលមានសារៈសំខាន់នៃការចូលរួម គឺដើម្បីធានាថាព័ត៌មានទាំងឡាយស្តីពីបញ្ហាតម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានប្រមូល និងវិភាគបានគ្រប់ជ្រុងជ្រោយមុននឹងធ្វើការសម្រេចចិត្តអ្វីមួយ។

[70] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ៣

ជាទូទៅ ការចូលរួមនេះត្រូវបានបែងចែកជា២ ធំៗគឺៈ

- ការចូលរួមដោយផ្ទាល់ គឺជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូបដោយខ្លួនឯងផ្ទាល់នៅក្នុងដំណើរការនៃការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តនោះ ។
- ការចូលរួមតាមរយៈតំណាង គឺអ្នកតំណាងប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចនោះតាមឆន្ទៈ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ដែលបានឱ្យខ្លួនជាតំណាងឱ្យនៅក្នុងតំបន់នោះ។[71]

❖ នីតិរដ្ឋ គឺជាការទាមទារឱ្យ មានឯកសារក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ដើម្បីបម្រើ និងការពារផលប្រយោជន៍សាធារណៈការពារសិទ្ធមនុស្សជាពិសេសក្រុមងាយរងគ្រោះ ឬក្រុមភាគតិចហើយច្បាប់ទាំងនោះត្រូវបានអនុវត្តដោយមិនលំអៀងលើសពីនេះទៅទៀតត្រូវមាន ប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ និងពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយដែលផ្តោតលើចំណុចសំខាន់ ៥យ៉ាងគឺៈ

- ឯកសារក្របខ័ណ្ឌច្បាប់ គឺជាលិខិតបទដ្ឋានគតិយុត្តិដែលរួមមានច្បាប់ ព្រះរាជក្រឹត្យ ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំ ដីកា និងលិខិតបទដ្ឋានគតិយុត្តនានា។ ដែលមានឯកសារសំខាន់ៗបីគឺគោលការណ៍តាមការវិវត្តន៍របស់សង្គមជាតិ និងតាមតម្រូវការ នៃការគ្រប់គ្រងរដ្ឋ ហើយចំពោះច្បាប់ផ្ទៃក្នុងគឺជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សម្រាប់ដាក់បទបញ្ជាផ្សេងៗ ពីរាជរដ្ឋាភិបាល ចំណែកឯច្បាប់អន្តរជាតិ គឺជាសន្ធិសញ្ញា អនុសញ្ញា កតិសញ្ញា ពីធីសារ ក្នុងការចុះកិច្ចសន្យាជាមួយប្រទេសផ្សេង និងការចូលរួមទៅលើគោលការណ៍ណាមួយ ដែលអន្តរជាតិយកទៅអនុវត្តទូទាំងពិភពលោក។
- ការពារសិទ្ធមនុស្ស គឺជាសេចក្តីត្រូវការចំបាច់របស់មនុស្សគ្រប់ៗរូប ដែលមានតាំងពីកំណើតដើម្បីទាមទារនូវអ្វីៗ ដែលធ្វើឱ្យមនុស្សរស់នៅប្រកបដោយវិចារណញ្ញាណ និងសេចក្តីថ្លៃថ្នូរ។ ក្នុងសិទ្ធជាមូលដ្ឋានធំបំផុតសម្រាប់គ្រប់រូប គឺជីវិតសេរីភាព និងការស្វះស្វែងរកសុភមង្គលដែលមិនអាចប្តូរបាន ឬដកហូតបានសេរីភាពយុត្តិធម៌ និងសន្តិភាព។
- ប្រព័ន្ធទទួលខុសត្រូវ គឺត្រូវបានបែងចែកដោយឡែកពីគ្នាក្នុងការទទួលខុសត្រូវក្នុងនោះខាងអំណាចនយោបាយត្រូវទទួលខុសត្រូវលើការបង្កើតសភា ឱ្យលេចចេញជារដ្ឋាភិបាល និងត្រូវធ្វើជាប្រមុខរដ្ឋក្នុងការគ្រប់គ្រងប្រទេស ចំណែកខាងនីតិបញ្ញាត្តិជាសភា សម្រាប់ទទួលខុសត្រូវ ក្នុងការតាក់តែងនូវច្បាប់ផ្សេងៗ រីឯខាងអំណាចនីតិបញ្ញត្តិជាសភា សម្រាប់ទទួលខុសត្រូវក្នុងការតាក់តែងនូវច្បាប់ផ្សេងៗ រីឯខាងអំណាចនីតិប្រតិបត្តិជាអ្នកអនុវត្តនូវការគ្រប់គ្រងរដ្ឋបាលទូទាំងប្រទេស ហើយជាអ្នករៀបចំបង្កើតនៅ

[71] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ៧

អាជ្ញាធរដែនដីសម្រាប់រៀបចំឱ្យមានសណ្តាប់ធ្នាប់សង្គ ឱ្យមានសន្តិសុខល្អ និងជាអ្នករៀបចំនូវមន្រ្តីរាជការគ្រប់លំដាប់ថ្នាក់ចាប់ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ។ ចំណែកឯខាងអំណាចតុលាការ គឺជាអ្នកធ្វើឱ្យមានការគោរពច្បាប់ទូទាំងប្រទេស និងមានការដាក់ទោសចំពោះជនណាដែលមិនគោរពច្បាប់។

- ប្រព័ន្ធយុត្តិធម៌ គឺត្រូវធ្វើអោយមានភាពឯករាជ្យ យុត្តិធម៌ និងតម្លាភាព ចំពោះប្រជាពលរដ្ឋគ្រប់រូបជាពិសេសតុលាការដែលមានតួនាទីកាត់ក្តី និងជម្លោះនានាដោយយុត្តិធម៌ និងមិនលំអៀងដែលជំរុញឱ្យមានមានយុត្តិធម៌ហើយជាយន្តការដើម្បីឱ្យមានការគោរពច្បាប់ និងអនុវត្តច្បាប់ជាពិសេសលុបបំបាត់ឱ្យបាននូវអំពោះពុករលួយចំពោះតុលាការ។
- សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់មិនលម្អៀង និងមិនពុករលួយដែលត្រូវអនុវត្តទៅតាមឯកសារច្បាប់ទាំងគឺធ្វើយ៉ាងពេញលេញត្រឹមត្រូវយុត្តិធម៌ និងមិនលម្អៀងដែលសមត្ថកិច្ចទទួលខុសត្រូវ គឺត្រូវអនុវត្តតាមច្បាប់ដោយមិនលម្អៀង និងមិនពុករលួយដែលជាការចូលរួមយ៉ាងខ្លាំងក្នុងអភិបាលកិច្ចល្អក្នុងសង្គម។[72]

❖ តម្លាភាព គឺរាល់ការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចនោះត្រូវធ្វើឡើងដោយមានការអនុលោមទៅតាមច្បាប់ និងបទដ្ឋាននានាហើយព័ត៌មានពាក់ព័ន្ធ និងការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តត្រូវផ្សព្វផ្សាយជាចំហតាមរយៈប្រព័ន្ធសមស្រប និងអាចអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះ និងព័ត៌មានទាំងនោះ និងព័ត៌មានទាំងនោះត្រូវមានលក្ខណៈគ្រប់គ្រាន់ និងងាយយល់ចំពោះប្រជាពលរដ្ឋ។[73]

❖ ការព្រមព្រៀងឯកភាពគ្នា គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការសម្រេចចិត្តដោយមានការព្រមព្រៀងឯកភាពគ្នាលើជម្រើស និងវិធីសាស្រ្តល្អណាមួយដែលបម្រើផលប្រយោជន៍ទូទៅ។[74]

❖ សមធម៌ គឺជាក្រុម ឬជនគ្រប់រូបទាំងអស់ជាពិសេសក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះមានឱកាសគ្រប់គ្រាន់នៅក្នុងការចូលរួមបញ្ចេញយោបល់លើកឡើងនូវតម្រូវការពិតប្រាកដ ដើម្បីអនុវត្តសកម្មភាព និងផលប្រយោជន៍សមស្របដើម្បីកែលម្អ និងថែរក្សាសុខុមាលភាពរបស់ពួកគេ។ ជាមួយគ្នានេះដែរចំពោះសុខភាពរបស់ពលរដ្ឋទាំងអស់នៅក្នុងសង្គមគឺត្រូវតែមានការការពារ និងថែរក្សាពីរាជរដ្ឋាភិបាលដែលជាដំណើរការនៃការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្ត ប្រកបដោយសមធម៌ និងធ្វើឱ្យគ្រប់ពលរដ្ឋទាំងអស់នៅក្នុងសង្គមមានអារម្មណ៍ថាពួកគាត់ម្នាក់ៗ គឺជាសមាជិកពិតប្រាកដរបស់សង្គម និងបានចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍសង្គមនោះ។ សុខុមាលភាពដែលពលរដ្ឋចង់បាន

[72] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ១០

[73] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ១៣

[74] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ១៣

គឺភាពសប្បាយភាពសុខភាពសុខស្រួលសុវត្ថិភាពសន្តិសុខល្អ និងភាពគ្រប់គ្រាន់ចំពោះការគិតទៅដល់ ជំនឿ សាសនា ស្មារតី ផ្លូវអារម្មណ៍ព្រមទាំងជីវភាពរស់នៅរបស់ពលរដ្ឋម្នាក់ៗសម្រាប់រស់នៅប្រចាំថ្ងៃផងដែរ។[75]

- ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ គឺជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព និងសន្សំសំចៃខ្ពស់ដើម្បីទទួលបានលទ្ធផល ដែលមានគុណភាពបរិមាណច្រើនអាចបម្រើផលប្រយោជន៍ជាអតិបរិមា និងឆ្លើយតបទៅតម្រូវការពិតរបស់សង្គម។ ម៉្យាងទៀតត្រូវបានរួមបញ្ចូលចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការការពារបរិស្ថាន ហើយដើម្បីឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធក្នុងការអនុវត្តនោះ គឺត្រូវមានការពិចារណាលើចំណុចផ្សេងៗមួយចំនួន គឺការប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវ ការអនុវត្តសកម្មភាពដែល ជាអាទិភាពខ្ពស់ជៀសវាងអនុវត្តនូវ ការិយាធិបតេយ្យការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិគ្មានអំពើពុករលួយ និងមានការសម្រេចចិត្តតាមចូលរួមជាដើម។[76]
- គណនេយ្យភាព គឺជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការនិងក្នុងការអនុវត្តសេចក្តីសម្រេចចិត្តទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុអ្វី ដែលខ្លួនបានសម្រេច និងអនុវត្ត។ គណនេយ្យភាព គឺមិនត្រឹមតែជាការទទួលខុសត្រូវចំពោះមុខអ្នកណាម្នាក់ដែលបានស្នើសុំឱ្យធ្វើអ្វីមួយនោះទេ ប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាព ដែលបានអនុវត្តចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់ ហើយគណនេយ្យភាពរួមមានគណនេយ្យចំពោះថ្នាក់ដឹកនាំ និងគណនេយ្យភាពចំពោះមុខសាធារណៈជន។[77]
- ការឆ្លើយតប គឺជាការខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័នដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងអ្នកដែលពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នា និងមិនរើសអើងនៅក្នុងក្របខ័ណ្ឌពេលវេលាដ៏សមហេតុផល។ ជាមួយគ្នានេះដែលការឆ្លើយតបត្រូវតែមានការបំពេញសេវាកម្មជូនប្រជាពលរដ្ឋ តាមការស្នើសុំត្រូវមានដំណោះស្រាយដែលស្តែងឡើងជាសកម្មដើម្បីដោះស្រាយបញ្ហា ឬការលំបាកនានាឆ្លើយបំភ្លឺអំពីមូលហេតុដែលមិនអាចឈានដល់ ការធ្វើសកម្មភាពដោះស្រាយបញ្ហា ឬការលំបាកទាំងនោះបាន និងសំណើសុំអន្តរាគមន៍ពីស្ថាប័នអង្គភាពមាន សមត្ថកិច្ចដើម្បីជួយដោះស្រាយបញ្ហា ឬការលំបាកទាំង

[75] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ១៥
[76] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ១៦
[77] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ១៧

នោះព្រមទាំង ជំម្រាបអំពីសំណើសុំអន្តរាគមន៍នេះ ដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងបញ្ហា ឬការលំបាកនោះ។[78]

- ចក្ខុវិស័យជាយុទ្ធសាស្ត្រ គឺសម្រាប់អ្នកដឹកនាំទាំងអស់ និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនៈទូលំទូលាយ និងសម្រាប់រយៈពេលវែងអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍ធនធានមនុស្សដោយយកចិត្តទុកដាក់អំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍លើការងារនេះ។ ជាងនេះទៅទៀតមេដឹកនាំ ទាំងអស់ត្រូវមានការយល់អោយច្បាស់អំពីទិដ្ឋភាពនានាលើចំណុចមួយចំនួនលើផ្នែក ប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គមដែលមានការពាក់ព័ន្ធទៅ នឹងអភិបាលកិច្ចល្អ។[79]

### ២.១.៣. តួអង្គសំខាន់ៗ ក្នុងអភិបាលកិច្ចល្អ

កាលពីមុនគេយល់ឃើញថា មានតែរដ្ឋាភិបាលមួយគត់ ដែលជាតួអង្គនៃអភិបាលកិច្ចល្អ។ ប៉ុន្តែបច្ចុប្បន្ននេះ មានគំនិតថ្មីៗជាច្រើនបានបង្ហាញឱ្យឃើញថាផ្នែកឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀតក៏បានដើរ តួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសផងដែរ។ ដូចនេះតួអង្គសំខាន់ក្នុងអភិបាលកិច្ចល្អ មានបីគឺ :

- ស្ថាប័នរដ្ឋ (ស្ថាប័ននយោបាយ និងរដ្ឋាភិបាល ជាតួអង្គសំខាន់ជាងគេ)
- ផ្នែកឯកជន
- សង្គមស៊ីវិល

ឥទ្ធិពល នៃតួអង្គផ្នែកឯកជន និងសង្គមស៊ីវិល មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយអាស្រ័យលើគោលការណ៍មួយចំនួនដូចជា ប្រព័ន្ធនយោបាយ លក្ខណៈអំណោយផលខាងធនធានធម្មជាតិ ប្រជាពលរដ្ឋ ទីតាំង ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងកម្រិត នៃការអភិវឌ្ឍសេដ្ឋកិច្ច ។ល។[80]

### ២.១.៤. អភិបាលកិច្ចល្អ នៃរដ្ឋបាលខណ្ឌចំការមន

នៅក្នុងខណ្ឌចំការមន មានការអនុវត្តគ្រប់គ្រងរដ្ឋបាលតាមគោលការណ៍ នៃរដ្ឋបាលដែលឯកភាពដើម្បីបង្កើតការជំម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការដោយផ្អែកតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ដោយនៅក្នុងខណ្ឌចំការមន មានការបែងចែកនូវភារកិច្ចបានយ៉ាងត្រឹមត្រូវទៅតាមផ្លូវច្បាប់ និងមុខងារដោយមិនមានការរំលោភបំពានចំពោះគ្នា និងមានការគោរពសិទ្ធិទៅតាមតួនាទី នៃសមាជិកក្នុងនោះក្រុមប្រឹក្សាខណ្ឌ

[78] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ១៧

[79] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ១៨

[80] សៀវភៅស្តីពី អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០ ទំព័រទី ៤

មានសិទ្ធិទៅលើគណៈអភិបាលខណ្ឌ រាល់ពេលមានភាពមិនសមហេតុផលក្នុងការសម្រេចចិត្តបានល្អ។ ក្នុងនោះគណៈអភិបាលខណ្ឌ បានអនុវត្តសកម្មភាព នៃការបម្រើសេវាសាធារណៈ ជូនពលរដ្ឋបានល្អប្រសើរព្រមទាំងមានកម្មវិធីបណ្តុះបណ្តាលនៅតាមសង្កាត់នីមួយៗ ដើម្បីពួកគាត់ទទួលបាននូវសកម្មភាព នៃការបម្រើសេវាសាធារណៈប្រកបដោយតម្លាភាព។ ជាមួយគ្នានេះដែលការអភិវឌ្ឍរបស់ខណ្ឌ គឺតាមបែបប្រជាធិបតេយ្យ ចំពោះពលរដ្ឋដែលមានលក្ខណៈ ភាពជាតំណាងសាធារណៈស្វ័យភាពរបស់មូលដ្ឋានការពិគ្រោះយោបល់ និងការចូលរួមឆ្លើយតប និងគណនេយ្យភាព ការលើកកំម្ពស់គុណភាពជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ការលើកស្ទួយដល់ មូលដ្ឋានតម្លាភាព និងសុចរិតភាព និងវិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាចជាដើម សម្រាប់លើលស្ទួយដល់ខណ្ឌចំការមន មានការជឿនលឿនកាន់តែប្រសើរឡើង ជាពិសេសអាចជាប់ជាខណ្ឌគំរូផងដែលនាពេលអនាគត។ ជាពិសេសការរៀបចំសណ្តាប់ធ្នាប់សាធារណៈទៅលើសន្តិសុខ បង្រ្កាបក្មេងទំនើង ចោរកម្មការជួញដូរស្ត្រី និងកុមារ ការចែកចាយគ្រឿងញៀនអំពើពុករលួយ និងគ្រោះថ្នាក់ចរាចរណ៍ គឺត្រូវបានលុបបំបាត់ស្ទើរតែ ១០០% ហើយនៅក្នុងខណ្ឌសព្វថ្ងៃមាន ការខិតខំអនុវត្តបន្តនូវការអភិវឌ្ឍតាមលក្ខណៈ អភិបាលកិច្ចល្អឱ្យកាន់តែប្រសើរឡើងជារៀងរាល់ឆ្នាំដោយមានគោរពតាមគោលការណ៍ របស់រាជរដ្ឋាភិបាលកម្ពុជា ។

## ២.២. សមិទ្ធផលការងារដែលសម្រេចបានរបស់រដ្ឋបាលខណ្ឌ

នៅក្នុងឆ្នាំ២០២០ កន្លងមកនេះ រដ្ឋបាលខណ្ឌចំការមន បានបន្តខិតខំជម្នះ ពុះពាររាល់ ការលំបាកស្មុគស្មាញ និងអនុវត្តគ្រប់វិធានការពិសេសការរៀបចំទីកន្លែងបម្រើការងាររបស់មន្ត្រីតាម ការិយាល័យបានសមរម្យ ការងារចាត់តាំងគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព និងការទប់ស្កាត់ប្រយុទ្ធប្រឆាំងការរីករាលជំងឺកូវីដ១៩ ការពារសន្តិសុខនៅក្នុងខណ្ឌបានល្អ ទោះបីជាមានសកម្មភាពតវ៉ាផ្សេងៗរបស់ប្រជាពលរដ្ឋ និងសកម្មជនគណបក្សនយោបាយមួយចំនួន ដែលព្យាយាមបង្កចលាចលនយោបាយ និងមិនមានអំពើភេរវកម្ម ទប់ស្កាត់មិនឱ្យកើតមានអំពើប្លន់ ប្រដាប់អាវុធ អំពើអនាចារ កាត់បន្ថយអំពើអបាយមុខបង្កដោយក្រុមក្មេងទំនើង ល្បែងស៊ីសង និងផ្តល់នូវភាពកក់ក្តៅដល់ប្រជាពលរដ្ឋ វិនិយោគិន និងភ្ញៀវបរទេស។ ម្យ៉ាងទៀតបានបន្តខិតខំផ្សព្វផ្សាយអប់រំ និងរឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីឱ្យអ្នកបើកបរយានយន្តគ្រប់ប្រភេទគោរព និងអនុវត្តច្បាប់ចរាចរផ្លូវគោកឱ្យបានត្រឹមត្រូវព្រមទាំងខិតខំ កសាង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅតាមតំបន់ ដែលមានការកកស្ទះចរាចរណ៍ច្រើនជូនប្រជាពលរដ្ឋ និងរួមចំណែកធ្វើឱ្យករណីគ្រោះថ្នាក់ និងករណីកកស្ទះចរាចរណ៍ត្រូវបានកាត់បន្ថយ។ ដែលសមិទ្ធផល ទាំងនោះមានដូចជា សមិទ្ធផលនៃការគ្រប់គ្រងរដ្ឋបាល និងសមិទ្ធផលរបស់ការិយាល័យ។

### ២.២.១. សមិទ្ធផល នៃការគ្រប់គ្រងរដ្ឋបាល

សមិទ្ធផលការងារប្រចាំឆ្នាំ២០២០ របស់រដ្ឋបាលខណ្ឌចំការមន បានអនុវត្តដើម្បីឆ្លើយតបនូវផែនការអភិវឌ្ឍ។

#### ២.២.១.១. ការងាររដ្ឋបាល

❖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ មានៈ

- សេចក្តីសម្រេចដែលបានដាក់ចេញ មានចំនួន ២០
- លិខិតរដ្ឋបាលដែលបានដាក់ចេញចំនួន ៤៧៥ លិខិត
- លិខិតដែលទទួលបានចំនួន ២,០៤៧ លខិត
- សៀវភៅស្នាក់នៅដែលបានដាក់ចេញ ចំនួន ៣១៤សៀវភៅ ។

❖ ការគ្រប់គ្រងប្រជាពលរដ្ឋ

យោងតាមស្ថិតិជាតិ ប្រជាពលរដ្ឋមានចំនួន ៩,៤៤២គ្រួសារ ដោយក្នុងនោះ មនុស្សចំនួន ៤៧.០៥៣នាក់ មានស្រីចំនួន ២២,៦១២នាក់ ហើយប្រជាពលរដ្ឋខ្មែរ អាយុ ១៨ឆ្នាំឡើង មានចំនួន ៣០,៣៦៩នាក់។

តារាងស្ថិតិប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានខណ្ឌចំការមន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សរុបគ្រួសារ | ៩,៤៤២ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៧.៣៣៨ |
| ៣ | គ្រួសារបណ្តោះអាសន្ន | ១.៩៦៥ |
| ៤ | ប្រជាពលរដ្ឋសរុប | ៤៧,០៥៣ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ២២,៦១២ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៣០,៣៦៩ |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | ០០ |

❖ ការងារអត្រានុកូលដ្ឋាន

ការចម្លងសំបុត្រអត្រានុកូលដ្ឋានឆ្លងឆ្នាំអនុវត្តបានៈ

- សេចក្តីចម្លងសំបុត្រកំណើតបានចំនួន ៤០០ នាក់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតបានចំនួន ៣,០៧៤ នាក់
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍បានចំនួន ៥៤៥ នាក់

- សេចក្ដីចម្លងសំបុត្រមរណៈភាពបានចំនួន ៦០ នាក់។

❖ ការងារគណៈអភិបាល

ប្រជុំអឌ្ឍមាសរបស់គណៈអភិបាល ចំនួន ១២ លើក ការប្រជុំប្រចាំខែរបស់គណៈអភិបាល មានចំនួន ១២លើក ។

ក្រៅពីការងារប្រជុំអឌ្ឍមាស និងកិច្ចប្រជុំប្រចាំខែ គណៈអភិបាលបានបំពេញការងារផ្សេងទៀត ទៅតាមការបែងចែកភារកិច្ច និងទៅតាមការប្រគល់ភារកិច្ចបន្ថែម ជាតំណាងឱ្យលោកអភិបាលខណ្ឌ ដើម្បីចុះទៅបំពេញការងារនានា ។[81]

❖ ការងារក្រុមប្រឹក្សា និងគណៈកម្មការនានា

- កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ចំនួន ១២ លើក
- កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា គ្មាន
- កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សាខណ្ឌ គ្មាន
- កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ចំនួន ០២ លើក
- កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចស្ត្រីកុមារ ចំនួន ១១ លើក។

**២.២.១.២. ការងារផែនការ និងការគាំទ្រឃុំសង្កាត់**

❖ ការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគខណ្ឌ

- បានរៀបចំសៀវភៅផែនការអភិវឌ្ឍប្រចាំឆ្នាំរបស់ខណ្ឌ (២០២០-២០២៤)
- រៀបចំសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ(២០២១-២០២៣) និងសៀវភៅទិន្នន័យខណ្ឌឆ្នាំ២០២០
- ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ បានដាក់ពង្រាវនូវ សៀវភៅកម្មវិធីវិនិយោគ បីឆ្នាំរំកិលខណ្ឌ (២០២១-២០២៣) ជូនក្រុមប្រឹក្សាដើម្បីធ្វើការពិនិត្យ និងអនុម័ត នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី១៨ របស់ក្រុមប្រឹក្សាខណ្ឌចំការមន ក្រោមអធិបតីភាពលោក **ព្រុំ សំខាន់** ប្រធានក្រុមប្រឹក្សាខណ្ឌចំការមន ។

❖ ការអនុវត្តគម្រោងវិនិយោគ

គម្រោងវិនិយោគខណ្ឌ ត្រូវបានអនុវត្តឆ្នាំ២០២០ គម្រោងខាងក្រោមនេះ គឺជាគម្រោងដែលគាំទ្រដោយថវិការដ្ឋបាលខណ្ឌ ចំពោះគម្រោងគាំទ្រដោយមន្ទីរជំនាញ អង្គការ មិនបានរាប់បញ្ចូលនោះទេ ។ គម្រោងសរុបមានចំនួន ១៩គម្រោង ក្នុងនោះមាន

- ផ្នែកសេដ្ឋកិច្ច មាន ០១គម្រោង

[81] ឧបសម្ព័ន្ធទី៣ របាយការណ៍ប្រចាំឆ្នាំ ស្ដីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០

- ផ្នែកសង្គមកិច្ច មាន០៤គម្រោង
- ផ្នែកប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ
  បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ មាន ០៥ គម្រោង
- ផ្នែករដ្ឋបាលសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ មាន ០៩ គម្រោង ។

**២.២.១.៣. ការគ្រប់គ្រងបុគ្គលិកបច្ចុប្បន្ន**

❖ ការគ្រប់គ្រងបុគ្គលិក

រចនាសម្ព័ន្ធខណ្ឌរួមមាន ៖

| ល.រ | បរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា | ១៩ | ០៤ |
| ២ | ប្រធានក្រុមប្រឹក្សា | ០១ | ០០ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលផ្លាស់ប្តូរ | ០១ | ០០ |
| ៤ | អភិបាល | ០១ | ០០ |
| ៥ | អភិបាលរង | ០៤ | ០១ |
| ៦ | នាយករដ្ឋបាល | ០១ | ០០ |
| ៧ | នាយករងរដ្ឋបាល | ០២ | ០០ |
| ៨ | ប្រធានការិយាល័យ និងអង្គភាព | ០៧ | ០១ |
| ៩ | អនុប្រធានការិយាល័យ និងអង្គភាព | ១៨ | ០២ |
| ១០ | មន្ត្រីការិយាល័យ (រាប់ទាំងស្មៀនសង្កាត់) | ៤២ | ១៧ |
| ១១ | មន្ត្រីជាប់កិច្ចសន្យា | ១៤០ | ២៩ |

❖ ការអភិវឌ្ឍសមត្ថភាព

ឆ្នាំ២០២០ ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលខណ្ឌបានចូលរួមចំនួន ១៤វគ្គសរុប ១៤៨ នាក់ ស្រី ៤០នាក់ ។ ការអភិវឌ្ឍន៍សមត្ថភាព ៖

| ល.រ | ឈ្មោះវគ្គការសិក្សា | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ១៤ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ១៤៨ |

| | | |
|---|---|---|
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៥០ |

**២.២.១.៤. ការងារអន្តរវិស័យ**

ការងារអន្តរវិស័យ ត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាព និងលទ្ធផលរបស់ការិយាល័យរួចហើយ ។

❖ ការសម្របសម្រួលតាមវិស័យ

ការសម្របសម្រួលតាមការិយាល័យត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាព និងលទ្ធផលរបស់ការិយាល័យរួចហើយ ។

❖ ការដោះស្រាយ និងសម្រុះសម្រួលទំនាស់

- បានទទួលលិខិតចូល ចំនួន ៨៤ច្បាប់
- បានចេញលិខិត ចំនួន ៧០ច្បាប់

ការសម្រុះសម្រួលទំនាស់បាន ៖

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | បណ្តឹងចូលថ្មី | ៣៥ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ០៩ |
| ៣ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលខណ្ឌ | ២០ |
| ៤ | បណ្តឹងកំពុងដោះស្រាយបន្ត | ០៥ |

❖ កិច្ចការការិយាល័យច្រកចេញចូលតែមួយ

ការិយាល័យច្រកចេញចូលតែមួយ សាលាខណ្ឌចំការមន បានផ្តល់សេវាជូនប្រជាពលរដ្ឋ បាន ចំនួន ២១, ៥១១សេវា, ប្រជាពលរដ្ឋមកទទួលសេវាបាន ចំនួន ២០,៣២៣ នាក់,ស្រី ចំនួន ៥,៦៥២ នាក់ ។

កិច្ចការងារការិយាល័យច្រកចេញចូលតែមួយ ៖

| ល.រ | កាលបរិយាយ | ចំនួន |
|---|---|---|
| ១ | សេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់ | ២១,៥១១ នាក់ |
| ២ | ប្រជាពលរដ្ឋសរុបដែលបានមកទទួលសេវា | ២០,៣២៣ នាក់ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានមកទទួលសេវា | ៥,៦៥២ នាក់ |
| ៤ | ចំណូលដែលទទួលបានពីការផ្តល់សេវា | ២០,៣២៣ នាក់ |
| ៥ | ករណីបណ្តឹងដែលទទួលបានសរុប | ០០ |
| ៦ | ករណីបណ្តឹងដែលបានដោះស្រាយរួចជាស្ថាពរ | ០០ |

❖ កិច្ចការសេវាសង្គម និងការបង្កើតសិទ្ធិស្ត្រី

ការងារអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក

| ល.រ. | សូចនាករ | ផែនការប្រចាំឆ្នាំ | លទ្ធផលសម្រេចបាន | |
|---|---|---|---|---|
| | | | ជាក់ស្តែង | % |
| ១ | ចំនួនកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក | ១២ | ១១ | ៩២% |
| ២ | ចំនួនថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើផ្នែក សេវាសង្គម (រៀល) | - | - | - |
| ៣ | ខណ្ឌបានចងក្រងទិន្នន័យអត្រានុកូលដ្ឋានដែលទទួលបានពីសង្កាត់ | ១,៩៣០ | ២,១៥៦ | ១១១% |
| ៤ | ចំនួនបេសកម្មដែល គ.ក.ស.ក ខណ្ឌបានចុះការគាំទ្រ និងផ្តល់សេវាសង្គម | ០០ | ០០ | ០០ |
| ៥ | ចំនួនសង្កាត់ដែល គ ក.ស.ក.ខណ្ឌ បានចុះគាំទ្រ | ០៥ | ០៥ | ១០០% |
| ៦ | ចំនួនវគ្គបណ្តុះបណ្តាលដែល គ.ក.ស.ក ខណ្ឌបានទទួល | ០០ | ០១ | ១០០% |

### ២.២.១.៥. ការងារហិរញ្ញវត្ថុ

ការអនុវត្តចំណូលចំណាយរបស់រដ្ឋបាលខណ្ឌ

- យោងសារាចរណែនាំលេខ ០០១ សហវ.អថ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរឹតបន្តឹង និងពង្រឹងប្រសិទ្ធភាព ចំណាយសម្រាប់ ការអនុវត្តច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី-ខេត្ត ។
- លិខិតលេខ ២៤៩ លស.ហ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ របស់សាលារាជធានីភ្នំពេញ ស្តីពីការរឹតបណ្តឹង ថវិការដ្ឋបាលខណ្ឌទាំង១៤ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២០ឡើងវិញ។
- ការអនុវត្តចំណូល ប្រភពចំណូលមានពីរប្រភេទ គឺចំណូលដែលទទួលបានពីការឧបត្ថម្ភធន របស់សាលារាជធានីភ្នំពេញ និងមួយប្រភេទទៀតបានមកពីការផ្តល់សេវាសាធារណៈ តាមរយៈការិយាល័យច្រកចេញចូលតែមួយ ។ ប៉ុន្តែដោយផ្អែកលើសភាពការណ៍វិបត្តិថ្មី នៃសេដ្ឋកិច្ចសកល ពិសេសការផ្ទុះរីករាលដាលនូវជំងឺរលាកផ្លូវដង្ហើមដ៏ធ្ងន់ធ្ងរ (COVID-19) ដែលបណ្តាលឱ្យមានផលប៉ះពាល់ដល់ក្របខណ្ឌច្បាប់ថវិកាប្រចាំឆ្នាំ ។

- អនុវត្តចំណាយគឺចំណាយលើការទិញ សេវាខាងក្រៅ និងសេវាខាងក្រៅផ្សេងៗបន្ទុកបុគ្គលិកនិងផ្សេងៗ។[82]

ការគ្រប់គ្រងទ្រព្យសម្បត្តិ របស់រដ្ឋបាលខណ្ឌ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិ ដែលបានទិញ ឬទទួល (ថ្មី) | ០០ ប្រភេទ |
| ២ | ទ្រព្យសម្បត្តិដែលបានកាត់ចេញ | ០០ ប្រភេទ |
| ៣ | ទ្រព្យសម្បត្តិសរុប | ០០ ប្រភេទ |

#### ២.២.១.៦. ការងារលទ្ធកម្ម

បានផ្សព្វផ្សាយឯកសារដេញថ្លៃ-ពិគ្រោះថ្លៃ និងស្ទង់តម្លៃសម្ភារៈ (លូ-ផ្លូវ) សំណង់ បានចំនួន ០៩លើក លើទំព័រកាសែត ។

បានរៀបចំបញ្ជីប៉ាន់ស្មានតម្លៃ និងស្នើសុំគោលការណ៍ធានាចំណាយ សម្រាប់ការដេញថ្លៃ និងស្ទង់តម្លៃថវិកា និយ័តចុងឆ្នាំ និងការបន្ថែមឥណទានសម្រាប់ការប្រើប្រាស់របស់ការិយាល័យដែលបានសមារណ៍កម្មមក រដ្ឋបាលខណ្ឌចំការមន ទៅមន្ទីរសេដ្ឋកិច្ច រួចរាល់ ។

បានប្រជុំបើកសំណើរ ស្ទង់តម្លៃ-ពិគ្រោះដេញថ្លៃ សម្ភារៈនិងសំណង់ បានចំនួន ០៧លើក ។[83] ការងារតាមដាន និងការអនុវត្តគម្រោងអភិវឌ្ឍន៍មូលនិធិខណ្ឌឆ្នាំ២០២០ ។

### ២.២.២. សមិទ្ធផលរបស់ការិយាល័យ

ការិយាល័យចំណុះរបស់រដ្ឋបាលខណ្ឌបានខិតខំបំពេញតួនាទីតាមជំនាញរបស់ខ្លួន ដែលស្របតាមច្បាប់ និងការអនុវត្តការងារដើម្បីបម្រើប្រយោជន៍សាធារណៈ ។

#### ២.២.២.១. វិស័យសេដ្ឋកិច្ច

- ❖ ការងារផែនការ បានអនុវត្តការងារ
- ចុះសិក្សាគម្រោងមូលនិធិសង្កាត់ឆ្នាំ ២០២០
- សម្របសម្រួលការដេញថ្លៃគម្រោងមូលនិធិសង្កាត់ឆ្នាំ២០២០
- រៀបចំផែនការកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) របស់រដ្ឋបាលខណ្ឌចំការមន
- សម្របសម្រួលសិក្ខាសាលាសមាហរណកម្មវិនិយោគ សង្កាត់ ខណ្ឌ ឆ្នាំ (២០២១-២០២៣)
- រៀបចំសៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលខណ្ឌ (២០២១-២០២៣)

[82] របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី១២

[83] របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី១៣

- រៀបចំសៀវភៅផែនការអភិវឌ្ឍន៍ ៥ឆ្នាំ (២០២១-២០២៣) របស់រដ្ឋបាលខណ្ឌចំការមន
- សម្របសម្រួលសង្កាត់រៀបចំសៀវភៅកម្មវិធីវិនិយោគសម្រាប់ឆ្នាំ២០២១
- ចូលរួមវគ្គបណ្តុះបណ្តាលការស្រង់ព័ត៌មានទិន្នន័យភូមិ សង្កាត់ ខណ្ឌ ឆ្នាំ២០២០ ។

❖ ការងារសាធារណការ និងដឹកជញ្ជូន

- បានចុះពីនិត្យមើលការជួសជុលផ្លូវក្នុងមូលដ្ឋាន ចំនួន៣០លើក
- បានចុះពិនិត្យមើលរថយន្តដឹកដីដែលធ្វើឱ្យប៉ះពាល់បរិស្ថានតាមដងផ្លូវ និងហាមឃាត់រថយន្តមកធ្វើការណែនាំបានចំនួន ១០លើក
- ចុះរៀបចំសណ្តាប់ធ្នាប់តាមមហាវិថី និងតាមផ្លូវក្នុងមូលដ្ឋានជាប្រចាំ
- ចុះពិនិត្យ និងសហការណ៍ជាមួយក្រុមហ៊ុន ស៊ិន ទ្រី ប្រមូលសំរាមកុំឱ្យមានការកកស្ទះសំរាម ជាប្រចាំ
- ចុះពិនិត្យប្រឡាយ លូបង្ហូរទឹក ការជីកដីដាក់លូថ្មី និងការកាត់ខ្សែកាបអុបទិចតាមដងផ្លូវបានចំនួន២០លើក
- ចុះកាប់មែកឈើបានចំនួន ២០លើក
- ចុះពិនិត្យគុណភាពបរិស្ថាន និងណែនាំតាមភោជនីយដ្ឋាន និងសិប្បកម្ម ចំនួន ១០លើក ៨០ទីតាំង
- ចុះពិនិត្យលិខិតអនុញ្ញាត និងណែនាំម្ចាស់អាជីវកម្មយានដ្ឋានជួសជុលរថយន្ត សរុប៥២ទីតាំង

❖ ការងារទេសចរណ៍

មន្ត្រីទទួលបន្ទុកទេសចរណ៍ នៃការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ខណ្ឌ បានចុះត្រួតពិនិត្យទីតាំងមុនចេញអាជ្ញាប័ណ្ណបានចំនួន ៦៣ទីតាំងក្នុងនោះមាន

- ភោជនីយដ្ឋាន ចំនួន ៣៩ ទីតាំង
- ម៉ាស្សា ចំនួន ០៥ ទីតាំង
- ខារ៉ាអូខេ ចំនួន ១៧ ទីតាំង
- បន្ទប់ស្នាក់នៅ ចំនួន ០៣ ទីតាំង
- ផ្ទះសំណាក់ ចំនួន ១៦ ទីតាំង
- សណ្ឋាគារ ចំនួន ០៥ ទីតាំង
- អាផាតមិន ចំនួន ០២ ទីតាំង

អាជ្ញាប័ណ្ណទេសចរណ៍ ដែលបានផ្តល់នៅរាជធានីភ្នំពេញបានចំនួន ១០៩អាជ្ញាប័ណ្ណ ក្នុងនោះមាន ៖

- ភោជនីយដ្ឋាន ចំនួន ៦០ ទីតាំង
- សណ្ឋាគារ ចំនួន ១១ ទីតាំង

- ម៉ាស្សា ចំនួន ០២ ទីតាំង
- អាជាតមិន ចំនួន ០២ ទីតាំង
- ផ្ទះសំណាក់ ចំនួន ៣០ ទីតាំង
- ខារ៉ាអូខេ ចំនួន ០៣ ទីតាំង
- អាហារដ្ឋាន ចំនួន ០១ ទីតាំង

អាជ្ញាប័ណ្ណទេសចរណ៍ថ្មី និងបន្តដែលផ្តល់នៅការិយាល័យច្រកចេញចូលតែមួយខណ្ឌចំនួន ៥៩ទីតាំង ក្នុងនោះមាន៖

- ម៉ាស្សា ចំនួន ០៦ ទីតាំង
- ភោជនីយដ្ឋាន ចំនួន ៣២ ទីតាំង
- ផ្ទះសំណាក់ ចំនួន ០២ ទីតាំង
- ហាងកាហ្វេ ចំនួន ១១ ទីតាំង
- បន្ទប់ស្នាក់នៅ ចំនួន ០៣ ទីតាំង
- ខារ៉ាអូខេ ចំនួន ០១ ទីតាំង
- អាហារដ្ឋាន ចំនួន ០៣ ទីតាំង
- ភេសជ្ជៈ ចំនួន ០១ ទីតាំង

ការកត់ត្រាអត្តសញ្ញាណភ្ញៀវស្នាក់នៅ ៖

- សណ្ឋាគារ ចំនួន ០៩
- អាជាតមិន ចំនួន ០៩
- មានភ្ញៀវស្នាក់នៅសរុបចំនួន ២,៤០៨នាក់ ស្រី ២,២៩៣ នាក់

❖ ការងារពាណិជ្ជកម្ម

➢ អាជីវកម្ម-សេវាកម្ម

ចុះជម្រុញទីតាំងអាជីវកម្ម-សេវាកម្មបើកថ្មីនិងបន្តសុពលភាពបានចំនួនសរុប ២៣២ ទីតាំង រួមមាន៖

- ទីតាំងអាជីវកម្ម-សេវាកម្មដែលមានទំហំលើសពី ០៥ម៉ែត្រការ៉េ មានចំនួន ២៣២. ទីតាំង រួមមាន៖
- ថ្មី បានចំនួន ៧២ ទីតាំង
- បន្ត បានចំនួន ១៦០ ទីតាំង
- ទីតាំងអាជីវកម្ម-សេវាកម្មដែលមានទំហំក្រោម ០៥ម៉ែត្រការ៉េ មានចំនួន ០០ ទីតាំង រួមមាន៖

- ថ្មី បានចំនួន ០០ ទីតាំង
- បន្ត បានចំនួន ០០ ទីតាំង

➢ អាជីវកម្មលក់លោហធាតុថ្មមានតម្លៃជាគ្រឿងអលង្ការ

ចុះជម្រុញទីតាំងអាជីវកម្មលក់លោហធាតុថ្មមានតម្លៃជាគ្រឿងអលង្ការបើកបានចំនួន សរុប១០ទីតាំង៖

- ទីតាំងអាជីវកម្មនៅក្រៅផ្សារ មានចំនួន ០៩ ទីតាំង រួមមាន៖
- ថ្មី បានចំនួន ០១ ទីតាំង
- បន្ត បានចំនួន ០៨ ទីតាំង
- ទីតាំងអាជីវកម្មនៅក្នុងផ្សារ មានចំនួន ០១ តូប រួមមាន៖
- ថ្មី បានចំនួន ០០ តូប
- បន្ត បានចំនួន ០១ តូប

❖ ការងារកសិកម្ម

នៅក្នុងមូលដ្ឋានខណ្ឌការងារកសិកម្មគ្មាន។

❖ ការងារឧស្សាហកម្ម និងសិប្បកម្ម

ការងារសហគ្រាសធុនតូច និងមធ្យម ៖

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រតិភូកម្មថ្នាក់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ នៅក្រសួងរ៉ែ និងថាមពល
- ចុះជម្រុញម្ចាស់សិប្បកម្មលាងរថយន្ត ឱ្យមកសុំចុះបញ្ជី ចំនួន២០
- បានមកស្នើសុំចុះបញ្ជី នៅការិយាល័យច្រកចេញចូលតែមួយខណ្ឌ ចំនួន ៣មូលដ្ឋាន
- ចុះបញ្ជីសរុប ០៥មូលដ្ឋាន (ថ្មី ចំនួន ០២មូលដ្ឋាន)
- បានចេញលទ្ធផលវិភាគគុណភាពផ្នែកសិប្បកម្មផលិតចំណីអាហារ ចំនួន ០៨ទីតាំង ស្មើនិង០៨ មុខផលិតផល។

**២.២.២.២. វិស័យសង្គមកិច្ច**

❖ ការងារសង្គមកិច្ច អតីតយុទ្ធជន និងស្តានីតិសម្បទា

មន្ត្រីទទួលបន្ទុកបានធ្វើបញ្ជីបើកប្រាក់ខែឧបត្ថម្ភគោលនយោបាយជូន ជនចូលនិវត្តន៍ស៊ីវិល និងអតីតយុទ្ធជន ៖

- ជនចូលនិវត្តន៍ស៊ីវិល ចំនួន ១៨១៥ នាក់
- ជនបាត់បង់សប្បទាវិជ្ជាជីវៈ ចំនួន ៩៣ នាក់
- កូនក្នុងបន្ទុកសពមន្ត្រីរាជការស៊ីវិល ចំនួន ៣០ នាក់

- អតីតយុទ្ធជន ចំនួន ០០ នាក់
- យោធាពិការ ចំនួន ៩២ នាក់
- និវត្តន៍ជន ចំនួន ៣៣៣ នាក់
- និវត្តន៍នគរបាល ចំនួន ៥២ នាក់
- គ្រួសារមរណៈ ចំនួន ៥៩ នាក់

❖ ការងារកិច្ចការនារី

- ចូលរួមសកម្មភាពនានាជាមួយអង្គការដៃគូ និងអ្នកពាក់ព័ន្ធផ្សេងៗ
- គ.ក.ន.ក សង្កាត់ និងគ.ក.ស.ក ខណ្ឌ សហការណ៍ជាមួយការិយាល័យមានការពាក់ព័ន្ធដើម្បីអនុវត្តសកម្មភាពការងារ
- ផ្សព្វផ្សាយពីសុខភាពស្ត្រី កុមារថែទាំ អនាម័យស្ត្រីមុនសម្រាល និងក្រោយសម្រាល ។

❖ ការងារធម្មការ និងសាសនា

➢ ផ្នែកព្រះពុទ្ធសាសនា

- វត្តព្រះពុទ្ធសាសនា ចំនួន ០៤ វត្ត
- ព្រះសង្ឃសរុប ចំនួន ៤៥៨ អង្គ
- សម្តេច ចំនួន០៣ អង្គ
- ព្រះរាជគណៈ ចំនួន ០៥ អង្គ
- ព្រះចៅអធិការ ចំនួន ០៤ អង្គ
- ព្រះគ្រូ ចំនួន ០១ អង្គ
- អាចារ្យ-គណៈកម្មការ/តាជី-យាយជី ចំនួន ៦៦ នាក់
- សិស្ស-និស្សិត ចំនួន ២៦៦ នាក់ ។

➢ ផ្នែកពាហិរសាសនា

- គ្រឹស្ទសាសនា ចំនួន ១២
- អ្នកស្នាក់នៅសរុប ចំនួន ៣៥៦ នាក់
- បរិស័ទ្ធសរុប ចំនួន ២,៤៧៥ នាក់ ។

➢ ផ្នែកពុទ្ធិកសិក្សា ៖

ពុទ្ធិកបឋមសិក្សាវត្តទួលទំពូង សង្កាត់ទួលទំពូងទី១ គ្រូមានចំនួន ៨អង្គ/នាក់ និងសមណៈសិស្ស-សិស្ស ចំនួន ១៥ អង្គ/នាក់ ។

ពុទ្ធិកវិទ្យាល័យសម្តេចព្រះអភិសិរីសុគន្ធា មហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **ប៊ួរ គ្រី** សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជណាចក្រកម្ពុជា វត្តស្វាយពពែ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន គ្រូមានចំនួន ១៨អង្គ/នាក់ និងសមណៈសិស្ស-សិស្ស ចំនួន៣៥ អង្គ/នាក់ ។

❖ ការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ

មន្ត្រីទទួលបន្ទុកការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ បានចុះណែនាំដក់សហគ្រាសគ្រឹះស្ថានឱ្យដំកល់សៀវភៅ ច្បាប់ស្តីពី ការងារនៅកន្លែងធ្វើការ ងាយស្រួលដល់បុគ្គលិកស្វែងយល់ច្បាប់ស្តីពីការងារ ។ គ្រឹះស្ថានអប់រំវិជ្ជាជីវៈ ចំនួន០១ទីតាំង ។

❖ ការងារវប្បធម៌ និងវិចិត្រសិល្បៈ

មន្ត្រីជំនាញការងារវប្បធម៌ និងវិចិត្រសិល្បៈ នៃការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម បានចុះស្រង់ទិន្នន័យណែនាំ និងជម្រុញអាជីវកម្មតាមសង្កាត់ឱ្យមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម នៅការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលខណ្ឌ និងទៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ។ ចេញលិខិតអនុញ្ញាតបានចំនួន ២០ទីតាំង ។

❖ ការងារសុខាភិបាល

ក្រសួងសុខាភិបាលដែលអនុវត្តនៅក្នុងមូលដ្ឋានខណ្ឌបាន៖

- ការពិនិត្យផ្ទៃពោះសរុប ចំនួន ២៦៧ នាក់
- ការសម្រាលកូន ចំនួន ០៦ នាក់
- ការផ្តល់ជាតិដែក ៩០គ្រាប់មុនសម្រាល ចំនួន ១២៧ នាក់
- ចំនួនកុមារចាក់វ៉ាក់សាំងបង្ការគ្រប់មុខ ចំនួន ១៤១ នាក់
- ស្ត្រីមានផ្ទៃពោះចាក់ថ្នាំបង្ការតេតាណុសលើសពី២ដង ចំនួន ៤៣ នាក់
- ស្ត្រីអាយុ ១៥-៤៥ឆ្នាំ ចាក់ថ្នាំបង្ការតេតាណុសលើសពី២ដង ចំនួន ០៧ នាក់
- តាមដានជាប្រចាំករណីមាតាស្លាប់ និងទារកស្លាប់ក្រោម២៨ថ្ងៃ ចំនួន ០០ នាក់
- តាមដានជាប្រចាំករណីជំងឺផ្សេងៗ ចំនួន ០០ នាក់
- ប្រជុំពង្រឹងការងារគាំពារមាតា និងទារក កុមារ ចំនួន ០១ ដង ។ល។

❖ ការងារអប់រំ យុវជន និងកីឡា

➢ គ្រឹះស្ថានសាធារណៈ

- សាលាមត្តេយ្យដាច់ចំនួន ២សាលា (មិនដំណើរការចំនួន១សាលា) មានសិស្សសរុបចំនួន ១២៥ នាក់ ។
- ថ្នាក់មត្តេយ្យក្នុងបឋមសិក្សា សរុបមាន៩ថ្នាក់ មានសិស្សសរុប ២៣៤ នាក់ ស្រី ១១៨ នាក់ ។
- សាលាបឋមសិក្សាចំនួន ០៥សាលា មានសិស្សសរុបចំនួន ៤,៣៤៥ នាក់ ស្រី ២,០៥៩ នាក់
- សិស្សជាប់មធ្យមភាគសរុបចំនួន ៣,៩៤៦ នាក់ ស្រីចំនួន ១,៨៩២ នាក់ ត្រូវជា ៩០.៨១%
- សិស្សឆ្លងភូមិសិក្សាមានចំនួន ៧០៣ នាក់ ស្រីចំនួន ៣៧១ នាក់ ត្រូវជា ៩៤.១១%
- អនុវិទ្យាល័យមានដាច់ចំនួន ០១ សាលា សិស្សសរុប ១៦៦ ស្រី ៩២ នាក់ ជាប់មធ្យមភាគ ១៥៨ នាក់ ស្រី៨៩ នាក់ ត្រូវជា ៩៥.១៥% សិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ មានចំនួន ៤១ នាក់ ត្រូវជា ៩៧.៦៩% ។
- វិទ្យាល័យមាន៣សាលា មានសិស្សសរុបចំនួន ៦,៣៩៧នាក់ ជាប់មធ្យមភាគ ៥,៧៩៤ ស្រី ២,៩០៥ នាក់ ត្រូវជា ៩០,៦១% ។ សិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានចំនួន ៦៩១ នាក់ ត្រូវជា ៩២.៦៩% ។

➢ គ្រឹះស្ថានឯកជន

- សាលាមត្តេយ្យឯកជនដាច់ ចំនួន០៥ សាលា សិស្សសរុប ២៤១ នាក់ ស្រី ១២៦ នាក់ ។
- ថ្នាក់មត្តេយ្យក្នុងបឋមសិក្សាមាន ១៤ សាលា សិស្សសរុប ៧១៩ នាក់ ស្រី ៣៧៩ នាក់ ។
- សាលាចំណេះដឹងទូទៅបឋមភូមិ មានចំនួន២១សាលា មានសិស្សសរុប ៣,៧៧៦នាក់ ស្រី ១,៨៧០នាក់។
- សិស្សជាប់មធ្យមភាគសរុប ចំនួន ៣,៥៨៦ នាក់ ស្រី ១,៧៧៥ នាក់ ត្រូវជា ៩៣.៩៦% ។
- សិស្សឆ្លងភូមិសិក្សាមានចំនួន ៥៩៦ នាក់ ស្រី ៣០២ នាក់ ត្រូវជា ១០០% ។
- សាលាមធ្យមសិក្សាចំណេះទូទៅឯកជនមាន ៨សាលា សិស្សសរុបចំនួន២,៤៥២នាក់ ស្រី ១,១៨៧ នាក់។

### ២.២.២.៣. ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ

❖ អនាម័យ បរិស្ថាន

មន្ត្រីជំនាញ អនាម័យ បរិស្ថាន នៃការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និង សណ្តាប់ធ្នាប់សាធារណៈខណ្ឌ ចុះសហការជាមួយមន្ត្រីសង្កាត់ មន្ត្រីថ្នាក់មន្ទីរ មន្ត្រីថ្នាក់ក្រសួង បាន៖

- សហការជាមួយសង្កាត់ ក្រុមហ៊ុន ស៊ិន ទ្រី ចុះប្រមូលសំរាម ដឹកសំរាម និងសំអាតសំរាមតាមផ្លូវក្នុង មូលដ្ឋាន ខណ្ឌចំការមន ។
- បានអប់រំណែនាំអ្នកបញ្ចេញសំរាមខុសម៉ោងពេលកំណត់បានចំនួន ៣៥លើក ។

- បានអប់រំណែនាំ អ្នកចាក់កាកសំណល់ និងសម្ភារៈសំណង់អនាធិបតេយ្យលើចិញ្ចើមផ្លូវ និងទ្រូងផ្លូវ បានចំនួន ០៣ទីតាំង ។
- បានចុះអប់រំប្រជាពលរដ្ឋនៅតាមខ្នងផ្ទះឱ្យមាន ការវេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវតាមម៉ោងពេល និងទីកន្លែងកំណត់ និងណែនាំឱ្យជួយសំអាតមុខផ្ទះ និងសំអាតមានអណ្តូងលូបានចំនួន ៥៥ ខ្នងផ្ទះ ។
- បានចុះណែនាំអប់រំដល់ម្ចាស់ភោជនីយដ្ឋាន អ្នកលក់ដូរតាមចិញ្ចើមផ្លូវឱ្យទុកដាក់សំរាមឱ្យបានត្រឹមត្រូវ បានចំនួន ៥៥ទីតាំង ។
- តាមផ្សារនីមួយគណៈកម្មការផ្សារ បានធ្វើការលាងសំអាតដេប៉ូសំរាមជាប្រចាំ ជៀសវាងសាយក្លិនស្អុយចេញមកក្រៅធ្វើឱ្យប៉ះពាល់ដល់អាជីវកម្មដែលមានតូបលក់នៅជិតដេប៉ូសំរាម និងភ្ញៀវដែលអញ្ជើញមកផ្សារ ។ បានត្រួតពិនិត្យជាប្រចាំការទុកដាក់ វេចខ្ចប់សំរាម និងការប្រមូលសំរាមតាមធុង ដោយយកទៅរក្សាទុកក្នុងដេប៉ូសំរាមដើម្បីក្រុមហ៊ុនដឹកចេញ ។
- នៅក្នុងអំឡុងពេលកម្មករក្រុមហ៊ុន ស៊ិន ទ្រី បាតុកម្មបានប្រើប្រាស់កម្លាំងមន្ត្រីរដ្ឋបាលខណ្ឌ សណ្តាប់ធ្នាប់ ប្រជាការពារ មន្ត្រីសង្កាត់ ភូមិ យុវជន ចុះអន្តរាគមន៍ប្រមូលសំរាមក្នុងមូលដ្ឋានសង្កាត់ទាំង៥ បានទាន់ពេលវេលា ។

❖ ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

មន្ត្រីជំនាញ នៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល បានចុះណែនាំអំពីច្បាប់សាងសង់ ជួសជុលដល់ប្រជាពលរដ្ឋ ហើយក្រុមការងារសំណង់បានចុះធ្វើអធិការកិច្ចសំណង់ជាប្រចាំក្នុងមូលដ្ឋានក្នុងខណ្ឌ និងអនុវត្តការងាតាមជំនាញរៀងៗខ្លួនដែលថ្នាក់ដឹកនាំប្រគល់ជូន ។

➢ ការងារសុរិយោដី និងភូមិបាល

- ចេញប័ណ្ណកម្មសិទ្ធិផ្ទះ បានចំនួន ០៤ ប័ណ្ណ
- ចេញប័ណ្ណដី បានចំនួន ២៩ ប័ណ្ណ
- ចេញប័ណ្ណសហកម្មសិទ្ធិ បានចំនួន ០០ ប័ណ្ណ
- អំណោយផ្តាច់កម្មសិទ្ធិផ្ទះ បានចំនួន ០២ ច្បាប់
- អំណោយផ្តាច់កម្មសិទ្ធិប័ណ្ណដី បានចំនួន ៧៨ ច្បាប់
- អំណោយផ្តាច់សហកម្មសិទ្ធិ បានចំនួន ០០ ច្បាប់
- លក់ផ្តាច់កម្មសិទ្ធិ ចំនួន ០៨ ប័ណ្ណ
- លក់ផ្តាច់ប័ណ្ណដី ចំនួន ១៨១ ប័ណ្ណ

- លក់ផ្តាច់សហកម្មសិទ្ធិ បានចំនួន ១,២១៣ ច្បាប់
- កាន់កាប់ និងសាងសង់ បានចំនួន ០១ ច្បាប់
- ទុតិយតាដី-ផ្ទះ ចំនួន ០៣ ច្បាប់
- ទំនាស់ដី-ផ្ទះ ចំនួន ០០ ច្បាប់
- ការងារសាងសង់តាមការិយាល័យច្រកចេញចូលតែមួយ នៅសាលាខណ្ឌបាន ២០ច្បាប់
- ការងារជួសជុលតាមការិយាល័យច្រកចេញចូលតែមួយ នៅសាលាខណ្ឌបាន ២០ច្បាប់

➢ ការងារសំណង់

ការងារសំណង់ ចេញដោយការិយាល័យច្រកចេញចូលតែមួយ នៃសាលាខណ្ឌចំការមន

- សំណង់ថ្មីមានច្បាប់ បានចំនួន ២០
- សំណង់ថ្មីគ្មានច្បាប់ បានចំនួន ០០
- សំណង់ថ្មីខុសប្លង់ បានចំនួន ០០
- ស្នើសុំជួសជុលនៅមន្ទីរ បានចំនួន ០០
- សំណង់ជួសជុលមានច្បាប់ ចំនួន ១៤
- សំណង់ជួសជុលគ្មានច្បាប់ ចំនួន ០០
- សំណង់ជួសជុលខុសច្បាប់ ចំនួន ០០ ។

➢ ការងារសំណង់ ចេញដោយអង្គភាពច្រកចេញចូលតែមួយរាជធានីភ្នំពេញ

- សំណង់ថ្មីមានច្បាប់ បានចំនួន ០៩
- សំណង់ថ្មីគ្មានច្បាប់ បានចំនួន ០០
- សំណង់ថ្មីខុសប្លង់ បានចំនួន ០០
- ស្នើសុំជួសជុលនៅមន្ទីរ បានចំនួន ០០
- សំណង់ជួសជុលមានច្បាប់ ចំនួន ០១
- សំណង់ជួសជុលគ្មានច្បាប់ ចំនួន ០០
- សំណង់ជួសជុលខុសច្បាប់ ចំនួន ០០។

➢ ការងារសំណង់ ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់

- សំណង់ថ្មីមានច្បាប់ បានចំនួន ០៤
- សំណង់ថ្មីគ្មានច្បាប់ បានចំនួន ០០

- សំណង់ថ្មីខុសប្លង់ បានចំនួន ០០
- សំណង់ជួសជុលមានច្បាប់ ចំនួន ០០
- សំណង់ជួសជុលគ្មានច្បាប់ ចំនួន ០០
- សំណង់ជួសជុលខុសច្បាប់ ចំនួន ០០។

**២.២.២.៤. រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ការងារនីតិកម្ម និងដំណោះស្រាយវិវាទ

| ល.រ | បរិយាយសកម្មភាព | ចំនួន |
|---|---|---|
| ១ | ចូលរួមសម្រុះសម្រួលវិវាទជាមួយរដ្ឋបាលខណ្ឌ | ៥៨ |
| ២ | ចូលរួមចុះពិនិត្យទំនាស់ និងសំណង់ | ៣៧ |
| ៣ | ចូលរួមចុះអនុវត្តដីកាសម្រេច | ០២ |
| ៤ | ចូលរួមប្រជុំសាមញ្ញក្រុមប្រឹក្សាខណ្ឌ | ០៩ |
| ៥ | ចូលរួមប្រជុំ គ.ក.ស.ក | ០៧ |
| ៦ | ចូលរួមវគ្គបណ្តុះបណ្តាល | ០៣ |
| ៧ | ចូលរួមប្រជុំវេទិកាពិគ្រោះយោបល់ក្រុមប្រឹក្សាខណ្ឌ | ០៣ |
| ៨ | ចូលរួមប្រជុំចាំបាច់របស់រដ្ឋបាលខណ្ឌ | ០៥ |
| ៩ | ចូលរួមសហការជាមួយក្រុមការងារសុខាភិបាល | ០១ |
| ១០ | ប្រជុំថ្នាក់ការិយាល័យ | ០៤ |
| ១១ | ចូលរួមប្រជុំពង្រឹងការងារតាមការិយាល័យ | ០២ |
| ១២ | ចូលរួមប្រជុំគណៈបញ្ជាការឯកភាពខណ្ឌ | ០៩ |
| ១៣ | ចូលរួមប្រជុំនគរបាលយុត្តិធម៌ | ០១ |
| ១៤ | ចូលរួមប្រជុំវឌ្ឍនភាពការងារ និងទិសដៅខែបន្ទាប់ | ០១ |
| ១៥ | ចូលរួមប្រជុំបំពេញតារាងវិនិយោគរបស់ខណ្ឌ | ០១ |
| ១៦ | វគ្គផ្សព្វផ្សាយសេចក្តីណែនាំការផ្តល់លិខិតអញ្ជើញ | ០១ |
| ១៧ | ចូលរួមត្រួតពិនិត្យអាវុធជាតិផ្ទុះ និងគ្រឿងញៀន | ០១ |

❖ ការងារអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព

➢ សភាពការណ៍សន្តិសុខសង្គម ៖

ក្នុងរយៈពេល០១ ឆ្នាំ ២០២០ នេះ មានការប្រមូលផ្តុំធ្វើបាតុកម្ម កូដកម្ម និងតវ៉ា ផ្សេងៗ របស់កម្មករ អង្គការសង្គមស៊ីវិល សមាគម ប្រជាពលរដ្ឋ និងគណបក្សនយោបាយ កើតឡើង ៨៦ លើក/ ១០៥ រួមមាន៖

- កម្មករទាមទាររវ៉ា កើតឡើង ២៥ លើក ។[84]
- អង្គការសង្គមស៊ីវិល កើតឡើង ១១ លើក ។[85]
- ប្រជាពលរដ្ឋតាមទាមទារតវ៉ា កើតឡើង ៤៥ លើក ។[86]
- គណបក្សនយោបាយ កើតឡើង ០៥ លើក ។[87]

➢ សភាពការបទល្មើសព្រហ្មទណ្ឌ មាន៖

- បទល្មើសឧក្រិដ្ឋ កើតឡើង ០៣ លើក បង្ក្រាបបាន ០២លើក ឃាត់ខ្លួន ០៨នាក់
- បទល្មើសមជ្ឈឹម កើតឡើង ៣៣ លើក បង្ក្រាបបាន ៣២លើក ឃាត់ខ្លួន ៤៣នាក់

ស្លាប់ជនរងគ្រោះបុរស ០១នាក់ និងរបួសប្រុស ០២នាក់ ។

លទ្ធផលកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស បង្ក្រាបបាន ៥៦ករណី ឃាត់ខ្លួនជនល្មើស ៨៧នាក់ ប្រុស ៨៣នាក់ (បទល្មើសឧក្រិដ្ឋ ៥ករណី ឃាត់ខ្លួន ១៣នាក់ និងបទល្មើសមជ្ឈឹម ៥១ករណី ឃាត់ខ្លួន ៧៤នាក់) ។[88]

[84] របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី៩៦

[85] របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី៧០

[86] របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី៧០

[87] របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី៧១

[88] របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០ ទំព័រទី៧១

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ការគ្រប់គ្រងរដ្ឋបាលទៅតាមអភិបាលកិច្ចល្អ គឺជាការគោរពទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលជាពិសេស គឺជាការអភិវឌ្ឍតាមបែបវិមជ្ឈការ និងសហវិមជ្ឈការនៅ ថ្នាក់ក្រោមជាតិ។ នៅក្នុងនោះដែលការគ្រប់គ្រងរដ្ឋបាលនៅក្នុងខណ្ឌចំការមន គឺបានអនុវត្តទៅតាមអ្វីដែលថ្នាក់ជាតិបានដាក់ឱ្យអនុវត្តដែលដាក់ចេញនូវគោលការណ៍ដឹកនាំតាមបែបប្រជាធិបតេយ្យ ដោយមានការធ្វើប្រតិភូកម្ម ដែលធ្វើឱ្យសាលាខណ្ឌមានសិទ្ធ សម្រេចក្នុងការគ្រប់គ្រងខណ្ឌបានល្អ ជាពិសេសពីការគ្រប់គ្រងមកជាការបម្រើផលប្រយោជន៍សេវាសាធារណៈ ចំពោះប្រជាពលរដ្ឋនៅក្នុងខណ្ឌ។ ជាមួយគ្នានេះផងដែលការគ្រប់គ្រងរដ្ឋបាលខណ្ឌចំការមននាពេលបច្ចុប្បន្ននេះ គឺកាន់តែមានការអនុវត្តល្អប្រសើរឡើង ដោយបានគិតយ៉ាងល្អិតល្អន់ក្នុងការរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានា ដែលអាចធ្វើឱ្យប្រជាពលរដ្ឋរបស់ខ្លួន សុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត។ ពោល គឺបានអនុវត្តនូវគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល ជាពិសេសមានការគ្រប់គ្រង ជាលក្ខណៈអភិបាលកិច្ចល្អនៅក្នុងខណ្ឌ ឱ្យមានភាពប្រសើរឡើងដោយបានអនុវត្តតាម ៩ ចំណុចនៃអភិបាលកិច្ចល្អដែល ក្រសួងមហាផ្ទៃបានចែង ។

លើសពីនេះទៅទៀត កត្តាដែលជម្រុញឱ្យមានអភិបាលកិច្ចល្អនៅក្នុង ខណ្ឌចំការមន គឺដើម្បីអនុវត្តគ្រប់វិធានការការងារចាត់តាំងតាមគោលនយោបាយ ភូមិ-សង្កាត់ មានសុវត្ថិភាព បានកាន់តែល្អគ្រប់គ្រងបានសភាពការណ៍ សន្តិសុខនៅក្នុងខណ្ឌ ដោយផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋ វិនិយោគិន និងភ្ញៀវបរទេស។ ហើយនៅក្នុងពេលបច្ចុប្បន្នស្ថាប័នដែលពាក់ព័ន្ធ គឺបានខិតខំប្រឹងប្រែងបំពេញនៅតម្រូវការសេវាសាធារណៈរបស់ប្រជាពលរដ្ឋគ្រប់ ហើយបានពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកជូនប្រជាពលរដ្ឋ និងបានចុះធ្វើការណែនាំ និងធ្វើការហាមរាល់សកម្មភាពដែល ប្រាសចាកពីច្បាប់ និងក្រមសីលធម៌ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

សរុបសេចក្តីមកយើងអាចសន្និដ្ឋានបានថា អភិបាលកិច្ចល្អ របស់សាលាខណ្ឌចំការមន ពិតជាមានសារៈសំខាន់ណាស់ ព្រោះថាកាលណា ការគ្រប់គ្រងរដ្ឋបាលនៅក្នុងសាលាខណ្ឌមួយជ្រើសរើសយកការដឹកនាំដោយអភិបាលកិច្ចល្អ នោះនៅក្នុងខណ្ឌនោះប្រកដជាមានការអភិវឌ្ឍប្រកបដោយចីរភាព និងនិរន្តរភាព។ មិនត្រឹមតែប៉ុណ្ណោះទេ ការអនុវត្តនេះបែបបានធ្វើឱ្យប្រជាពលរដ្ឋ នៅក្នុងដែលសមត្ថកិច្ចរបស់ខ្លួនមានភាពសប្បាយរីករាយ ក្នុងការទៅទទួលសេវាកម្មរបស់ខណ្ឌ។ ពិសេសជាងនេះទៅទៀត បានធ្វើឱ្យប្រជាពលរដ្ឋមានភាពប្រសើរឡើងក្នុងការរស់នៅទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនាគតផងដែរ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការពិនិត្យមើលអំពីស្ថានភាពជាក់ស្តែង នៃការគ្រប់គ្រងរដ្ឋបាលរបស់ អភិបាលសាលាខណ្ឌចំការមន គឺយើងសង្កេតឃើញថាមាន លិទ្ធផលវិជ្ជមានជាច្រើនគួរឱ្យកំណត់សម្គាល់ ដោយក្នុងនោះផងដែលបានបម្រើដល់ផលប្រយោជន៍ដល់សាធារណៈជន និងអាចសម្រេចបានជាលទ្ធផលល្អប្រសើរសម្រាប់សង្គមជាតិផងដែរ ហើយក៏ជាកត្តាជម្រុញឱ្យប្រជាពលរដ្ឋមានទំនុកចិត្តទៅលើរាជរដ្ឋាភិបាលមួយកម្រិតទៀត។ ដោយទន្ទឹមនឹងមានលទ្ធផលវិជ្ជមានអភិបាលកិច្ចល្អនេះដែរ ក៏មានចំណុចខ្វះខាតដែលជាគុណវិបត្តិ ដែលជាកត្តាជម្រុញឱ្យមានការខិតខំប្រឹងប្រែងពង្រឹងការបន្ថែម នៃការគ្រប់គ្រងរដ្ឋបាលរបស់ អភិបាលសាលាខណ្ឌចំការមន។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ យើងខ្ញុំសូមសេចក្តីអនុញ្ញាតបញ្ចេញនូវមតិដូចតទៅ៖

- ស្នើសុំដល់ថ្នាកដឹកនាំនៃរដ្ឋបាលខណ្ឌចំការមន សូមមេត្តាពង្រឹងច្បាប់បន្ថែម និងអនុវត្តនូវគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពឱ្យបានរឹងមាំដើម្បីធានាដល់សុវត្ថិភាពក្នុងការរស់នៅនិងការដើរហើររបស់ប្រជាពលរដ្ឋ។
- សូមស្នើសុំបន្ថែមនៅការរៀបចំវគ្គបង្កើនសមត្ថភាពមន្ត្រី ការបង្កើនការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងាររបស់សង្កាត់នីមួយៗ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខណ្ឌ ដើម្បីធានាដល់ការអនុវត្តការងារ ប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌។
- សូមធ្វើការស្នើសុំបង្កើននូវការផ្សព្វផ្សាយច្បាប់ទាក់ទង នឹង សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ចរាចរណ៍ឱ្យបានប្រាកដថាប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ដែលខ្លួនគ្រប់គ្រង បានយល់ដឹងពីច្បាប់ និងសេចក្តីសម្រេចនានាដែលសាលាខណ្ឌបានដាក់ចេញសម្រាប់អនុវត្ត។
- ស្នើសុំដល់ថ្នាក់ដឹកនាំ និងអាជ្ញាធរមានសមត្ថកិច្ច ពង្រឹងបន្ថែមឱ្យបានល្អ នូវការការពារតាមគោលដៅនីមួយៗដែលមានស្រាប់ ដើម្បីធានាថាអាជ្ញាធរដែលគ្រប់គ្រងនៅគោលដៅនីមួយៗ អាចគ្រប់គ្រងបាននៅស្ថានការណ៍ទាំងអស់នៅតាមគោលដៅ និងសង្កាត់ដែលខ្លួនប្រចាំការ។
- ស្នើសុំដល់និស្សិត និងសាធារណៈជន ដែលបានអានលើប្រធានបទសារណារបស់យើងខ្ញុំបាទទាំងពីររូប សូមមេត្តាចូលរួមជាចំណែកក្នុងការចែករំលែកនូវចំណេះដឹងលើបញ្ហានេះ និងចូលរួមជួយជម្រុញឱ្យមានការថែរក្សា និងអភិវឌ្ឍន៍នូវស្នាដៃថ្មីៗបន្ថែមទៀត។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧
- ច្បាប់ស្តីពី ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១១
- អនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពី ការបង្កើតការិយាល័យ ប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពី ការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- អនុក្រឹត្យ លេខ ០៣ អនក្រ.បក ចុះ ថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៩ ស្តីពី ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ
- ប្រកាសអន្តរក្រសួង លេខ៣២៤ សហវ ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ៦៦០៦ បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍសមត្ថភាព របស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០១៩.២០២៣)

## ២. សៀវភៅនៃឯកសារនិពន្ធ

- វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត
- សៀវភៅ នីតិរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា
- សៀវភៅស្តីពី នីតិរដ្ឋបាលទូទៅ, សាស្ត្រាចារ្យ ហៀង សាង
- សៀវភៅស្តីពី អភិបាលកិច្ចល្អ
- សៀវភៅស្តីពី ការិយាល័យច្រកចេញចូលតែមួយ
- សៀវភៅស្តីពី ការិយាល័យប្រជាពលរដ្ឋ
- សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលខណ្ឌ ឆ្នាំ២០២០
- របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០២០

## ៣. គេហទំព័រ

- គេហទំព័រ http://freshnewsasia.com/index.php/en/localnews
- គេហទំព័រ https://www.interior.gov.kh/report/detail/2325
- គេហទំព័រ https://interior.gov.kh/news/detail/2225
- គេហទំព័រ https://www.moeys.gov.kh/index.php

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌចំការមន

ឧបសម្ព័ន្ធទី២៖ ទីតាំងសំខាន់នៅក្នុងខណ្ឌចំការមន និងសោភ័ណ្ឌភាពរបស់ខណ្ឌចំការមន

ឧបសម្ព័ន្ធទី៣៖ សកម្មភាពរបស់រដ្ឋបាលខណ្ឌចំការមន

## ២. ឧបសម្ព័ន្ធគតិយុត្ត

ឧបសម្ព័ន្ធទី១៖ ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លេខ នស/រកម/០៥០៨/០១៧

ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពី ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១១

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពី ការផ្ទេរប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

ឧបសម្ព័ន្ធទី៥៖ អនុក្រឹត្យ លេខៈ ០៣ អនក្រ.បក ចុះ ថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៩ ស្តីពី ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ របស់រាជរដ្ឋាភិបាលកម្ពុជា

ឧបសម្ព័ន្ធទី៦៖ អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ របស់រាជរដ្ឋាភិបាលកម្ពុជា

ឧបសម្ព័ន្ធទី៧៖ ប្រកាសអន្តរក្រសួង លេខ៣២៤ សហវ ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គ-ភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ឧបសម្ព័ន្ធទី៨៖ ប្រកាសលេខ ៦៦០៦ បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០១៩-២០២៣)

ឧបសម្ព័ន្ធទី៩៖ របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ ២០២០

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ ផែនទីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌចំការមន



ផែនទីរដ្ឋបាលរាជធានីភ្នំពេញ




ផែនទីរដ្ឋបាលខណ្ឌចំការមន




ទីតាំង៖ សាលាខណ្ឌចំការមន



ទីតាំង៖ ទីក្រុងរណបកោះពេជ្រ



ទីតាំង៖ រដ្ឋសភាជាតិ




ទីតាំង៖ ព្រឹទ្ធសភាជាតិ



ទីតាំង៖ ក្រសួងទំនាក់ទំនង ជាមួយរដ្ឋ-ព្រឹទ្ធសភា និងអធិការកិច្ច




ទីតាំង៖ ក្រសួងមហាផ្ទៃ



ទីតាំង៖ ស្ថានទូតវៀតណាម



ទីតាំង៖ ស្ថានទូតជប៉ុន



ទីតាំង៖សាលាភូមិន្ទរដ្ឋបាល




ទីតាំង៖ មណ្ឌលសុខភាពផ្សារដើមថ្កូវ




ទីតាំង៖  អគារ The Bridge



ទីតាំង៖ អាគារ វីរីវ៉ា




ទីតាំង៖ វិទ្យាល័យទួលទំពូង



ទីតាំង៖ វត្តទួលទំពូង



ទីតាំង៖ អាងស្តុកទឹកបឹងត្របែក



ទីតាំង៖ ស្ថានីយបូមទឹកបឹងត្របែក




ទីតាំង៖ វិទ្យាល័យហ៊ុន សែន ប៊ុន រ៉ានី ផ្សារដើមថ្កូវ




ទីតាំង៖ វិទ្យាល័យ បឹងត្របែក

# ឧបសម្ព័ន្ធទី៣៖ សកម្មភាពរបស់រដ្ឋបាលខណ្ឌចំការមន





សកម្មភាព៖ គណៈអភិបាលចុះចែកអំណោយ






សកម្មភាព៖ មន្ត្រីការិយាល័យច្រកចេញចូលតែមួយ បម្រើសេវាជូនប្រជាពលរដ្ឋ






សកម្មភាព៖ ការប្រមូលសំរាម និងការលាងសម្អាតផ្លូវក្នុងខណ្ឌចំការមន





សកម្មភាព៖ យុទ្ធនាការចុះចាក់វ៉ាក់សាំងការពារជំងឺកូវីត-១៩ ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានខណ្ឌ





សកម្មភាព៖ ការរៀបចំប្រព័ន្ធកែលម្អលូ និងការរៀបចំប្រលាយបឹងត្របែក





សកម្មភាព៖ ក្រុមការងាររបស់រដ្ឋបាលចុះធ្វើការណែនាំម្ចាស់អាជីវកម្ម ភោជនីយដ្ឋាន





សកម្មភាព៖ ការចុះពិនិត្យគោលដៅនៅពេលបិទខ្ទប់





សកម្មភាព៖ ការចុះអន្តរាគមន៍ពន្លត់អគ្គីភ័យជូនប្រជាពលរដ្ឋ

# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នា សម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបាន ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្ដីពី

## ការគ្រប់គ្រងរដ្ឋបាល

## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.-**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២

## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១

### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៣.-**

អភិបាលរងរាជធានី អភិបាលរងខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរប្រភេទ ដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិ ចាប់ពីវរមន្ត្រីឡើងទៅ

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៤.-**

អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរប្រភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង

-មានអាយុ ចាប់ពីសាមសិប(៣០)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំ(០៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង

-មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**មាត្រា ១៤៥.-**

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវធ្វើការជ្រើសរើសពីក្នុង

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភាឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣/ល.០៩០៥.៥៩៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខៈ ៥៥៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជីនកេន**

# ព្រះរាជក្រម

នស/រកម/០៦១១/០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# របបហិរញ្ញវត្ថុ

# និងការគ្រប់គ្រងទ្រព្យសម្បត្តិ

# របស់

# រដ្ឋបាលថ្នាក់ក្រោមជាតិ

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

# ជំពូកទី ៤
# ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៤៧.-**

ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមានទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឲ្យ និង ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង ។ រដ្ឋផ្ទេរ និង ប្រគល់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិកាន់កាប់ និង ប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋមួយចំនួនដែលជាអចលនវត្ថុ ហើយស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗទៅតាមការកំណត់របស់រដ្ឋ ។

ការផ្ទេរ ប្រគល់ទ្រព្យសម្បត្តិរបស់រដ្ឋទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ការផ្ទេរ ប្រគល់ ត្រូវបានប្រតិបត្តិក្នុងលក្ខណៈដែលអាចដកហូតយកមកវិញបាន ។

**មាត្រា ៤៨.-**

ការផ្ទេរទ្រព្យសម្បត្តិពីថ្នាក់ជាតិដើម្បីជាគុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ប្រើប្រាស់ជាសាធារណៈ ឬ សម្រាប់បំពេញនូវតម្រូវការនៃសេវាសាធារណៈ ត្រូវសមស្របទៅនឹងមុខងារ ដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

**មាត្រា ៤៩.-**

ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលត្រូវបានផ្ទេរប្រគល់ឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ប្រើប្រាស់ និង ទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវថែរក្សាការពារឲ្យបានគង់វង្ស និង គ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬ ផ្ទេរការប្រើប្រាស់ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

**មាត្រា ៥០.-**

ទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ជាកម្មសិទ្ធិផ្ទាល់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិស្វ័យសម្រេចក្នុងការគ្រប់គ្រង និង ប្រើប្រាស់ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ នៅក្នុងក្របខ័ណ្ឌដែលត្រូវកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។



Kol

ជំនួសស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ច្បាប់នេះ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៥៥.-**

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ បទប្បញ្ញត្តិទាំងឡាយដែលជាវិសោធនកម្មនៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង និង បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.១១០៦.៥៩៤ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**
**គាត ឈន់**

២៦/២០៦

លេខៈ ៥៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា៤ .-**

វាក្យសព្ទបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- **ប្រសិទ្ធផល** សំដៅដល់លទ្ធផលចុងក្រោយ ឬគុណភាពនៃលទ្ធផលដែលមានឥទ្ធិពល ឬផលប៉ះពាល់រយៈពេលវែង។
- **បុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ** សំដៅដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលិករបស់មន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួង ស្ថាប័នដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។
- **បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលបានជ្រើសរើស និងតែងតាំងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលបានផ្ទេរតាមដំណើរការនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឬចាត់តាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិ ឱ្យទៅបំពេញការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលិកជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងទីប្រឹក្សាបច្ចេកទេសដែលបានជ្រើសរើសដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២
## ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា៥ .-**

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតម្រូវឱ្យមានការអនុម័តដោយក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក រួមមាន៖

- ការរៀបចំផែនការបុគ្គលិក
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាលនិងនាយកទីចាត់ការ ឬ ប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលរាជធានី ខេត្តសម្រាប់រដ្ឋបាលរាជធានី ខេត្ត។
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាលនិងប្រធានការិយាល័យ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលក្រុង ស្រុក សម្រាប់រដ្ឋបាលក្រុង ស្រុក
- ការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិក។

**មាត្រា៦ .-**

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមិនតម្រូវឱ្យមានការអនុម័តដោយក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក រួមមាន៖

- ការជ្រើសរើសបុគ្គលិក
- ការធ្វើកម្មសិក្សា ការតាំងស៊ប់ និងការបញ្ឈប់កម្មសិក្សា
- ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងចាប់ពីនាយករងទីចាត់ការ ឬអនុប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលរាជធានី ខេត្តចុះក្រោមសម្រាប់រដ្ឋបាលរាជធានី ខេត្ត។ ដោយឡែកសម្រាប់រដ្ឋបាលរាជធានីក្រៅពីមុខតំណែងខាងលើនេះត្រូវរួមបញ្ចូលទាំងមុខតំណែងចាប់ពីនាយករងរដ្ឋបាលនៃរដ្ឋបាលខណ្ឌចុះក្រោម
- ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងចាប់ពីអនុប្រធានការិយាល័យក្រុង ស្រុក ឬអនុប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលចុះក្រោមសម្រាប់រដ្ឋបាលក្រុង ស្រុក
- ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៨ ..**

អនុក្រឹត្យលេខ៤៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្ទេរប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០កើត ខែ បុស្ស ឆ្នាំ រកា ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ គ.ស២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**និងជាប្រធានគណៈកម្មាធិការ**
**កែទម្រង់រដ្ឋបាលសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...០៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន០៧ ពីខណ្ឌចំការមន នៃរាជធានីភ្នំពេញគឺ សង្កាត់បឹងកេងកងទី១ សង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់អូឡាំពិច សង្កាត់ទំនប់ទឹក សង្កាត់ទួលស្វាយព្រៃទី១ និងសង្កាត់ទួលស្វាយព្រៃទី២។

ព្រំប្រទល់រដ្ឋបាលខណ្ឌបឹងកេងកង ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានផ្ទេរទីតាំងសាលាខណ្ឌចំការមនដែលស្ថិតក្នុងសង្កាត់បឹងកេងកងទី៣ ទៅឲ្យសាលាខណ្ឌបឹងកេងកង។

ទីតាំងសាលាខណ្ឌចំការមន ត្រូវស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខណ្ឌបឹងកេងកង ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌចំការមន គណៈអភិបាលខណ្ឌចំការមន ក្រុមប្រឹក្សាខណ្ឌបឹងកេងកង គណៈអភិបាលខណ្ឌបឹងកេងកង និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៩៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**មាត្រា ៥.-**

រដ្ឋបាលខណ្ឌមានកាតព្វកិច្ចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានីភ្នំពេញ ដោយផ្អែកតាមគោលការណ៍ នីតិវិធី ស្តង់ដាសេវាដែលបានកំណត់ និងធនធានដែលបានផ្ទេរមានភ្ជាប់លក្ខខណ្ឌ ព្រមទាំងអាចប្រើប្រាស់ធនធានដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីអនុវត្តមុខងារទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព។

គោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលត្រូវបានធ្វើប្រតិភូកម្ម ត្រូវកំណត់ដោយក្រសួង ស្ថាប័ននៃវិស័យនីមួយៗ ឬដោយរដ្ឋបាលរាជធានីភ្នំពេញ។

**មាត្រា ៦.-**

រដ្ឋបាលរាជធានីត្រូវពិនិត្យមើលឡើងវិញនូវមុខងារនានារបស់ខ្លួន ដើម្បីបន្តផ្ទេរមុខងារសមស្របទៅឱ្យរដ្ឋបាលខណ្ឌ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## ការបង្កើត តួនាទី ភារកិច្ច និងរបៀបរបបការងារនៃការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលខណ្ឌ

### ផ្នែកទី១

### ការបង្កើតការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលខណ្ឌ

**មាត្រា ៧.-**

រដ្ឋបាលខណ្ឌនីមួយៗត្រូវមានការិយាល័យ និងអង្គភាពមួយចំនួនជាចំណុះដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងបុគ្គលិក
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។

**មាត្រា ៨.-**

អង្គការលេខរបស់រដ្ឋបាលខណ្ឌមានកំណត់នៅក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

ការិយាល័យ និងអង្គភាពដែលបង្កើតបន្ថែមមិនត្រូវមានមុខងារ តួនាទី ភារកិច្ចត្រួតគ្នាជាមួយការិយាល័យ និងអង្គភាពដែលបានបង្កើតតាមមាត្រា៧នៃអនុក្រឹត្យនេះ។

ក្នុងករណីមានការបង្កើតការិយាល័យ និងអង្គភាពបន្ថែមដោយបំបែកចេញពីការិយាល័យ និងអង្គភាពណាមួយ មុខងារ តួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពបង្កើតថ្មីនេះត្រូវផ្ទេរចេញពីការិយាល័យ និងអង្គភាពដើម។

## ផ្នែកទី២

## តួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលខណ្ឌ

**មាត្រា ១៣.-**

**ការិយាល័យរដ្ឋបាល និងបុគ្គលិក**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងាររដ្ឋបាល និងបុគ្គលិក និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងការងារសហប្រតិបត្តិការអន្តរជាតិ
- ការងារអត្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលខណ្ឌ
- ការពិនិត្យ និងលើកយោបល់លើការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ
- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលខណ្ឌតាមការផ្ទេរសិទ្ធិពីរដ្ឋបាលរាជធានី
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលខណ្ឌ
- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំរបស់រដ្ឋបាលខណ្ឌ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**មាត្រា ១៤.-**

**ការិយាល័យផែនការ និងហិរញ្ញវត្ថុ**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារផែនការ និងហិរញ្ញវត្ថុ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលខណ្ឌ
- ការសិក្សា ការរៀបចំ និងការអនុវត្តគម្រោងនានារបស់រដ្ឋបាលខណ្ឌ
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលខណ្ឌ
- ការងារស្ថិតិប្រជាជន

- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ខណ្ឌតាមការកំណត់
- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានសង្កាត់ និងទិន្នន័យថ្នាក់ខណ្ឌ
- ការងារហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលខណ្ឌ
- ការងាររបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលខណ្ឌ
- ការគាំទ្រដល់រដ្ឋបាលសង្កាត់ក្នុងខណ្ឌតាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**មាត្រា ១៥.-**

**អង្គភាពលទ្ធកម្ម**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារលទ្ធកម្មសាធារណៈ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្តល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**មាត្រា ១៦.-**

**ការិយាល័យលេខាធិការក្រុមប្រឹក្សា**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារលេខាធិការដ្ឋានជូនក្រុមប្រឹក្សាខណ្ឌ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងការពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា
- ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានារបស់ក្រុមប្រឹក្សា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា និងអភិបាលខណ្ឌ។

**មាត្រា ១៧.-**

**ការិយាល័យអប់រំ យុវជន និងកីឡា**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារ

អប់រំ យុវជន និងកីឡា និងមានភារកិច្ចគ្រប់គ្រង គាំទ្រ សម្របសម្រួល និងតាមដាន ត្រួតពិនិត្យ វាយតម្លៃលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា
- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយ និងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**មាត្រា ១៨.-**

**ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារសំណង់
- ការងារលំនៅឋាន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**មាត្រា ១៩.-**

**ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន**មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារនីតិកម្ម និងការសម្រុះសម្រួលវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការសិក្សាស្រាវជ្រាវ ការរៀបចំ និងការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលខណ្ឌ
- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដល់មន្ត្រី បុគ្គលិក និងប្រជាពលរដ្ឋនៅនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌ
- ការផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ
- ការរៀបចំការបណ្តុះបណ្តាលជំនាញសម្រុះសម្រួល និងច្បាប់ដល់រដ្ឋបាលសង្កាត់ក្នុងខណ្ឌ
- ការទទួលពាក្យបណ្តឹង និងការសម្រុះសម្រួលវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌស្របតាមច្បាប់កំណត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។



ស

**មាត្រា ២០.-**

**ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសាធារណការ និងដឹកជញ្ជូន
- ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ការគ្រប់គ្រងផ្សែង សម្លេង ក្លិន និងការបំពុលបរិយាកាស
- ការដាំ ការគ្រប់គ្រង និងការថែទាំដើមឈើ និងសួនច្បារសាធារណៈ
- ការគ្រប់គ្រងភ្លើងបំភ្លឺទីសាធារណៈ
- ការគ្រប់គ្រងចំណតយានយន្តសាធារណៈ
- ការងារសណ្តាប់ធ្នាប់សាធារណៈ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**មាត្រា ២១.-**

**ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការអភិវឌ្ឍសេដ្ឋកិច្ច ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសហគមន៍ និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារឧស្សាហកម្ម និងសិប្បកម្ម
- ការងាររ៉ែ និងថាមពល
- ការងារទេសចរណ៍
- ការងារពាណិជ្ជកម្ម
- ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការងារធនធានទឹក
- ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
- ការងារអភិវឌ្ឍន៍សហគមន៍
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**មាត្រា ២២.-**

**ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គម និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- ការងារសុខាភិបាល
- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោះមហន្តរាយ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**មាត្រា ២៣.-**

**ការិយាល័យច្រកចេញចូលតែមួយ**ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលខណ្ឌលើការងារផ្តល់សេវារដ្ឋបាលនានា និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការទទួល និងការផ្តល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខណ្ឌ
- ការប្រមូល និងការបង់កម្រៃសេវារដ្ឋបាល តាមគោលការណ៍ និងនីតិវិធីកំណត់
- ការផ្តល់ព័ត៌មាននានា និងការផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ការទុកដាក់ ការថែរក្សា និងការគ្រប់គ្រងឯកសារនានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ។

**មាត្រា ២៤.-**

មុខងាររង ឬសកម្មភាពជាក់លាក់នៃមុខងារនីមួយៗពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមវិស័យនានាមានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

រដ្ឋបាលខណ្ឌអាចកំណត់បន្ថែមនូវតួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនីមួយៗដោយផ្អែកតាមស្ថានភាព និងតម្រូវការជាក់ស្តែងនៃខណ្ឌនីមួយៗ។

## ផ្នែកទី៣
## របៀបរបបការងាររបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលខណ្ឌ

**មាត្រា ២៥.-**

ការិយាល័យ និងអង្គភាពនីមួយៗត្រូវបំពេញមុខងារស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រដ្ឋបាលខណ្ឌត្រូវរៀបចំឱ្យមានលក្ខខណ្ឌការងារជាក់លាក់សម្រាប់បុគ្គលិកម្នាក់ៗ ដោយផ្អែកតាមតួនាទី ភារកិច្ចរបស់ការិយាល័យ និងអង្គភាពនីមួយៗ និងគោលការណ៍ណែនាំជាធរមាន។

លក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗត្រូវមានការឯកភាពពីរដ្ឋបាលរាជធានី។

បុគ្គលិកម្នាក់ៗនៃការិយាល័យ និងអង្គភាពនីមួយៗត្រូវបំពេញតួនាទី ភារកិច្ចរបស់ខ្លួនស្របតាមលក្ខខណ្ឌការងារដែលបានកំណត់។

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងក្រុមប្រឹក្សាសង្កាត់នៃរាជធានីភ្នំពេញត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

__**កន្លែងទទួល:**__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១÷ អង្គការលេខរបស់រដ្ឋបាលខណ្ឌ**

**ភ្ជាប់នឹងអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣២៤ សហវ.ប្រក

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**នីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ**

**នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ



៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
kat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**ប្រការ ៧.-**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានសមាសភាពដូចខាងក្រោម៖

- អភិបាលក្រុង ស្រុក ខណ្ឌ ប្រធាន
- អភិបាលរងក្រុង ស្រុក ខណ្ឌ ០១រូប អនុប្រធាន
- សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌយ៉ាងច្រើន០៣រូប សមាជិក
- នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានអង្គភាពលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ លេខាធិការ

សមាសភាពអនុប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវស្នើដោយអភិបាលក្រុង ស្រុក ខណ្ឌ។

សមាសភាពនៃគណៈកម្មាធិការលទ្ធកម្មក្រុង ស្រុក ខណ្ឌ ដែលជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌត្រូវជ្រើសរើសដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។

**ប្រការ ៨.-**

ក្នុងដំណើរការកិច្ចលទ្ធកម្មនីមួយៗ ប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវតែងតាំងសមាជិកចំពោះកិច្ចមួយចំនួន ដែលជាមន្ត្រីមានសមត្ថភាពគាំទ្របច្ចេកទេសមកពីអង្គភាព ស្ថាប័នរបស់រដ្ឋ ឬ ជួលពីខាងក្រៅដោយប្រើប្រាស់ថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអាចអញ្ជើញមន្ត្រីជំនាញក្នុងរដ្ឋបាលរបស់ខ្លួន ឬ ពីអង្គភាព ស្ថាប័នរដ្ឋផ្សេងៗទៀត ដើម្បីជួយផ្តល់យោបល់។

សមាជិកចំពោះកិច្ចនៃគណៈកម្មាធិការលទ្ធកម្មត្រូវរំសាយដោយស្វ័យប្រវត្តិនៅពេលកិច្ចលទ្ធកម្មនោះត្រូវបានបញ្ចប់ជាស្ថាពរ។

**ប្រការ ៩.-**

សមាជិកគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការលទ្ធកម្ម។

**ប្រការ ១០.-**

គណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវធ្វើសេចក្តីសម្រេចដោយសម្លេងភាគច្រើន។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានគណៈកម្មាធិការលទ្ធកម្មមានឧត្តមានុភាព។

**ប្រការ ២១.-**

ផ្អែកតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាមទារឲ្យមានការរៀបចំនូវយន្តការ នីតិវិធី ការតែងតាំងមន្ត្រី និងការបណ្តុះបណ្តាលកសាងសមត្ថភាពជាមុន។ ការរៀបចំនូវកិច្ចដំណើរការទាំងនេះត្រូវអនុវត្តភ្លាមបន្ទាប់ពីប្រកាសនេះចូលជាធរមាន ដើម្បីឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានលទ្ធភាពអនុវត្តនូវកិច្ចលទ្ធកម្មសាធារណៈរបស់ខ្លួន ក្នុងពេលវេលាសមស្របណាមួយក្នុងឆ្នាំ២០១៣។

ក្នុងពេលដែលកិច្ចដំណើរការខាងលើនេះពុំទាន់បានរៀបចំចប់សព្វគ្រប់ កិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវអនុវត្តតាមយន្តការ និងនីតិវិធីនៃកិច្ចលទ្ធកម្មសាធារណៈដែលអនុវត្តនៅរដ្ឋបាលរាជធានី ខេត្ត។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ២២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ២៣.-**

ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាសង្កាត់ អង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចម្លងជូនៈ</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋានគ.ជ.អ.ប
- ដូចប្រការ ២៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៦៦០៦ ប្រក

# ប្រកាស
## ស្តីពី
## ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៩២ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន
- យោងតាមសំណើរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់សមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានសមត្ថភាពវិជ្ជាជីវៈក្នុងការបំពេញការងារ និងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។

**ប្រការ១២.-**

រាល់ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវកត់ត្រាឱ្យបានត្រឹមត្រូវ និងច្បាស់លាស់នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអភិវឌ្ឍន៍សមត្ថភាព ដែលគ្រប់គ្រងដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី។

មន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលបានទទួលការអភិវឌ្ឍសមត្ថភាព ត្រូវទំនាក់ទំនងមកអង្គភាពទទួលបន្ទុកអភិវឌ្ឍន៍សមត្ថភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី តាមរយៈប្រធានអង្គភាពផ្ទាល់របស់ខ្លួន ដើម្បីបញ្ចូលទិន្នន័យនៃការអភិវឌ្ឍសមត្ថភាពទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ប្រការ១៣.-**

អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ត្រូវសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធដើម្បីធានាឱ្យមានប្រព័ន្ធគ្រប់គ្រងទិន្នន័យអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានរៀបចំ ប្រើប្រាស់ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងនិរន្តរភាព។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ នាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន ប្រធានអង្គភាពនានាក្រោមឱវាទក្រសួងមហាផ្ទៃ ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ គណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ និងអ្នកពាក់ព័ន្ធនានា ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២ រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី៤
ទម្រង់ទី៤

រាជធានី ៖ ភ្នំពេញ
ខណ្ឌ ៖ ចំការមន
លេខ ៖ ១៣៤/២០ ខចម

# របាយការណ៍ប្រចាំឆ្នាំ

## ស្ដីពី
## ការអនុវត្តការងាររបស់រដ្ឋបាលខណ្ឌចំការមន

ប្រចាំឆ្នាំ ២០២០

# សេចក្តីផ្តើម

ខណ្ឌចំការមន គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងកើតទល់នឹងខណ្ឌច្បារអំពៅ ដោយដងទន្លេបាសាក់, ខាងលិចទល់នឹងខណ្ឌបឹងកេងកង, ខាងត្បូងទល់នឹងខណ្ឌមានជ័យ, ខាងជើងទល់នឹងខណ្ឌដូនពេញ (ផ្ទៃដីសរុបមានទំហំ ៧,១៥១,៤២៤.៥៧ម៉ែត្រការ៉េ ស្មើនឹង ៧១៥ហិកតា ១៤អា និង២៤ទីអា។

| ល.រ | ការបរិយាយ | សរុប | ឯកត្តា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ៧,១៥១,៤២៤.៥៧ | ម៉ែត្រការ៉េ |
| ២ | ចំនួនសង្កាត់ | ០៥ | សង្កាត់ |
| ៣ | ចំនួនភូមិ | ៣៨ | ភូមិ |
| ៤ | ចំនួនគ្រួសារ | ៩,៤៤២ | គ្រួសារ |
| ៥ | ចំនួនប្រជាពលរដ្ឋ | ៤៧,០៥៣ | នាក់ |
| ៦ | ចំនួនស្ត្រីសរុប | ២២,៦១២ | នាក់ |

របាយការណ៍ប្រចាំឆ្នាំ២០២០ ការបរិយាយអំពីសមិទ្ធផលការងារប្រចាំឆ្នាំទី១ នៃអាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌ ដើម្បីឆ្លើយតបនូវផែនការអភិវឌ្ឍរយៈពេល ០៥ឆ្នាំ (២០២០-២០២៤) ។ របាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការងាររដ្ឋបាលខណ្ឌ មាន០៦ ផ្នែកដែលក្នុងនោះ ៖

- ផ្នែកទី១: **ការគ្រប់គ្រងរដ្ឋបាលខណ្ឌ**

បរិយាយអំពីលទ្ធផលនៃការអនុវត្តការងាររដ្ឋបាល ផែនការ និងការគាំទ្រសង្កាត់ ការគ្រប់គ្រងធនធានមនុស្ស ការងារអន្តរវិស័យ និងការងារហិរញ្ញវត្ថុរបស់រដ្ឋបាលខណ្ឌ។

- ផ្នែកទី២: **ការងាររដ្ឋបាលសង្កាត់**

បរិយាយសង្ខេបអំពីលទ្ធផលនៃការអនុវត្តការងាររបស់រដ្ឋបាលសង្កាត់ និងបញ្ហាប្រឈមដែលសង្កាត់

បានជួបប្រទះ ព្រមទាំងសំណើដំណោះស្រាយបញ្ហាប្រឈមទាំងនោះ។

- ផ្នែកទី៣: **ការងាររបស់ការិយាល័យ អង្គភាពជំនាញ**

បរិយាយអំពីលទ្ធផលនៃការអនុវត្តការងាររបស់ការិយាល័យ អង្គភាពជំនាញនានា ដែលមានទីតាំងនៅក្នុងដែនសមត្ថកិច្ចខណ្ឌ។

- ផ្នែកទី៤: **បញ្ហាប្រឈម និងដំណោះស្រាយ**

បរិយាយអំពីបញ្ហាប្រឈមនានា ដែលរដ្ឋបាលខណ្ឌ និងការិយាល័យ អង្គភាពជំនាញ បានជួបប្រទះ និងសំណើ ដំណោះស្រាយ បញ្ហាប្រឈម ទាំងនោះ។

- ផ្នែកទី៥: **ទិសដៅការងារឆ្នាំបន្ទាប់**

បរិយាយអំពីសកម្មភាពជាអាទិភាព ដែលរដ្ឋបាលខណ្ឌ និងការិយាល័យ អង្គភាពជំនាញ បានគ្រោងសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។

# ផ្នែកទី១
# ការគ្រប់គ្រងរដ្ឋបាលខណ្ឌ

## ១.១. ការងាររដ្ឋបាល

១.១.១.ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

- សេចក្តីសម្រេចដែលបានដាក់ចេញ មានចំនួន ២០ ។
- លិខិតរដ្ឋបាលដែលបានដាក់ចេញចំនួន ៤៧៥ លិខិត ។
- លិខិតដែលទទួលបានចំនួន ២,០៤៧ លិខិត។
- សៀវភៅស្នាក់នៅដែលបានចេញ ចំនួន ៣១៤ សៀវភៅ។

តារាងទី១៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ដីកាដែលបានដាក់ចេញ | ០០ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ២០ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ៤៧៥ |
| ៤ | លិខិតដែលបានទទួល | ២,០៤៧ |
| ៥ | សៀវភៅស្នាក់នៅ | ៣១៤ |

១.១.២. ការគ្រប់គ្រងប្រជាពលរដ្ឋ

ស្ថិតិប្រជាពលរដ្ឋមានចំនួន ៩,៤៤២គ្រួសារ , មនុស្សចំនួន ៤៧,០៥៣នាក់ ស្រីចំនួន ២២,៦១២ នាក់ ប្រជាពលរដ្ឋខ្មែរ អាយុ ១៨ឆ្នាំឡើង ចំនួន ៣០,៣៦៩នាក់ ។

តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សរុបគ្រួសារ | ៩,៤៤២ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៧,៣៣៨ |
| ៣ | គ្រួសារបណ្តោះអាសន្ន | ១,៩៦៥ |
| ៤ | ប្រជាពលរដ្ឋសរុប | ៤៧,០៥៣ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ២២,៦១២ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៣០,៣៦៩ |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | ០០ |

១.១.៣. ការងារអត្រានុកូលដ្ឋាន

ការចម្លងសំបុត្រអត្រានុកូលដ្ឋានឆ្លងឆ្នាំអនុវត្តបាន៖ ១-សេចក្តីចម្លងសំបុត្រកំណើត ៤០០ , ២-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតបាន ៣,០៧៤ ,៣-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍បាន ៥៤៥ ,៤-សេចក្តីចម្លងសំបុត្រមរណៈភាពបាន ៦០។

តារាងទី៣៖ ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេចក្តីចម្លងសំបុត្រកំណើត | ៤០០ នាក់ |
| ២ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ៣,០៧៤ នាក់ |
| ៣ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៥៤៥ នាក់ |
| ៤ | សេចក្តីចម្លងសំបុត្រមរណភាព | ៦០ នាក់ |

១.១.៤. ការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ (រួមទាំងការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល និងការងារចងសម្ព័ន្ធមេត្រីភាព )

-ការងារផ្សព្វផ្សាយតាមទូរទស្សន៍បានចំនួន ៦៧ លើក បិទផ្សាយព័ត៌មានសាធារណៈចំនួន ៤៨ ,សាធារណៈជនមកទំនាក់ទំនងនៅសាលាខណ្ឌចំនួន ១,៩៩៥ ,គណៈប្រតិភូភ្ញៀវជាតិ-អន្តរជាតិ ចំនួន ១៩៥នាក់។

តារាងទី៤៖ ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ក). ការផ្សព្វផ្សាយព័ត៌មាន | | |
| ១ | វិទ្យុ | ០០ |
| ២ | ទូរទស្សន៍ | ៦៧ |
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | ៤៨ |
| ៤ | ព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តី សារព័ត៌មាន | ០៥ |
| ៥ | ផ្សេងៗ | ១៧៦ |
| ខ). ទំនាក់ទំនងសាធារណៈ | | |
| ១ | សាធារណៈជនមកទំនាក់ទំនងសាលាខណ្ឌ | ២០,៣២៣ នាក់ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | ៣៨ នាក់ |

១.១.៥. ការងារគណៈអភិបាល(រួមទាំងការអនុវត្តតួនាទីជាតំណាងក្រសួង ស្ថាប័ន)

ប្រជុំអឌ្ឍមាសរបស់គណៈអភិបាល មានចំនួន ១២លើក ការប្រជុំប្រចាំខែរបស់គណៈអភិបាល មាន១២លើក។

តារាងទី៥៖ កិច្ចប្រជុំគណៈអភិបាល

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ១២ |
| ២ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | ១២ |

ក្រៅពីការងារប្រជុំអឌ្ឍមាស និងកិច្ចប្រជុំប្រចាំខែ គណៈអភិបាលបានបំពេញការងារផ្សេងទៀត ទៅតាមការបែងចែកភារកិច្ច និងទៅតាមការប្រគល់ភារកិច្ចបន្ថែម ជាតំណាងឱ្យលោកអភិបាលខណ្ឌ ដើម្បីចុះទៅបំពេញការងារនានា។ (សូមអានលម្អិតក្នុងតារាង ឧបសម្ព័ន្ធទី៣)

១.១.៦. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ចំនួន ១២ លើក កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា( គ្មាន), កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សាខណ្ឌចំនួន (គ្មាន) កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ០២ លើក ,កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីកុមារ ចំនួន ១១ លើក ។

តារាងទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១២ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ០០ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០០ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ០២ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ១១ |

តារាងទី៧៖ ការរៀបចំវេទិកា

| ល.រ | ឈ្មោះវេទិកា | អ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | បានរៀបចំវេទិកាសាធារណៈអនុវត្តគោលនយោបាយភូមិ.សង្កាត់មានសុវត្ថិភាព ៤៦ លើក | ២,២៦២ | ៩៨១ |
| ២ | បានរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខណ្ឌចំការមន ទាំង៥សង្កាត់ បានចំនួន០៣លើក | ៣៨៣ | ៨៩ |
| ៣ | បានរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី២ | ០០ | ០០ |

+វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខណ្ឌចំការមន បានរៀបចំ ចំនួន ០៣លើក
- លើកទី១ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ នៅវត្តទួលទំពូង អ្នកចូលរួមសរុប ១៤១ នាក់ ស្រី ៣១នាក់
- លើកទី២ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ នៅវត្តទួលទំពូង អ្នកចូលរួមសរុប ១៣០នាក់ ស្រី ៣២នាក់
- លើកទី៣ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ នៅវត្តនួនមុណីរាម អ្នកចូលរួមសរុប ១១២នាក់ ស្រី ២៦នាក់

+វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវបានពន្យាពេល២លើក ដោយសារតែការឆ្លងជំងឺកូវីដ-១៩។

## ១.២. ការងារផែនការ និងការគាំទ្រសង្គាត់ (ការិយាល័យផែនការ និងហិរញ្ញវត្ថុ)

### ១.២.១. ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខណ្ឌ

- បានរៀបចំសៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់ខណ្ឌ(២០២០-២០២៤)
- បានរៀបចំសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ(២០២១-២០២៣)និងសៀវភៅទិន្នន័យខណ្ឌឆ្នាំ ២០២០។
- ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ បានដាក់ពង្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ (២០២១-២០២៣) ជូនក្រុមប្រឹក្សាដើម្បីធ្វើការពិនិត្យនិងអនុម័ត នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី១៨ របស់ក្រុមប្រឹក្សាខណ្ឌចំការមន ក្រោមអធិបតីភាពលោក ព្រំ សំខាន់ ប្រធានក្រុមប្រឹក្សាខណ្ឌ ។

តារាងទី៨៖ គម្រោងវិនិយោគបីឆ្នាំរំកិលខណ្ឌ

| ល.រ | ផ្នែក | ចំនួនគម្រោង | តម្លៃគម្រោង |
|---|---|---|---|
| ១ | សេដ្ឋកិច្ច | ០១ | ១៤៣,៥០០,០០០៛ |
| ២ | សង្គមកិច្ច | ០៤ | ២៧,០០០,០០០៛ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០៥ | ៨៧១,៨០២,០០០៛ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ០៩ | ៤៤,៩៦០,០០០៛ |
| សរុប | | ១៩ | ៩៥៣,០៩០,០០០៛ |

### ១.២.២. ការអនុវត្តគម្រោងវិនិយោគខណ្ឌ

គម្រោងវិនិយោគខណ្ឌ ត្រូវអនុវត្តនៅឆ្នាំ២០២០ គម្រោងខាងក្រោមនេះ គឺជាគម្រោងដែលគាំទ្រដោយថវិការដ្ឋបាលខណ្ឌ ចំពោះគម្រោងគាំទ្រដោយមន្ទីរជំនាញ អង្គការ មិនបានរាប់បញ្ចូលក្នុងតារាងខាងក្រោមនេះទេ គម្រោងសរុបមានចំនួន ១៩គម្រោង ក្នុងនោះ ផ្នែកសេដ្ឋកិច្ចមាន ០១គម្រោង, ផ្នែកសង្គមកិច្ចមាន ០៤គម្រោង, ផ្នែកប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុមាន ០៥គម្រោង, ផ្នែករដ្ឋបាលនិងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈមាន ០៩ គម្រោង។

### តារាងទី៩៖ ការអនុវត្តគម្រោងវិនិយោគខណ្ឌ
(ព័ត៌មានបន្ថែមមាននៅក្នុងឧបសម្ព័ន្ធទី១)

| ល.រ | ផ្នែក | សរុប | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|
| | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ០១ | ០០ | ០០ | ០១ |
| ២ | សង្គមកិច្ច | ០៤ | ០០ | ០០ | ០៤ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០៥ | ០០ | ០០ | ០៥ |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ០៩ | ០០ | ០០ | ០៩ |
| សរុប | | ១៩ | ០០ | ០០ | ១៩ |

១.២.៣. ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣

### តារាងទី១០ ៖ ការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣
(ព័ត៌មានបន្ថែមមាននៅក្នុងឧបសម្ព័ន្ធទី២)

| លេខកូដ | ឈ្មោះសកម្មភាព | ស្ថានភាព | %សម្រេច | ថវិកាគ្រោង | | | សេចក្តីបរិយាយ |
|---|---|---|---|---|---|---|---|
| | | | | គ្រោង | ចំណាយ | % ចំណាយ | |
| ៣.១.៦.១ | ការលើកកម្ពស់ និងការបញ្ជៀបយេនឌ័រ និងបរិយាយ ប័ន្ទ និងសមធម៌សង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុង | ១០០% | គ្មាន | គ្មាន | គ្មាន | ពុំមានថវិកា |
| ៣.១.៦.១.១៣ | ការបំពេញមុខងាររបស់ គ.ក.ស.ក | កំពុង | ១០០% | គ្មាន | គ្មាន | គ្មាន | |
| | គាំទ្រការចំណាយប្រតិបត្តិការជាប្រចាំសម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ (មន្ត្រី ផអ៣) | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | |

១.២.៤. ការគាំទ្រសង្កាត់

- ប្រជុំផ្សព្វផ្សាយដល់គ្រប់សង្កាត់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ
- ចុះសិក្សាគម្រោងតាមសង្កាត់ទាំង៥
- ជម្រុញសង្កាត់ក្នុងការរៀបចំធ្វើកម្មសិទ្ធិដីធ្លីដែលជាទ្រព្យសម្បត្តិរដ្ឋ
- ជម្រុញសង្កាត់ទាំង៥ ត្រៀមឯកសារចូលរួមសមាហរណកម្មផែនការសង្កាត់ខណ្ឌ

- ជម្រុញសង្កាត់ទាំង៥ រៀបចំសៀវភៅកម្មវិធីវិនិយោគសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់ (២០២១-២០២៣)
- ជម្រុញសង្កាត់ទាំង៥រៀបចំសៀវភៅទិន្នន័យភូមិ សង្កាត់ឆ្នាំ២០២០
- ពង្រឹងសកម្មភាព សមត្ថភាព របស់គ.ក.ន.ក សង្កាត់ទាំង៥
- ពង្រឹងសង្កាត់ទាំង៥ ប្រជុំប្រចាំខែក្រុមប្រឹក្សាសង្កាត់ និងប្រជុំគ.ក.ន.ក អោយបានទៀងទាត់
- ជម្រុញសង្កាត់ទាំង៥ ផ្តល់របាយការណ៍គ.ក.ន.ក មកខណ្ឌឲ្យបានទៀងទាត់

## ១.៣. ការគ្រប់គ្រងធនធានមនុស្ស

### ១.៣.១. ការគ្រប់គ្រងបុគ្គលិក

១.៣.១. ការគ្រប់គ្រងបុគ្គលិក

របនាសម្ព័ន្ធខណ្ឌរួមមាន ៖ សមាជិកក្រុមប្រឹក្សាខណ្ឌ ចំនួន ១៩រូប សរុប ១៩ រូប ស្រី ០៤ រូប, ប្រធានក្រុមប្រឹក្សាខណ្ឌ ០១ រូប(ប្រុស), សមាជិកក្រុមប្រឹក្សាខណ្ឌដែលបានផ្លាស់ប្តូរ ០១រូប , គណៈអភិបាលខណ្ឌមាន ០៥រូប ស្រី ០១រូប ក្នុងនោះអភិបាលខណ្ឌ ០១ រូប និងអភិបាលរងខណ្ឌ ០៤ រូប ស្រី ០១ រូប, នាយក នាយករងរដ្ឋបាល ០៣រូប, ប្រធានការិយាល័យ និងអង្គភាពលទ្ធកម្ម ០៧រូប ស្រី ០១ រូប, អនុប្រធានការិយាល័យ និងអង្គភាពលទ្ធកម្ម ១៨ រូប ស្រី ០២ រូប, មន្ត្រីការិយាល័យ និងស្មៀនសង្កាត់ចំនួន ៤២ រូប ស្រី ១៧ រូប, បុគ្គលិកជាប់កិច្ចសន្យា ១៤០រូប ស្រី ២៩រូប។

តារាងទី១១៖ ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា | ១៩ | ០៤ |
| ២ | ប្រធានក្រុមប្រឹក្សា | ០១ | ០០ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ០១ | ០០ |
| ៤ | អភិបាល | ០១ | ០០ |
| ៥ | អភិបាលរង | ០៤ | ០១ |
| ៦ | នាយករដ្ឋបាល | ០១ | ០០ |
| ៧ | នាយករងរដ្ឋបាល | ០២ | ០០ |
| ៨ | ប្រធានការិយាល័យ និងអង្គភាព | ០៧ | ០១ |
| ៩ | អនុប្រធានការិយាល័យ និងអង្គភាព | ១៨ | ០២ |
| ១០ | មន្ត្រីការិយាល័យ(រាប់ទាំងស្មៀនសង្កាត់) | ៤២ | ១៧ |
| ១១ | បុគ្គលិកកិច្ចសន្យា | ១៤០ | ២៩ |

១.៣.២. ការកសាងសមត្ថភាព

ឆ្នាំ២០២០ ថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលខណ្ឌ បានចូលរួមចំនួន ១៤ វគ្គ អ្នកចូលរួមសរុប១៤៨នាក់ ស្រី ៥០នាក់។

**តារាងទី១២៖ ការអភិវឌ្ឍសមត្ថភាព**

| ល.រ | ឈ្មោះវគ្គសិក្សា | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ១៤ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ១៤៨ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៥០ |

## ១.៤. ការងារអន្តរវិស័យ

(ត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាព និងលទ្ធផលរបស់ការិយាល័យ រួចហើយ)

**១.៤.១. ការសម្របសម្រួលតាមវិស័យ**

(ត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាព និងលទ្ធផលរបស់ការិយាល័យ រួចហើយ)

**១.៤.២. ការអនុវត្តមុខងារផ្សេងៗ** (មុខងារដែលបានប្រតិភូកម្ម)

..........................................................................................................................................

**១.៤.៣. ការដោះស្រាយ និងសម្រុះសម្រួលទំនាស់**

- បានទទួលលិខិតចូលចំនួន ៨៤ ច្បាប់
- បានចេញលិខិតចំនួន ៧០ ច្បាប់

**តារាងទី១៣៖ ការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | បណ្ដឹងចូលថ្មីចំនួន | ៣៤ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ៩ |
| ៣ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលខណ្ឌ | ២០ |
| ៤ | បណ្ដឹងកំពុងដោះស្រាយបន្ត | ៥ |

១.៤.៤. កិច្ចការច្រកចេញចូលតែមួយ

ការិយាល័យច្រកចេញចូលតែមួយខណ្ឌចំការមន បានផ្ដល់សេវាជូនប្រជាពលរដ្ឋ បានចំនួន ២១,៥១១ សេវា, ប្រជាពលរដ្ឋមកទទួលសេវាបានចំនួន ២០,៣២៣ នាក់,ស្រីចំនួន ៥,៦៥២ នាក់, ចំណូល សរុបចំនួន ១៣២,៣៧២,២០០ រៀល។

តារាងទី១៤ ៖ កិច្ចការច្រកចេញចូលតែមួយ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់ | ២១,៥១១ នាក់ |
| ២ | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | ២០,៣២៣ នាក់ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | ៥,៦៥២ នាក់ |
| ៤ | ចំណូលដែលទទួលបានពីការផ្តល់សេវា | ១៣២,៣៧២,២០០ ៛ |
| ៥ | ករណីបណ្តឹងដែលទទួលបានសរុប | 0 |
| ៦ | ករណីបណ្តឹងដែលបានដោះស្រាយរួចជាស្ថាពរ | 0 |

### ១.៤.៥. កិច្ចការសេវាសង្គម និងការបង្កើនសិទ្ធិអំណាចស្ត្រី:

តារាងទី១៥៖ ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក

| ល.រ | សូចនាករ | ផែនការប្រចាំឆ្នាំ | លទ្ធផលសម្រេច | |
|---|---|---|---|---|
| | | | ជាក់ស្តែង | % |
| ១ | ចំនួនកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ខណ្ឌ | ១២ | ១១ | ៩២% |
| ២ | ចំនួនថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើផ្នែកសេវាសង្គម (រៀល) | - | - | - |
| ៣ | ខណ្ឌបានចងក្រងទិន្នន័យអត្រានុកូលដ្ឋាន ដែលទទួលបានពីសង្កាត់ | ១,៩៣០ | ២,១៥៦ | ១១១% |
| ៤ | ចំនួនបេសកកម្មដែល គ.ក.ស.ក ខណ្ឌបានចុះគាំទ្រ និងផ្តល់សេវាសង្គម | ០០ | ០០ | ០០ |
| ៥ | ចំនួនសង្កាត់ដែល គ.ក.ស.ក ខណ្ឌ បានចុះគាំទ្រ | ០៥ | ០៥ | ១០០% |
| ៦ | ចំនួនវគ្គបណ្តុះបណ្តាលដែល គ.ក.ស.ក ខណ្ឌបានទទួល | ០០ | ០១ | ១០០% |

## ១.៥. ការងារហិរញ្ញវត្ថុ

### ១.៥.១.ការអនុវត្តចំណូល និងចំណាយ

- យោងសារាចរណែនាំលេខ០០១ សហវ.អថ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការធ្វើវិចារណកម្ម និងពង្រឹងប្រសិទ្ធិភាពចំណាយសម្រាប់ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី/ខេត្ត។

- លិខិតលេខ ២៤៩ លស.ហ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ របស់សាលារាជធានីភ្នំពេញ ស្តីពីការធ្វើវិចារណកម្ម ថវិការដ្ឋបាលខណ្ឌទាំង១៤ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២០ ឡើងវិញ។
- ការអនុវត្តចំណូល៖ ប្រភពចំណូលមានពីរប្រភេទ គឺចំណូលដែលទទួលបានពីការឧបត្ថម្ភធនរបស់សាលារាជធានីភ្នំពេញ អនុម័តដើមឆ្នាំមានចំនួន៖៥,០០០,០០០,០០០៛ និងមួយប្រភេទទៀតបានមកពីការផ្តល់សេវាសាធារណៈតាមរយៈការិ.ច្រកចេញចូលតែមួយ ចំនួន ៦៦,០០០,០០០៛។ ប៉ុន្តែដោយផ្អែកលើសភាពការណ៍វិវត្តថ្មី នៃសេដ្ឋកិច្ចសកល ពិសេសការផ្ទុះរីករាលដាលនូវជំងឺរលាកផ្លូវដង្ហើមដ៏ធ្ងន់ធ្ងរ(COVID-19)ដែលបណ្តាលអោយមាន ផលប៉ះពាល់ដល់ក្របខណ្ឌច្បាប់ថវិកាឆ្នាំ២០២០ ជាទូទៅ និងតម្រូវអោយរាជរដ្ឋាភិបាលធ្វើវិចារណកម្មថវិកាឡើងវិញ ដោយកាត់ចេញពីកញ្ចប់ថវិកាឆ្នាំ២០២០ ចំនួន៖១,៥០០,០០០,០០០៛ (មួយពាន់ប្រាំរយលានរៀល)។
- ថវិកាអនុម័តដំបូងចំណូលមានចំនួន ៥,០៦៦,០០០,០០០ ៛ ក្រោយធ្វើវិចារណកម្ម ចំណូលមានចំនួន ៣,៥៦៦,០០០,០០០ ៛។
- ថវិកាអនុម័តដំបូងចំណាយមានចំនួន ៥,០៦៦,០០០,០០០ ៛ ក្រោយធ្វើវិចារណកម្ម ចំណាយមានចំនួន ៣,៥៦៦,០០០,០០០ ៛។

តារាងទី១៦៖ ការអនុវត្តចំណូល និងចំណាយ

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត (ក្រោយវិចារណកម្ម) | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| **ផ្នែកចំណូល** | | | | |
| ៧០ | ចំណូលសារពើពន្ធ | | | |
| ៧២ | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | | | |
| ៧៣ | ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិ និងសេវា | ៦៦,០០០,០០០៛ | ១៤១,៤២៦,១៤០ | ២១៤,២៨% |
| ៧៤ | ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម | | | |
| ៧៥ | ការឧបត្ថម្ភកធន | ៣,៥០០,០០០,០០០៛ | ៣,៥០០,០០០,០០០៛ | ១០០% |
| ៧៦ | ផលហិរញ្ញវត្ថុ | | ១១,៥៤៩,១២០៛ | |
| ៧៧ | ផលផ្សេងៗ និងផលពិសេស | | | |
| ៧៨ | ការងារនៃរដ្ឋទេយ្យ | | | |
| ០៨ | ចំណូលមូលនិធិបម្រុង | | | |
| ១៣ | ឧបត្ថម្ភធន-វិនិយោគ | | | |
| | សរុបចំណូល | ៣,៥៦៦,០០០,០០០៛ | ៣,៦៥២,៩៧៥,២៦០ | ១០២,៤៣% |

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត (ក្រោយវិចារណកម្ម) | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| **ផ្នែកចំណាយ** | | | | |
| ៦០ | ការទិញ | ២២៧,៦២០,០០០៛ | ១៥០,០៩០,៥០០៛ | ៦៥,៩៤% |
| ៦១ | សេវាខាងក្រៅ | ៩១០,០៦០,០០០៛ | ៩០៥,៨៣៥,១០០៛ | ៩៩,៥៣% |
| ៦២ | សេវាខាងក្រៅផ្សេងៗ | ១១០,០០០,០០០៛ | ៣៣៩,១២៩,០០០៛ | ៣០៨,៣០% |
| ៦៣ | ពន្ធ និងអាករ | | | |
| ៦៤ | បន្ទុកបុគ្គលិក | ២,០៥៦,៣២០,០០០៛ | ២,១១៥,៥៩១,១៦០៛ | ១០២,៨៣% |
| ៦៥ | ឧបត្ថម្ភធននិងជំនួយសង្គម | | | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | | | |
| ៦៧ | បន្ទុកពិសេស | | | |
| ៦៨ | ទាយជ្ជទានឱ្យដល់រំលោះ អចលកម្មរូបី | | | |
| ០៩ | ចំណាយមិនបានគ្រោងទុក | ២៥៣,០០០,០០០៛ | ០០ | ០០% |
| ២០ | អចលកម្មអរូបី | | | |
| ២១ | អចលកម្មរូបី | | | |
| | សរុបចំណាយ | ៣,៥៦៦,០០០,០០០៛ | ៣,៥១០,៦៤៥,៧៦០៛ | ៩៨,៤៥% |

### ១.៥.២.ការគ្រប់គ្រងទ្រព្យសម្បត្តិ

តារាងទី១៧៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិ ដែលបានទិញ ឬទទួល (ថ្មី) | ០០ ប្រភេទ |
| ២ | ទ្រព្យសម្បត្តិ ដែលបានកាត់ចេញ | ០០ ប្រភេទ |
| ៣ | ទ្រព្យសម្បត្តិ សរុប | ០០ ប្រភេទ |

## ១.៦. ការងារលទ្ធកម្ម

១-**ការងារផ្សព្វផ្សាយ:**

- បានផ្សព្វផ្សាយឯកសារដេញថ្លៃ-ពិគ្រោះថ្លៃ និង ស្ទង់តម្លៃ សម្ភារ( លូ-ផ្លូវ ) សំណង់- បានចំនួន ០៩លើក លើទំព័រ កាសែត។

២-**ការងារពិគ្រោះថ្លៃ-ដេញថ្លៃគម្រោង:**

- បានរៀបចំបញ្ជីប៉ាន់តម្លៃ និងស្នើសុំគោលការណ៍ធានាចំណាយ សម្រាប់ការដេញថ្លៃនិងស្ទង់តម្លៃសម្ភារ ថវិកា និយ័តចុងឆ្នាំ និងការបន្ថែមឥណទានសម្រាប់ការប្រើប្រាស់របស់ការិយាល័យដែលបានសមាហរណកម្មមក រដ្ឋបាលខណ្ឌចំការមន ទៅមន្ទីរសេដ្ឋកិច្ច រួចរាល់។

# ផ្នែកទី៣
# ការងាររបស់ការិយាល័យ អង្គភាពជំនាញ

## ៣.១. សេដ្ឋកិច្ច

### ៣.១.១- ការិយាល័យផែនការ និងហិរញ្ញវត្ថុ

**ការងារផែនការ**

+ បានអនុវត្តការងារ

- ចុះសិក្សាគម្រោងមូលនិធិសង្កាត់ឆ្នាំ២០២០
- សម្របសម្រួលការដេញថ្លៃគម្រោងមូលនិធិសង្កាត់ឆ្នាំ២០២០
- សម្របសម្រួលសង្កាត់រៀបចំផែនការកម្មវិធីវិនិយោគសម្រាប់ឆ្នាំ២០២០
- រៀបចំផែនការកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) របស់រដ្ឋបាលខណ្ឌចំការមន
- សម្របសម្រួលសិក្ខាសាលាសមាហរណកម្មវិនិយោគ សង្កាត់ ខណ្ឌ ឆ្នាំ (២០២១-២០២៣) នៅថ្នាក់ខណ្ឌ
- រៀបចំសៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលខណ្ឌ (២០២១-២០២៣)
- រៀបចំសៀវភៅផែនការអភិវឌ្ឍ៥ឆ្នាំ (២០២០-២០២៤) របស់រដ្ឋបាលខណ្ឌចំការមន
- សម្របសម្រួលសង្កាត់រៀបចំសៀវភៅកម្មវិធីវិនិយោគសម្រាប់ឆ្នាំ២០២១
- ចូលរួមវគ្គបណ្តុះបណ្តាលការស្រង់ព័ត៌មានទិន្នន័យភូមិ សង្កាត់ ខណ្ឌ ឆ្នាំ២០២០ ។

+ បានចូលរួមកម្មវិធីផ្សេងៗ ដូចខាងក្រោម៖

- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ២០២១-២០២៣
- ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលនៃការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅសាលាខណ្ឌចំការមន។
- ចូលរួមវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខណ្ឌចំការមន ឆ្នាំ២០២០អាណត្តិទី៣ នៅវត្តទួលទំពូង និងវត្តថាន់។
- ចូលរួមវគ្គផ្សព្វផ្សាយស្តីពីប្រព័ន្ធប្រកាសឱ្យដឹងមុន១២៩៤ ថ្នាក់ខណ្ឌនៅសាលាខណ្ឌចំការមន។
- បំពេញតារាង១.១.ក ៖ តម្រូវការគម្រោង សកម្មភាពអាទិភាពរបស់រដ្ឋបាលខណ្ឌ បញ្ជូនទៅការិយាល័យផែនការនិងវិនិយោគ។
- បំពេញទម្រង់ទី៤ តារាងបច្ចុប្បន្នភាពតម្រូវការគម្រោង សកម្មភាពអាទិភាពរបស់រដ្ឋបាលខណ្ឌ បញ្ជូនទៅការិយាល័យផែនការ និងវិនិយោគ។
- ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ បានចូលរួមប្រជុំស្តីពីការអនុវត្តការងារតាមបណ្តាការិយាល័យ ក្រោមអធិបតីភាព **លោកស្រី កែវ សាម៉ុល** អភិបាលរងខណ្ឌចំការមន។
- ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ បានចូលរួមប្រជុំគណៈបញ្ជាការឯកភាពខណ្ឌ ក្រោមអធិបតីភាព **លោក ថេង សុថុល** អភិបាល នៃគណៈអភិបាលខណ្ឌចំការមន។

- បញ្ជូនរបាយការណ៍ស្តីពីលទ្ធផលនៃសិក្ខាសាលាសមាហរណកម្មផែនការសង្កាត់ ខណ្ឌ ទៅសាលារាជធានីភ្នំពេញ, មន្ទីរនានាដែលគាំទ្រគម្រោងសង្កាត់ ខណ្ឌ និង សង្កាត់ទាំង៥។
- បានបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំខណ្ឌ(២០២០-២០២៤) តាមការណែនាំក្នុងលិខិតអនុលោមភាពលេខ៩២០/២០ ធត.ផ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានីភ្នំពេញ។
- ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ បានចូលរួមប្រជុំគណៈបញ្ជាការឯកភាពខណ្ឌចំការមន ក្រោមអធិបតីភាពលោក **ថេង សុធុល**អភិបាលនៃគណៈអភិបាលខណ្ឌចំការមន នៅសាលប្រជុំសាលាខណ្ឌចំការមន។
- ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៧ របស់ក្រុមប្រឹក្សាខណ្ឌចំការមន ក្រោមអធិបតីភាពលោក **ព្រំ សំខាន់** ប្រធានក្រុមប្រឹក្សាខណ្ឌ និង លោក **ថេង សុធុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមននៅសាលប្រជុំសាលាខណ្ឌចំការមន។
- ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ បានចូលរួមប្រជុំស្តីពីការចុះប៉ាន់ប្រមាណតម្រូវការសមត្ថភាពនៅថ្នាក់ខណ្ឌរបស់គណៈប្រតិភូសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាពលោកស្រី **កែវ សាម៉ុល** អភិបាលរងខណ្ឌនៅសាលប្រជុំសាលាខណ្ឌចំការមន។
- ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០ បានចូលរួមប្រជុំគណៈបញ្ជាការឯកភាពខណ្ឌចំការមន ក្រោមអធិបតីភាពលោក **ថេង សុធុល**អភិបាលនៃគណៈអភិបាលខណ្ឌចំការមន នៅសាលប្រជុំសាលាខណ្ឌចំការមន។
- ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ បានចូលរួមប្រជុំត្រួតពិនិត្យរបៀបរបបធ្វើការងាររបស់មន្ត្រីសាលាខណ្ឌចំការមនទាំង១១ការិយាល័យ និងអង្គភាព ក្រោមអធិបតីភាពលោកស្រី **កែវ សាម៉ុល** អភិបាលរងខណ្ឌ នៅសាលប្រជុំសាលាខណ្ឌចំការមន។
- បានរៀបចំសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ(២០២១-២០២៣)និងសៀវភៅទិន្នន័យខណ្ឌឆ្នាំ២០២០។
- ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ បានចូលរួមប្រជុំសាមញ្ញរបស់គ.ក.ស.កខណ្ឌ ប្រចាំខែវិច្ឆិកា ក្រោមអធិបតីភាពលោកស្រី កែប សំបូរ ប្រធានគ.ក.ស.កខណ្ឌ នៅសាលប្រជុំសាលាខណ្ឌចំការមន។
- ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៨ របស់ក្រុមប្រឹក្សាខណ្ឌចំការមន ក្រោមអធិបតីភាពលោក ព្រំ សំខាន់ ប្រធានក្រុមប្រឹក្សាខណ្ឌ និងបានដាក់ពង្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ(២០២១-២០២៣)ជូនក្រុមប្រឹក្សាដើម្បីធ្វើការពិនិត្យនិងអនុម័ត។

### ៣.១.២- ការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ

- បានចុះពិនិត្យមើលការជួសជុលផ្លូវក្នុងមូលដ្ឋាន ចំនួន ៣០លើក
- បានចុះពិនិត្យមើលរថយន្តដឹកដីដែលធ្វើឱ្យប៉ះពាល់បរិស្ថានតាមដងផ្លូវ និងឃាត់រថយន្តមកធ្វើការណែនាំចំនួន ១០ករណី។
- ចុះរៀបចំសណ្តាប់ធ្នាប់តាមមហាវិថី និងតាមផ្លូវក្នុងមូលដ្ឋានជាប្រចាំ។

- ចុះពិនិត្យ និងសហការណ៍ជាមួយក្រុមហ៊ុនស៊ិនទ្រី ប្រមូលសំរាមកុំឱ្យមានការកកស្ទះសំរាម ជាប្រចាំ
- ចុះពិនិត្យប្រឡាយ,លូបង្ហូរទឹក,ការជីកផ្លូវដាក់លូថ្មី និងការកាត់ខ្សែកាបអុបទិចតាមដងផ្លូវបានចំនួន ២០លើក។
- ចុះកាប់មែកឈើ បានចំនួន ២០លើក។
- ចុះពិនិត្យគុណភាពបរិស្ថាន និងណែនាំតាមភោជនីយ៍ដ្ឋាន និងសិប្បកម្ម ចំនួន១០លើក (៨០ទីតាំង)។
- ចុះពិនិត្យលិខិតអនុញ្ញាត និងណែនាំម្ចាស់អាជីវកម្មយានដ្ឋានជួសជុលរថយន្ត សរុប ៥២ទីតាំង។

### ៣.១.២- <u>**ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍**</u>

#### ១. **ការងារទេសចរណ៍**

- នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ លោក **ហាយ សិទ្ធី** ប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ លោកអនុប្រធានការិយាល័យ និងមន្ត្រីក្រោមឱវាទ បានចូលរួមជាមួយគណៈបញ្ជាការឯកភាពខណ្ឌចំការមនដឹកនាំលោក **កែវ សំណាង** អភិបាលរង នៃគណៈអភិបាលខណ្ឌចំការមន បានចុះត្រួតពិនិត្យទីតាំងអាជីវកម្មក្លឹបកំសាន្តចំនួន ០២ គឺក្លឹបកំសាន្ត Epic និង មូស ៩ ដែលស្ថិតនៅផ្លូវរដ្ឋសភាថ្មី ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ក្រុមការងារត្រួតពិនិត្យឃើញថា ក្លឹបកំសាន្តទាំង ០២ ខាងលើ បានកែប្រែពីក្លឹបកំសាន្ត មកជាភោជនីយដ្ឋាន ដោយមានលិខិតអនុញ្ញាតប្រកបអាជីវកម្មភោជនីយដ្ឋាន របស់រដ្ឋបាលរាជធានីភ្នំពេញ។
- ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ លោក **ហាយ សិទ្ធី** ប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ លោកអនុប្រធានការិយាល័យ និងមន្ត្រីក្រោមឱវាទ ចូលរួមជាមួយគណៈបញ្ជាការឯកភាពខណ្ឌចំការមន ដឹកនាំដោយលោក **ថេង សុផុល** អភិបាល នៃគណៈអភិបាលខណ្ឌចំការមន បានចុះត្រួតពិនិត្យទីតាំងអាជីវកម្មចំនួន ០២ទីតាំងគឺភោជនីយដ្ឋាន Epic និងភោជនីយដ្ឋាន ហ៊ូថោវលី ដែលស្ថិតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន។
- ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០ លោក **ហាយ សិទ្ធី** ប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ លោកអនុប្រធានការិយាល័យ និងមន្ត្រីក្រោមឱវាទ ចូលរួមជាគណៈបញ្ជាការឯកភាពខណ្ឌចំការមន ដឹកនាំដោយលោក **កែវ សំណាង** អភិបាលរង នៃគណៈអភិបាលខណ្ឌចំការមន បានចុះត្រួតពិនិត្យទីតាំងអាជីវកម្មចំនួន ០៣ទីតាំង គឺភោជនីយដ្ឋាន តន្ត្រីពិភពសុបិន្ត១៦៨, ដារីសាច់អាំង១៦៨ និងសប្បាយសប្បាយ ដែលស្ថិតនៅភូមិ១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន។
- ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ លោក **ហេង ទេពហ៊ីរ** អនុប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ និងមន្ត្រីក្រោមឱវាទ ចូលរួមជាគណៈបញ្ជាការឯកភាពខណ្ឌចំការមន ដឹកនាំដោយលោក **កែវ សំណាង** និង**លោក ម៉ុន សុភ័ក្ត្រ** អភិបាលរង នៃគណៈអភិបាលខណ្ឌចំការមន បានចុះត្រួតពិនិត្យទីតាំងអាជីវកម្មភោជនីយដ្ឋាន អេស៊ីអ៊ី ដែលស្ថិតនៅភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានបណ្តឹងពីស្ថានទូតរុស្ស៊ី ស្តីពីបង្កសម្លេងរំខាន។
- ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ លោក **ហាយ សិទ្ធី** ប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ លោកអនុប្រធានការិយាល័យ និងមន្ត្រីក្រោមឱវាទ ចូលរួមជាគណៈបញ្ជាការឯកភាពខណ្ឌចំ

ក្រុមការងារក្រសួងសុខាភិបាលចុះមកត្រួតពិនិត្យ និងតាមដានសុខភាពរបស់បុគ្គលិកដែលបម្រើការងារនៅក្នុងភោជនីយដ្ឋានខាងលើនេះ ហើយម្ចាស់អាជីវកម្មបានឯកភាពតាមណែនាំរបស់ក្រុមការងារ។

- ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ លោក **ហេង ទេពហ៊ា** និងលោក **ពៅ ឆាយ** អនុប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ខណ្ឌ បានចូលរួមជាមួយគណៈបញ្ជាការឯកភាពខណ្ឌចំការមន ដឹកនាំដោយលោក **ម៉ុន សុផ័ក្រ្ត** អភិបាលរងខណ្ឌចំការមន បានបន្តចុះត្រួតពិនិត្យ អាជីវកម្ម ក្លឹបកំសាន្ត និងខារ៉ាអូខេ នៅក្នុងមូលដ្ឋានខណ្ឌចំការមន ហើយអាជីវកម្មក្លឹបកំសាន្ត និងខារ៉ាអូខេបានផ្អាកអាជីវកម្មខ្លួនឯង ដោយបានអនុវត្តតាមការណែនាំរបស់ក្រសួង សុខាភិបាល ក្រសួងទេសចរណ៍ និងរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន។
- បានចុះណែនាំដល់អាជីវកម្មភោជនីយដ្ឋានចំនួន ០៥ ទីតាំង ចូលរួមធ្វើអនាម័យ ដើម្បីបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ដោយអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ក្រសួងទេសចរណ៍ និងរដ្ឋបាលរាជធានីភ្នំពេញ និងបានណែនាំដល់ម្ចាស់អាជីវកម្មឱ្យសំអាតអនាម័យទីតាំងកន្លែងទទួលទានអាហារ, ចង្ក្រានបាយ, បន្ទប់ទឹក និងយកចិត្តទុកដាក់ពង្រឹងគុណភាពសេវាកម្ម និងការបដិសណ្ឋារកិច្ចភ្ញៀវឱ្យបានល្អ។
- មន្ត្រីទទួលបន្ទុកទេសចរណ៍នៃការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ខណ្ឌ បានចុះត្រួតពិនិត្យទីតាំងមុនចេញអាជ្ញាប័ណ្ណបានចំនួន ៦៣ មូលដ្ឋាន ក្នុងនោះ៖

  +ភោជនីយដ្ឋាន ចំនួន ៣៩ ទីតាំង +ផ្ទះសំណាក់ ចំនួន ១៨ ទីតាំង
  +ហាងកាហ្វេ ចំនួន ០៣ ទីតាំង +ម៉ាស្សា ចំនួន ០១ ទីតាំង
  +បន្ទប់ស្នាក់នៅ ចំនួន ០១ទីតាំង +អាហារដ្ឋាន ចំនួន ០១ទីតាំង
- បានចុះជម្រុញមូលដ្ឋានអាជីវកម្មដែលជិតផុតសុពលភាពបានចំនួន ១២៦ មូលដ្ឋាន ក្នុងនោះរួមមាន៖

  +ភោជនីយដ្ឋាន ៧៨ ទីតាំង +ផ្ទះសំណាក់ ១៦ ទីតាំង
  +ម៉ាស្សា ០៥ ទីតាំង +សណ្ឋាគារ ០៥ ទីតាំង
  +ខារ៉ាអូខេ ១៧ ទីតាំង +អឺផាតមិន ០២ ទីតាំង
  +បន្ទប់ស្នាក់នៅ ០៣ ទីតាំង
- អាជ្ញាប័ណ្ណទេសចរណ៍ ដែលបានផ្តល់នៅរាជធានីភ្នំពេញបានចំនួន ១០៩ អាជ្ញាប័ណ្ណ ក្នុងនោះ៖

  +ភោជនីយដ្ឋាន ចំនួន ៦០ ទីតាំង +ផ្ទះសំណាក់ ចំនួន ៣០ ទីតាំង
  +សណ្ឋាគារ ចំនួន ១១ទីតាំង +ខារ៉ាអូខេ ចំនួន ០៣ ទីតាំង
  +ម៉ាស្សា ចំនួន ០២ ទីតាំង +អាហារដ្ឋាន ចំនួន ០១ ទីតាំង
  +អឺផាតមិន ចំនួន ០២ ទីតាំង
- អាជ្ញាប័ណ្ណទេសចរណ៍ថ្មី និងបន្ត ដែលផ្តល់នៅការិយាល័យច្រកចេញចូលតែមួយខណ្ឌបានចំនួន ៥៩ ទីតាំង ក្នុងនោះរួមមាន៖

+ម៉ាស្សា ចំនួន ០៦ ទីតាំង
+ផ្ទះសំណាក់ ចំនួន ០២ ទីតាំង
+ហាងកាហ្វេ ចំនួន ១១ ទីតាំង
+ភេសជ្ជៈ ចំនួន ០១ ទីតាំង
+ភោជនីយដ្ឋាន ចំនួន ៣២ ទីតាំង
+បន្ទប់ស្នាក់នៅ ចំនួន ០៣ ទីតាំង
+ខារ៉ាអូខេ ចំនួន ០១ ទីតាំង
+អាហារដ្ឋាន ចំនួន ០៣ ទីតាំង

- ការកត់ត្រាអត្តសញ្ញាណភ្ញៀវស្នាក់នៅ៖

+សណ្ឋាគារ ចំនួន ០៩
+អាផាតមិន ចំនួន ០៩
+មានភ្ញៀវស្នាក់នៅសរុបចំនួន ២,៤០៨នាក់ ស្រី ២,២៩៣នាក់។

## ២.ការងារពាណិជ្ជកម្ម

### ២.១ អាជីវកម្ម-សេវាកម្ម

ចុះជម្រុញទីតាំងអាជីវកម្ម-សេវាកម្មបើកថ្មីនិងបន្តសុពលភាពបានចំនួនសរុប ២៣២ ទីតាំង ក្នុងនោះរួមមាន៖

-ទីតាំងអាជីវកម្ម-សេវាកម្មដែលមានទំហំលើសពី ០៥ម៉ែត្រការ៉េ មានចំនួន ២៣២ ទីតាំង រួមមាន៖

+ថ្មី បានចំនួន ៧២ ទីតាំង
+បន្ត បានចំនួន ១៦០ ទីតាំង

-ទីតាំងអាជីវកម្ម-សេវាកម្មដែលមានទំហំក្រោម ០៥ម៉ែត្រការ៉េ មានចំនួន ០០ ទីតាំង រួមមាន៖

+ថ្មី បានចំនួន ០០ ទីតាំង
+បន្ត បានចំនួន ០០ ទីតាំង

### ២.២ អាជីវកម្មលក់លោហធាតុថ្មមានតម្លៃជាគ្រឿងអលង្ការ

ចុះជម្រុញទីតាំងអាជីវកម្មលក់លោហធាតុថ្មមានតម្លៃជាគ្រឿងអលង្ការបើកថ្មី និងបន្តសុពលភាពបានចំនួនសរុប ១០ ទីតាំង៖

-ទីតាំងអាជីវកម្មនៅក្រៅផ្សារ មានចំនួន ០៩ ទីតាំង រួមមាន៖

+ថ្មី បានចំនួន ០១ ទីតាំង
+បន្ត បានចំនួន ០៨ ទីតាំង

-ទីតាំងអាជីវកម្មនៅក្នុងផ្សារ មានចំនួន ០១ តូប រួមមាន៖

+ថ្មី បានចំនួន ០០ តូប
+បន្ត បានចំនួន ០១ តូប

## ៣.ការងារឧស្សាហកម្ម និងសិប្បកម្ម

ក.ការងារឧស្សាហកម្ម៖ (គ្មាន)

ខ.ការងារសហគ្រាសធុនតូច និងមធ្យម៖

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រតិភូកម្មថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅក្រសួងរ៉ែ និងថាមពល
- ចុះជម្រុញម្ចាស់សិប្បកម្មលាងរថយន្ត អោយមកស្នើសុំចុះបញ្ជី ចំនួន ២០ មូលដ្ឋាន
- ចុះស្រង់ស្ថិតិអាជីវកម្មលក់ហ្គាស ចំនួន ០២ទីតាំង។
- បានមកស្នើសុំចុះបញ្ជីនៅការិយាល័យច្រកចេញចូលខណ្ឌ ចំនួន ០៣មូលដ្ឋាន។
- ចុះបញ្ជីនៅមន្ទីរសេរុប ០៥ មូលដ្ឋាន (ថ្មី ចំនួន ០២មូលដ្ឋាន)។
- បានចេញលទ្ធផលវិភាគគុណភាពផ្នែកសិប្បកម្មផលិតចំណីអាហារ ចំនួន ០៨ ទីតាំង ស្មើនិង ០៨ មុខផលិតផល។

គ.ការងារស្តង់ដារ និងមាត្រាសាស្ត្រ

- ចុះយកផលិតផលទំនិញវេចខ្ចប់ត្រួតពិនិត្យផ្ទៀងផ្ទាត់ (ចំណុះ-ទម្ងន់ និងរង្វាស់រង្វាល់) ចំនួន ០៤ មុខទំនិញ ស្មើ ០៨ មុខផលិតផល។
- បានសហការជាមួយមន្ត្រីមន្ទីរឧស្សាហកម្មរាជធានីភ្នំពេញ ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ស្ថានីយ៍ប្រេងឥន្ធនៈ ភីធីធី (ដៃបាញ់ប្រេង) ចំនួន ០៣ស្ថានីយ៍ ក្នុងសង្កាត់ទន្លេបាសាក់ សង្កាត់បឹងត្របែក និងសង្កាត់ទួលទំពូងទី២ ជាលទ្ធផល សមស្របការកំណត់។

**ឃ.សកម្មភាពចូលរួមផ្សេងៗ**

- ចូលរួមបណ្តុះបណ្តាលស្តីពីការធ្វើប្រតិភូកម្មជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន ០៤លើក។

**៤.ការងារកសិកម្ម**

គ្មាន

**៣.២. សង្គមកិច្ច**

**៣.២.១- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**

តារាងសរុបសកម្មភាពការងារ ប្រចាំឆ្នាំ២០២០ មានការងារដូចខាងក្រោម:

| ល.រ. | **បរិយាយ** | **ចំនួនលើក** |
|---|---|---|
| ១ | ចូលរួមវគ្គបណ្តុះបណ្តាល | ០៧ |
| ២ | ចូលរួមចែកអំណោយមនុស្សធម៌ | ១៧ |
| ៣ | ចូលរួមចុះសួរសុខទុក្ខ | ០៤ |
| ៤ | ចុះត្រួតពិនិត្យសន្តិសុខសណ្តាប់ធ្នាប់ក្នុងវត្ត | ០២ |
| ៥ | ចូលរួមពិធីប្រគល់និងទទួលប័ណ្ណសមធម៌ | ០៤ |
| ៦ | បាននាំយកថវិការ មរណៈសង្គ្រោះរបស់សមាគមន៍អតីតយុទ្ធជនកម្ពុជាខណ្ឌចំការមន | ១៤ |

- ថ្ងៃទី១៥ ខែវិច្ឆិកា២០២០ លោក បានសារិទ្ធិ ប្រធានការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម បានចូលរួមប្រជុំស្តីពី ការពង្រឹងការងារសន្តិសុខសណ្តាប់ធ្នាប់ ជូនដល់បងប្អូនប្រជាពលរដ្ឋនូវក្នុងខណ្ឌចំការមន។
- ក្នុងខែធ្នូ ឆ្នាំ២០២០ លោក **បាន សារិទ្ធិ** ប្រធានការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម បានចូលរួមចែកអំណោយមនុស្សធម៌ជូនដល់គ្រួសារក្រីក្រដែលរស់នៅក្នុង -សង្កាត់ទន្លេបាសាក់ -សង្កាត់ទួលទំពូងទី១-សង្កាត់ទួលទំពូងទី២ -សង្កាត់បឹងត្របែក -សង្កាត់ផ្សារដើមថ្កូវ សរុបចំនួន ១០០គ្រួសារ អំណោយដែលទទួលបានក្នុង១គ្រួសារ រួមមាន៖អង្ករចំនួន ២០គីឡូក្រាម ទឹកត្រីចំនួន ២ដប ទឹកស៊ីអ៊ីវ ចំនួន២ដប ត្រីខចំនួន៣កំប៉ុង ស្ករសចំនួន១គីឡូក្រាម សាប៊ូចំនួន១ដុំ ម៉ាសចំនួន ១០ អាកុលចំនួន១ដប ទឹកដោះគោចំនួន១កំប៉ុង មីចំនួន១០កញ្ចប់ ថវិការ ២០០០០៛(ពីរម៉ឺនរៀល) ដោយឡែកសង្កាត់ទន្លេបាសាក់ ចំនួន២០គ្រួសារទទួលបានថវិការ៤០០០០៛(បួនម៉ឺនរៀល) ក្រោមអធិបតីភាព លោក **ព្រុំ សំខាន់** ប្រធាន កិត្តិយសអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌចំការមននិងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមននិងជាប្រធានគណៈកម្មាធិការអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌចំការមន។
- បានធ្វើបញ្ជីបើកប្រាក់ឧបត្ថម្ភគោលនយោបាយជូនជនចូលនិវត្តន៍ស៊ីវិលនិងអតីតយុទ្ធជន៖

១.<u>ចំនួនជនចូលនិវត្តន៍ស៊ីវិល</u> ១៨១៥នាក់

-ចំនួនជនបាត់បង់សប្បទាវិជ្ជាជីវៈ ៩៣ នាក់

-ចំនួនកូនក្នុងបន្ទុកសពមន្ត្រីរាជការស៊ីវិល ៣០ នាក់

២.<u>អតីតយុទ្ធជន</u>

-យោធាពិការ ៩២ នាក់

-និវត្តន៍យោធា+និវត្តន៍នគរបាល ៣៣៣ នាក់ + ៥២ នាក់

-គ្រួសារមរណៈ ៥៩ នាក់

## ២.<u>ការងារកិច្ចការនារី</u>

- ថ្ងៃទី១៣ ខែមករា ២០២០ វេលាម៉ោង៧:២០នាទី គ.ក.ន.ក.សង្កាត់ទន្លេបាសាក់បានចុះជាមួយក្រុមការងារសង្កាត់នៅចំណុចសង្កាត់នៅចំណុចស្ពាននាគ បានជួយស្ត្រីម្នាក់លោតទឹកសម្លាប់ខ្លួន បន្ទាប់ស្រង់ពីទឹកឃើញថា ពុំមានបញ្ហាធ្ងន់ធ្ងរទេក្រុមការងារបាននាំស្ត្រីរូបនោះមកទីស្នាក់ការប៉ុស្តិ៍ដើម្បីសួរព័ត៌មាន ស្ត្រីរូបនោះមានឈ្មោះ **ភួង រាត្រី** អាយុ ២៨ឆ្នាំមុខរបរបុគ្គលិកក្រុងហ៊ុនឯកជនមួយ ស្នាក់នៅផ្ទះលេខ ៨៧ ភូមិ៧ (មុខវត្តថាន់) និងមានស្រុកកំណើតនៅខេត្តព្រៃវែង ដោយខ្លួនមានបញ្ហា នៅកន្លែងធ្វើការ និងបញ្ហាផ្ទាល់ខ្លួនទៀតទើបដាច់ចិត្តធ្វើយ៉ាងនេះក្រោយពីការណែនាំ នៅវេលាម៉ោង ២២:០០នាទី ក្រុមការងារ បានប្រគល់ជនរងគ្រោះទៅគ្រួសារ និងប្រគល់ទៅអង្គភាពវិញ។
- ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ នៅសាលាសង្កាត់ផ្សារដើមថ្កូវ មានករណីអំពើហិង្សាកើតឡើងចេតនា ស្ថិតក្នុងវិទ្យាល័យផ្សារដើមថ្កូវ **ហ៊ុនសែន ប៊ុនរ៉ានី** ទៅលើសិស្សស្រីឈ្មោះ **ស្រ៊ុន កែវមរកត** គេទ

- បានចុះណែនាំដល់សហគ្រាស គ្រឹះស្ថានឲ្យដំកល់សៀវភៅច្បាប់ស្តីពីការងារនៅកន្លែងធ្វើការងាយស្រួលដល់បុគ្គលិកស្វែងយល់ច្បាប់ស្តីពីការងារ។
- គ្រឹះស្ថានអប់រំវិជ្ជាជីវៈចំនួន០១ទីតាំង។

## ៥.វិស័យវប្បធម៌ និងវិចិត្រសិល្បៈ

- ចុះស្រង់ទិន្នន័យណែនាំ និងជំរុញអាជីវកម្មតាមសង្កាត់ឲ្យមកសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្មរបស់ច្រកចេញចូលតែមួយនៃរដ្ឋបាលខណ្ឌចំការមន និងទៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ។
- ចេញលិខិតអនុញ្ញាតបានចំនួន ២០ទីតាំង។

## ៦.ការងារសុខាភិបាល

| | | | |
|---|---|---|---|
| ១.ការពិនិត្យផ្ទៃពោះសរុប | ចំនួន | ២៦៧ | នាក់ |
| ២.ការសំរាលកូន | ចំនួន | ០៦ | នាក់ |
| ៣.ការផ្តល់ជាតិដែក ៩០គ្រាប់មុនសំរាល | ចំនួន | ១២៧ | នាក់ |
| ៤.ចំនួនកុមារចាក់ថ្នាំបង្ការគ្រប់មុខ | ចំនួន | ១៤១ | នាក់ |
| ៥.ស្ត្រីមានផ្ទៃពោះចាក់ថ្នាំបង្ការតេតាណុសលើសពី២ដង | ចំនួន | ៤៣ | នាក់ |
| ៦.ស្ត្រីអាយុ១៥-៤៥ឆ្នាំចាក់ថ្នាំបង្ការតេតាណុសលើសពី២ដង | ចំនួន | ០៧ | នាក់ |
| ៧.តាមដានជាប្រចាំករណីមាតាស្លាប់ និងទារកស្លាប់ក្រោម ២៨ ថ្ងៃ | ចំនួន | ០០ | លើក |
| ៨.តាមដានជាប្រចាំករណីជំងឺផ្សេងៗ | ចំនួន | ០០ | លើក |
| ៩.ប្រជុំពង្រឹងការងារគាំពារមាតា និងទារក កុមារ | ចំនួន | ០១ | ដង |

- ថ្ងៃទី០៥ ដល់ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ រដ្ឋបាលខណ្ឌចំការមន បានសហការជាមួយការិយាល័យសុខាភិបាល ស្រុកប្រតិបត្តិនៃមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ធ្វើយុទ្ធនាការបោសសំអាត និងផ្តល់បន្ថែមថ្នាំបង្ការបង្គ្រប់ នៅសហគមន៍ងាយរងគ្រោះសម្រាប់ជុំទី៣ ត្រីមាសទី៣ ឆ្នាំ២០២០ ជូនដល់កុមារអាយុក្រោម២ឆ្នាំ ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្នុងវ័យបន្តពូជ(អាយុ១៥ ដល់៤៥ឆ្នាំ) នៅសង្កាត់ទន្លេបាសាក់ សង្កាត់ផ្សារដើមថ្កូវ សង្កាត់បឹងត្របែក ក្នុងមូលដ្ឋានខណ្ឌចំការមន។
- ថ្ងៃទី១៩ ខែ១១ ឆ្នាំ២០២០ ក្រុមការងាររដ្ឋបាលខណ្ឌ ដឹកនាំដោយលោក **អាំង សិរីពិសិដ្ឋ** អភិបាលរងខណ្ឌចំការមន បានចូលរួមសហការជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដឹកនាំដោយ ឧត្តមសេនីយ៍ទោ វណ្ណ ថេង អនុប្រធានលេខាធិការដ្ឋាន បានអនុវត្តតាមលិខិតបង្គាប់ឱ្យឆែកឆេ លេខ **១៩៧** អ.យ.ឋ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់លោក **គុជ គីមឡុង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតផ្ទះលេខ ៨៩ ផ្លូវ ១៦៣ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រោយពីបាន ពិនិត្យជាក់ស្តែងរួមមក ដោយរកឃើញសម្ភារៈវត្ថុតាងរួមមានៈ ប្រភេទថ្នាំទឹកសរុប **២,៨៦១**ដប ព្រះរាជអាជ្ញារងបានអនុញ្ញាតឱ្យសមត្ថកិច្ចចំរុះ សម្រេចផ្អាកអាជីវកម្មពាក់ព័ន្ធនឹងផលិតផលបារីអេឡិចត្រូនិច និងបិទទីតាំងខាងលើបណ្តោះអាសន្ន និងអញ្ជើញអ្នកពាក់ព័ន្ធទីតាំងខាងលើ មកបំភ្លឺនៅលេខាធិការដ្ឋាននៃ គ.ប.ផ.ក ។

- ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ ចុះផ្សព្វផ្សាយអំពីការបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីត១៩ ដល់បងប្អូនប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានខណ្ឌចំការមន កុំឱ្យមានការឆ្លងចូលសហគមន៍ដើម្បីបានដង្ហែជាក្បួនធ្វើដំណើរទៅតាមដងវិថីផ្សារតូច-ធំ ក្នុងមូលដ្ឋានចំការមន ក្នុងមធ្យោបាយរួមមាន ឡាន ម៉ូតូកង់បី និងម៉ូតូ ហើយបានចាក់សារអប់រំរបស់ក្រសួងសុខាភិបាល និងបានចែកម៉ាស់របស់សម្តេចតេជោ ហ៊ុន សែន។
- ថ្ងៃទី០៨ ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ រដ្ឋបាលខណ្ឌចំការមន បានសហការជាមួយការិយាល័យសុខាភិបាល ស្រុកប្រតិបត្តិនៃមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ធ្វើយុទ្ធនាការបោសសំអាត និងផ្តល់បន្ថែមថ្នាំបង្ការបង្គ្រប់ នៅសហគមន៍ងាយរងគ្រោះសម្រាប់ជុំទី៤ ត្រីមាសទី៤ ឆ្នាំ២០២០ ជូនដល់កុមារអាយុក្រោម២ឆ្នាំ ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្នុងវ័យបន្តពូជ(អាយុ១៥ ដល់៤៥ឆ្នាំ) នៅសង្កាត់ទន្លេបាសាក់ សង្កាត់ផ្សារដើមថ្កូវ សង្កាត់បឹងត្របែក ក្នុងមូលដ្ឋានខណ្ឌចំការមន។
- ខែធ្នូ ឆ្នាំ២០២០ លោក **អាំង សិរីពិសិដ្ឋ** អភិបាលរងនៃគណៈអភិបាលខណ្ឌចំការមនបានដឹកនាំ អធិការនគបាលខណ្ឌ មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ លោក ប្រធានការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គមនិងសង្កាត់ ចុះមកត្រួតពិនិត្យនឹងស្រង់ស្ថិតិភ្ញៀវបរទេសមកពីក្រៅប្រទេស ចូលមកស្នាក់នៅដើម្បីធ្វើ ចត្តាឡីស័ក ចំនួន៣ ទីតាំង សរុបរួម៤៦៧ នាក់ រួមមាន ៖សណ្ឋាគារ តូយ៉ូកូអ៊ីន ផ្លូវស-ប៊ិត សង្កាត់ទន្លេបាសាក់ ចំនួនសរុប ១៨២នាក់ មិនទាន់ដឹងភេទ (ជនបរទេសចំនួន ១៧៦នាក់,ខ្មែរ០៦ នាក់ នឹងសណ្ឋាគារ ឡុង លីវ ផ្លូវ៣១២ សង្កាត់ទន្លេបាសាក់ សរុបចំនួន១២២នាក់ ស្រី១២នាក់ (ខ្មែរ) និងសណ្ឋាគារ ប្រេងជីផានី ផ្លូវ១២៣ សង្កាត់ទួលទំពូងទី១ សរុបចំនួន១៦៣ នាក់ស្រី១២នាក់(ខ្មែរ)។
- ខែធ្នូ ឆ្នាំ២០២០ រដ្ឋបាលខណ្ឌចំការបានសហការជាមួយមន្ទីរសុខាភិបាលរាជធានីភ្នំពេញនិងក្រសួងសុខាភិបាល បានចុះធ្វើការប្រមូលពីបុគ្គលិក ផ្សារទំនើបអ៊ីអន១,ផ្សារចិន ឈួន ម៉ាគួរ, ហាង មីនីសួរ សង្កាត់ទន្លេបាសាក់ ,ហាង ប៊ីហ្គើ,អាហារដ្ឋាន យីហោ ដាយក្រុង សង្កាត់ទួលទំពូងទី១ ,ស្ថានីយ៍ប្រេង កាល់តិច,វិមានរដ្ឋសភា សង្កាត់បឹងត្របែកនិងហាង តាន់ ហ៊្វូត សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ដើម្បីស្វែងរកមេរោគកូវីដ-១៩ ជាលទ្ធផល បុគ្គលិកយកសំណាកវិភាគរកមេរោគកូវីដ-១៩ សរុប ៣,៣០៥ នាក់ ស្រី១៨៩៨ នាក់ក្នុងនោះរួមមាន វិមាន រដ្ឋសភា ៣៥ នាក់ស្រី ១៥នាក់ ,ផ្សារទំនើបអ៊ីអន ១ សរុប៣,២៣៣នាក់ ស្រី ១,៨៦១នាក់,ផ្សារចិន ឈួន ម៉ាគួរ ២៤នាក់ ស្រី១៩នាក់,ហាង មីនីសួរ១៥នាក់ស្រី១១នាក់,ហាងប៊ីហ្គើ២៨នាក់ស្រី១៤នាក់,ស្ថានីយ៍ កាល់តិច១៧នាក់ស្រី១០នាក់ ,ហាង តាន់ ហ៊្វូត ០៩នាក់ ស្រី០៦នាក់,អាហារដ្ឋាន យីហោ ដាយក្រុង ០៨នាក់។

## ៣.២.៧.ការងារអប់រំយុវជន និងកីឡា

**I- គ្រឹះស្ថានសិក្សាសាធារណៈ**

ក- សាលាមត្តេយ្យជាច់ចំនួន២ សាលា(មិនដំណើរការចំនួន០១ ) មានសិស្សសរុបចំនួន ១២៥ នាក់ ស្រី ៧០ន

- ថ្នាក់មត្តេយ្យក្នុងបឋមសិក្សាសរុបមាន ៩ ថ្នាក់ មានសិស្សសរុប ២៣៤ នាក់ ស្រី ១១៨ នាក់

ខ- សាលាបឋមសិក្សាចំនួន០៥ សាលា មានសិស្សសរុបចំនួន ៤៣៤៥ នាក់ ស្រី ចំនួន ២០៥៩ នាក់

- សិស្សជាប់ជាប់មធ្យមភាគសរុបចំនួន ៣៩៤៦ នាក់ ស្រីចំនួន ១៨៩២ នាក់ ត្រូវជា ៩០.៨១%
- សិស្សឆ្លងកម្រិតសិក្សាមានចំនួន ៧០៣ នាក់ ស្រីចំនួន ៣៧១ នាក់ ត្រូវជា ៩៤.១១ %

គ- អនុវិទ្យាល័យជាច់មាន ០១សាលា សិស្សសរុប ១៦៦ ស្រី ៩២ នាក់ ជាប់មធ្យមភាគ ១៥៨ នាក់ ស្រី៨៩នាក់ ត្រូវជា ៩៥.១៨% សិស្សប្រឡងជាប់សញ្ញាបត្របមធ្យមសិក្សាបឋមមានចំនួន ៤១នាក់ ត្រូវជា ៩៧.៦១ % ។

ឃ- វិទ្យាល័យមាន ៣សាលា មានសិស្សសរុបចំនួន ៖ ៦៣៩៧ នាក់ ៣២២០៤ នាក់ ជាប់មធ្យមភាគ ៥៧៩៤ នាក់ ស្រី ២៩០៥នា ក់ ត្រូវជា ៩០.៦១ % ។

- សិស្សដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំនួន ៦៩១ នាក់,ស្រី ៦២១នាក់ ត្រូវជា ៩២.៦៩%

**ការជួយពីសប្បុរសជន និងអង្គការនានា ៖**

- សប្បុរសជនជួយអភិវឌ្ឍន៍បរិស្ថានសាលារៀន(បឋម និងមធ្យម ) គិតជាប្រាក់ចំនួន ៥១.០៨៣.០០០៛ ។
- សប្បុរសជនជួយឧបត្ថម្ភសម្ភារៈអនាម័យការពារជំងឺកូវីដ១៩ ដូចជា៖ អាល់កុល,ជែល,ម៉ាស់ និងកន្លែងលាងដៃ សរុបជាប្រាក់ចំនួន ៦.៦០៥.០០០៛ និង ១.៨៣៣ $ ។
- សប្បុរសជន និងអតីតសិស្ស បានជួយលាបអគារសិក្សា ១ខ្នង ២ជាន់ ១០ បន្ទប់ នៅសាលាបឋមសិក្សាអឧមក. ហាន.បឹងត្របែកត្បូង គិតជាប្រាក់ អស់ ១០.៨៥០.០០០៛ ។
- អង្គការផ្ទះបាយជួយកុមារក្រីក្រនៅសាលាបឋមសិក្សាអឧមក.ហានបឹងត្របែកខាងត្បូង ចំនួន ៧៥នាក់ រយៈពេល ៦ខែ ( ធមាសទី១ )គិតជាប្រាក់ ៧.៥០០.០០០៛ ។
- អង្គការ UNICEF ជួយសម្ភារអនាម័យដូចជា៖ សាប៊ូដុំ,អូសាវ៉ែល,ធុងលាងដៃ ,ស្រោមដៃ...។ល។ ដល់គ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ ។
- អង្គការ Paschal Global Foundation ជួយលាបអគារសិក្សា១ខ្នង ២ជាន់១០បន្ទប់ នៅសាលាបឋមសិក្សា អឧមក.ហាន.ទួលទំពូងទី២ គិតជាប្រាក់ ១០.២០០.០០០៛ ។

**II- គ្រឹះស្ថានសិក្សាចំណោះទូទៅឯកជន ៖**

ក- សាលាមត្តេយ្យឯកជនជាច់ មានចំនួន ៥ សាលា មានសិស្សសរុប ២៤១ នាក់ ស្រី ១២៦ នាក់ ។

ខ- ថ្នាក់មត្តេយ្យក្នុងបឋមសិក្សាមានចំនួន ១៤ សាលា មានសិស្សសរុបប ៧១៩ នាក់ ស្រី ៣៧៩នាក់ ។

គ- សាលាចំណោះទូទៅបឋមសិក្សាមាន ២១ សាលា មានសិស្សសរុប ៣៧៧៦ នាក់ ស្រី ១៨៧០ នាក់ ។

- សិស្សជាប់ជាប់មធ្យមភាគសរុបចំនួន ៣៥៨៦ នាក់ ស្រីចំនួន ១៧៧៥ នាក់ ត្រូវជា ៩៤.៩៦ % ។
- សិស្សឆ្លងភូមិសិក្សាមានចំនួន ៥៩៦ នាក់ ស្រី ៣០២ នាក់ ត្រូវជា ១០០% ។

ឃ- សាលាមធ្យសិក្សាចំណោះទូទៅឯកជនមាន ៨សាលា សិស្សសរុបចំនួន ២៤៥១នាក់ ស្រី១១៨៧នាក់

## ៣.២.៨.ការខារពត៌មាន

(មិនមានមន្ត្រីជំនាញ)

## ៣.៣.ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ៣.៣.១ អនាម័យ បរិស្ថាន

១.សហការជាមួយសង្កាត់និងក្រុមហ៊ុន ស៊ិន ទ្រី ចុះប្រមូលសំរាម ដឹកសំរាម និងសំអាតសំរាមតាមផ្លូវក្នុងមូលដ្ឋាន ខណ្ឌចំការមន ។

២.បានអប់រំណែនាំអ្នកបញ្ចេញសំរាមខុសម៉ោងពេលកំណត់បានចំនួន ៣៥លើក។

៣.បានអប់រំណែនាំ អ្នកចាក់កាកសំណល់និងសម្ភារៈសំណង់អនាធិបតេយ្យលើចិញ្ចើមផ្លូវ និងទ្រូងផ្លូវបានចំនួន ០៣ទីតាំង។

៤.បានចុះអប់រំប្រជាពលរដ្ឋនៅតាមខ្នងផ្ទះអោយមានការវេចខ្ចប់ ទុកដាក់សំរាមអោយបានត្រឹមត្រូវតាមម៉ោងពេលនិងទីកន្លែងកំណត់ និងណែនាំអោយជួយសំអាតមុខផ្ទះនិងសំអាតមាត់អណ្តូងលូបានចំនួន ៥៥ខ្នងផ្ទះ។

៥.បានចុះអប់រំណែនាំដល់ម្ចាស់ភោជនីយដ្ឋាន និងអ្នកលក់ដូរតាមចិញ្ចើមផ្លូវអោយទុកដាក់សំរាមអោយបានត្រឹមត្រូវបានចំនួន ៥៥ទីតាំង។

៦.តាមផ្សារនីមួយៗគណៈកម្មការផ្សារ បានធ្វើការលាងសំអាតដេប៉ូសំរាមជាប្រចាំ ជៀសវាងសាយក្លិនស្អុយចេញមកក្រៅ ធ្វើអោយប៉ះពាល់ដល់អាជីវករដែលមានតូបលក់នៅជិតដេប៉ូរាមនិងភ្ញៀវដែលអញ្ជើញមកផ្សារ, បានត្រួតពិនិត្យជាប្រចាំការទុកដាក់ វេចខ្ចប់សំរាមនិងការប្រមូលសំរាមតាមធុងដោយយកទៅរក្សាទុកក្នុងដេប៉ូសំរាមដើម្បីក្រុមហ៊ុនដឹកចេញ។

៧. នៅក្នុងអំឡុងពេលកម្មករក្រុមហ៊ុនស៊ិនទ្រី បាតុកម្ម បានប្រើប្រាស់កំលាំងមន្ត្រីរដ្ឋបាលខណ្ឌ សណ្តាប់ធ្នាប់ កំលាំងប្រជាការពារ កំលាំងមន្ត្រីសង្កាត់ មន្ត្រីភូមិ កំលាំងយុវជន ចុះអន្តរាគមន៍ប្រមូលសំរាមក្នុងមូលដ្ឋានសង្កាត់ទាំង៥ បានទាន់ពេលវេលា ។

**៣.៣.២.ការងាររៀបចំដែនដី នគរូបនីយកម្ម ភូមិបាល និងសំណង់**

១- **ការងារសុរិយោដី និងភូមិបាល**

- ចេញប័ណ្ណកម្មសិទ្ធិផ្ទះបានចំនួនៈ ០៤ ប័ណ្ណ
- ចេញប័ណ្ណដី ចំនួនៈ ២៩ ប័ណ្ណ
- ចេញប័ណ្ណសហកម្មសិទ្ធបានចំនួនៈ ០ប័ណ្ណ
- អំណោយផ្តាច់កម្មសិទ្ធផ្ទះបានចំនួនៈ២ច្បាប់
- អំណោយផ្តាច់ប័ណ្ណដីចំនួនៈ ៨៧ ច្បាប់
- អំណោយផ្តាច់សហកម្មសិទ្ធចំនួនៈ ០០
- លក់ផ្តាច់កម្មសិទ្ធចំនួនៈ ០៨ ប័ណ្ណ
- លក់ផ្តាច់ប័ណ្ណដីចំនួនៈ ១៨១ ប័ណ្ណ
- លក់ផ្តាច់សហកម្មសិទ្ធចំនួនៈ១២១៣ ច្បាប់
- កាន់កាប់និងសាងសង់បានចំនួនៈ០១ច្បាប់
- ទុតិយតាដី-ផ្ទះបានចំនួនៈ ០៣ ច្បាប់
- ទំនាស់ដី-ផ្ទះចំនួនៈ ០០ច្បាប់
- ការងារសាងសង់តាមការិយាល័យច្រក១នៅសាលាខណ្ឌបានចំនួនៈ ២០ ច្បាប់
- ការងារជួសជុលតាមការិយាល័យច្រក១នៅសាលាខណ្ឌបានចំនួនៈ ១៤ ច្បាប់

២- <u>ការងារសំណង់</u>

២.១ ការងារសំណង់ (ច្រកសាលាខណ្ឌចំការមន)

- សំណង់ថ្មីមានច្បាប់បានចំនួនៈ ២០
- សំណង់ថ្មីគ្មានច្បាប់បានចំនួនៈ ០០
- សំណង់ថ្មីខុសប្លង់បានចំនួនៈ ០០
- ស្នើសុំជួលជុលនៅមន្ទីរបានចំនួនៈ ០០ច្បាប់
- សំណង់ជួសជុលមានច្បាប់ៈ ១៤
- សំណង់ជួសជុលគ្មានច្បាប់ៈ ០០
- សំណង់ជួសជុលខុសច្បាប់ៈ ០០

២.២ ការងារសំណង់ (ច្រកសាលារាជធានីភ្នំពេញ)

- សំណង់ថ្មីមានច្បាប់បានចំនួនៈ ០៩
- សំណង់ថ្មីគ្មានច្បាប់បានចំនួនៈ ០០
- សំណង់ថ្មីខុសប្លង់បានចំនួនៈ ០០
- សំណង់ជួសជុលមានច្បាប់ៈ ០១
- សំណង់ជួសជុលគ្មានច្បាប់ៈ ០០
- សំណង់ជួសជុលខុសច្បាប់ៈ ០០

- ស្នើសុំជួលជុលនៅមន្ទីរបានចំនួនៈ ០០ច្បាប់

២.៣ ការងារសំណង់ (ប្រកក្រសួង)

- សំណង់ថ្មីមានច្បាប់បានចំនួនៈ ០៤
- សំណង់ថ្មីគ្មានច្បាប់បានចំនួនៈ ០០
- សំណង់ថ្មីខុសប្លង់បានចំនួនៈ ០០
- សំណង់ជួសជុលមានច្បាប់ៈ ០០
- សំណង់ជួសជុលគ្មានច្បាប់ៈ ០០
- សំណង់ជួសជុលខុសច្បាប់ៈ ០០

## ៣.៤.រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ៣.៤.១.ការងារនីតិកម្ម និងដោះស្រាយវិវាទ

| ល.រ | បរិយាយសកម្មភាពការងារ | ចំនួន |
|---|---|---|
| ១ | ចូលរួមសម្រុះសម្រួលវិវាទជាមួយរដ្ឋបាលខណ្ឌ | ៥៨ |
| ២ | ចូលរួមចុះពិនិត្យទីតាំងទំនាស់ និងសំណង់ | ៣៧ |
| ៣ | ចូលរួមចុះអនុវត្តដីកាសម្រេច | ០២ |
| ៤ | ចូលរួមប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌ | ០៩ |
| ៥ | ចូលរួមប្រជុំ គ.ក.ស.ក | ០៧ |
| ៦ | ចូលរួមវគ្គបណ្តុះបណ្តាល | ០៣ |
| ៧ | ចូលរួមវេទិកាពិគ្រោះយោបល់ក្រុមប្រឹក្សាខណ្ឌ | ០៣ |
| ៨ | ចូលរួមប្រជុំចាំបាច់របស់រដ្ឋបាលខណ្ឌ | ០៥ |
| ៩ | ចូលរួមសហការជាមួយក្រុមការងារសុខាភិបាល | ០១ |
| ១០ | ប្រជុំប្រចាំខែថ្នាក់ការិយាល័យ | ០៤ |
| ១១ | ចូលរួមប្រជុំពង្រឹងការងារតាមការិយាល័យ | ០២ |
| ១២ | ចូលរួមប្រជុំគណៈបញ្ជាការឯកភាពខណ្ឌ | ០៩ |
| ១៣ | ចូលរួមប្រជុំនគរបាលយុត្តិធម៌ | ០១ |
| ១៤ | ចូលរួមប្រជុំវឌ្ឍនភាពការងារ និងទិសដៅខែបន្ទាប់ | ០១ |
| ១៥ | ចូលរួមប្រជុំការបំពេញតារាងវិនិយោគរបស់ខណ្ឌ | ០១ |
| ១៦ | ប្រជុំឆ្លងរបាយការណ៍ | ០២ |
| ១៧ | វគ្គផ្សព្វផ្សាយសេចក្តីណែនាំការផ្តល់លិខិតអញ្ជើញ | ០១ |
| ១៨ | ប្រជុំការពង្រឹងការអនុវត្តការងារតាមការិយាល័យ | ០២ |
| ១៩ | ចុះសួរសុខទុក្ខ និងចែកអំណោយសប្បុរសធម៌ | ០៤ |
| ២០ | ចូលរួមជាមួយអនុសាខាកាកបាទក្រហមកម្ពុជា | ០១ |
| ២១ | ចូលរួមចែកសៀវភៅស្នាក់នៅជូនប្រជាពលរដ្ឋ | ០១ |
| ២២ | ចូលរួមត្រួតពិនិត្យជាតិផ្ទុះ និងគ្រឿងញៀន | ០១ |
| ២៣ | ចូលរួមប្រជុំពិភាក្សាការងារជាមួយអង្គការជនពិការ | ០១ |
| ២៤ | ប្រជុំត្រៀមសិក្ខាសមាហរណកម្មផែនការសង្កាត់នៅថ្នាក់ខណ្ឌ | ០១ |

| | | |
|---|---|---|
| ២៥ | សិក្ខាសមាហរណកម្មកម្មវិធីវិនិយោគបីរំកិល (២០២១-២០២៣) | ០១ |
| ២៦ | អបអរសាទរខួបលើកទី៦៧ ទិវាបុណ្យឯករាជ្យជាតិ៩ វិច្ឆិកា | ០១ |
| ២៧ | ចូលរួមធ្វើអនាម័យសាធារណៈ | ០១ |
| ២៨ | ចូលរួមបំពេញបញ្ជីសំណួរសម្ភាសន៍របស់សាលាក្រុងភ្នំពេញ | ០១ |
| ២៩ | ចូលរួមក្រុង៣លីបើកការដ្ឋានសាងសង់ស្ពានបេតុង | ០១ |
| ៣០ | ចូលរួមចែកម៉ាស់ | ០២ |
| ៣១ | ចូលរួមទទួលម៉ាស់ | ០១ |

**ដែលមានសកម្មភាពលម្អិតដូចខាងក្រោម៖**

៣.១.ការសម្រុះសម្រួលវិវាទ

- ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ បានចូលរួមពិភាក្សាដោះស្រាយផលប៉ះពាល់ដល់ប្រជាពលរដ្ឋ០៤គ្រួសារ ដែលរស់នៅលើចិញ្ចើមផ្លូវ១០១ ភូមិ៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន។ជាលទ្ធផល ប្រជាពលរដ្ឋមិនជំទាស់នឹងការពង្រីកផ្លូវនេះឡើយប៉ុន្តែសុំដោះស្រាយគោលនយោបាយជាថវិកាខ្លះ សូមបញ្ជាក់ថាប្រជាពលរដ្ឋទាំង០៤គ្រួសារនេះស្នាក់អាស្រ័យនៅលើចិញ្ចើមផ្លូវនេះជាង៣០ឆ្នាំមកហើយ។
- ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ បានចូលរួមសម្រុះសម្រួលវិវាទបញ្ហាសំណង់ដែលស្ថិតនៅដីឡូតិ៍លេខ១៥៦ ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ ។ជាលទ្ធផលភាគីទាំងពីរបានសះជានឹងគ្នា
- ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ បានចូលរួមសម្រុះសម្រួលវិវាទបញ្ហាសំណង់ដែលស្ថិតនៅដីឡូតិ៍លេខ១៥៦ ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ។ជាលទ្ធផលភាគីទាំងពីរបានឯកភាពគ្នាតាមមតិរបស់អង្គប្រជុំ ដោយទុករយៈពេលមួយសប្តាហ៍សម្រាប់ពិចារណា។
- ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ បានចូលរួមសម្រុះសម្រួលវិវាទបញ្ហាសំណង់ដែលស្ថិតនៅដីឡូតិ៍លេខ១៥៦ ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ។ ជាលទ្ធផលភាគីទាំងពីរបានឯកភាពគ្នាតាមមតិរបស់អង្គប្រជុំ ដោយទុករយៈពេលពីរថ្ងៃសម្រាប់ពិចារណា និងមកជួបគ្នាម្តងទៀតនៅថ្ងៃសុក្រ ទី១៧ ខែមេសា ឆ្នាំ២០២០។
- ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ បានចូលរួមសម្រុះសម្រួលវិវាទបញ្ហាសំណង់ដែលស្ថិតនៅដីឡូតិ៍លេខ១៥៦ ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ។
- ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ បានចូលសម្រុះសម្រួលវិវាទបញ្ហាសំណង់ដែលស្ថិតនៅផ្ទះលេខ២៣បេ ផ្លូវលេខ១៧៣ ភូមិ០៤ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន។ជាលទ្ធផលភាគីទាំងពីរបានឯកភាពសះជា។
- ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ បានចូលរួមការបំភ្លឺបញ្ជាក់បន្ថែមពីបញ្ហាលួចតប្រព័ន្ធប្រើប្រាស់ទឹកស្អាតពីផ្ទះរបស់គាត់អស់រយៈពេល១៧ឆ្នាំ ដែលស្ថិតនៅផ្ទះលេខហាស់៣៧ មហាវិថីព្រះនរោត្តម ក្រុមទី៥៤ ភូមិ០៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន។
- ថ្ងៃទី១៨ខែឧសភា ឆ្នាំ២០២០ បានចូលការសម្រុះសម្រួលវិវាទករណីមិនគោរពតាមកិច្ចសន្យា ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៩ របស់រដ្ឋបាលខណ្ឌចំការមន ។
- ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០បានចូលការសម្រុះសម្រួលវិវាទបញ្ហាសំណង់ដែលស្ថិតនៅផ្ទះលេខ២៣បេ ផ្លូវលេខ១៧៣ ភូមិ០៤ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន។ ជាលទ្ធផលភាគីទាំងពីរបានឯកភាពផ្សះផ្សាគ្នាតាមការសម្រុះសម្រួលរបស់អង្គប្រជុំ។

- ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ បានចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពខណ្ឌចំការមន ក្រោមអធិបតីភាព **លោក ថេង សុថុល អភិបាល នៃគណៈអភិបាលខណ្ឌចំការមន។**
- ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ ចូលរួមកិច្ចប្រជុំសាមញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចស្ត្រី និងកុមារ លើកទី៦ ក្រោមអធិបតីភាព **លោកស្រី កែប សំបូរ** ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ខណ្ឌចំការមន។
- ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ បានចូលរួមទទួលអំណោយម៉ាស់ចំនួន ១០,០០០ ពីសភាសម្ព័ន្ធសហជីពជាតិកម្ពុជា ក្រោមការដឹកនាំដោយ **លោក ថេង សុថុល អភិបាល នៃគណៈអភិបាលខណ្ឌចំការមន។**
- ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៨ របស់ក្រុមប្រឹក្សាខណ្ឌចំការមន អាណត្តិទី៣ ក្រោមអធិបតីភាព **លោក ព្រុំ សំខាន់ ប្រធានក្រុមប្រឹក្សាខណ្ឌចំការមន និង លោក ថេង សុថុល អភិបាល នៃគណៈអភិបាលខណ្ឌចំការមន។**

## ៣.៤.២.ការងារអនុវត្តគោលនយោបាយ "ភូមិ.សង្កាត់មានសុវត្ថិភាព"

### I.សភាពការណ៍សន្តិសុខសង្គម ៖

ក្នុងរយៈពេល០១ ឆ្នាំ ២០២០ នេះ មានការប្រមូលផ្តុំធ្វើបាតុកម្ម កូដកម្ម និងការតវ៉ាផ្សេងៗ របស់កម្មករ អង្គការសង្គមស៊ីវិល សមាគម ប្រជាពលរដ្ឋ និងគណបក្សនយោបាយ កើតឡើង ៨៦ លើក / ១០៥ លើក រួមមាន ៖

១-<u>កម្មករទាមទារតវ៉ា</u> ៖ កើតឡើង ២៥ លើក / ១៣ លើក

- កម្មករជនជាតិចិន ប្រមូលផ្តុំមុខស្ថានទូតចិន សង្កាត់ទួលទំពូង២ ស្នើសុំអន្តរាគមន៍បើកប្រាក់ខែ និងប្រគល់លិខិតឆ្លងដែនដល់ពួកគាត់វិញ ដែលក្រុមហ៊ុនចិន បានដកហូតទុក ០៦ លើក ។
- មានកម្មករជនជាតិចិន-ខ្មែរ បានបិទផ្លូវ និងលើកបដាទាមទារ-តវ៉ា ពាក់ព័ន្ធក្រុមហ៊ុន ជិនយ៉ាស៊ីង ទីតាំងក្នុងសង្កាត់ផ្សារដើមថ្កូវ មិនទាន់បើកប្រាក់ខែរយៈពេល ០៤ ខែ ដល់ពួកគាត់ ០៣ លើក ។
- បុគ្គលិកណាហ្គាវើល ប្រមូលផ្តុំនៅស្នាក់ការផ្ទះជួល ក្នុងសង្កាត់ទន្លេបាសាក់ ដើម្បីប្រមូលស្នាមមេដៃទាមទារលក្ខខ័ណ្ឌ ០៦ ចំណុច ស្នើឲ្យបុគ្គលិកដែលបញ្ឈប់ចូលធ្វើការងារវិញ ,ឲ្យបញ្ឈប់ប្រធានផ្នែកប្រតិបត្តិ ដែលប្រមាថ-បៀនបៀនកេរ្តិ៍ខ្មាស់បុគ្គលិក ,ទាមទារប្រាក់ឈ្នួល ,ស្នើក្រុមហ៊ុនគោរពសេចក្តីបង្គាប់លើវិវាទ និងស្នើក្រុមហ៊ុន អង្គុយជជែកដោះស្រាយវិវាទដែលកើតឡើងកន្លងមក ០៤ លើក ។
- បុគ្គលិកក្រុមហ៊ុនណាហ្គាវើល ប្រមូលគ្នាផ្តិតមេដៃនៅផ្ទះលេខ E២ ផ្លូវ សុធារស សង្កាត់ទន្លេបាសាក់ ដើម្បីទាមទារក្រុមហ៊ុនជួយឧបត្ថម្ភ និងផ្តល់ដំណោះស្រាយដល់ពួកគាត់ សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារប្រចាំថ្ងៃ ក្នុងអំឡុងមានការរាលដាលនៃជំងឺកូវីដ-១៩ (ក្នុងរយៈពេល ៥ ថ្ងៃ ស្នាមមេដៃសរុបប្រហែល ២,១៥០ នាក់) ០៥ លើក ។
- កម្មករស៊ិនទ្រី ប្រមូលផ្តុំមុខក្រុមហ៊ុនស៊ិនទ្រី សង្កាត់ទន្លេបាសាក់ ស្នើសុំក្រុមហ៊ុនទូទាត់សំណង ១០០% ដល់បុគ្គលិកដែលត្រូវបានបញ្ចប់កិច្ចសន្យាការងារ និងសុំឲ្យសាលារាជធានីភ្នំពេញ ទទួលបុគ្គលិកដែលក្រុមហ៊ុនស៊ីនទ្រី បញ្ឈប់ ចូលធ្វើការនៅរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងបន្តទៀត ០៥ លើក ។
- កម្មករសំណង់ក្លឹបអន្តរជាតិភ្នំពេញ ប្រមូលផ្តុំមុខក្រុមហ៊ុនចិនទី៨ ផលិតដែកថែប សង្កាត់ទន្លេបាសាក់ ដើម្បីសុំឲ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលប្រចាំខែ រយៈពេល ០២ ខែ ០១ លើក ។

- មានកម្មករក្រុមហ៊ុនផ្លូវដែកចិនជុងជឿនស៊ីរី ប្រមូលផ្ដុំមុខស្នាក់ការការិយាល័យពាណិជ្ជកម្មចិន (កុងស៊ុល) សង្កាត់ទន្លេបាសាក់ ដើម្បីសុំតំណាងក្រុមហ៊ុន បើកប្រាក់ឈ្នួលប្រចាំខែ (០៧ខែ) ដែលមិនទាន់បើក ០១ លើក ។

២-អង្គការសង្គមស៊ីវិល ៖ កើតឡើង ១១ លើក / ១១ លើក

- នៅភោជនីយដ្ឋានទន្លេបាសាក់២ សង្កាត់ទន្លេបាសាក់ មានសមាគមន៍ប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានធ្វើពិធីអបអរសាទរទិវា អ្នកលក់ដូរតាមដងផ្លូវអន្តរជាតិ ខួបលើកទី៨ ក្រោមប្រធានបទ កិច្ចគាំពារសង្គមសម្រាប់ អ្នកលក់ដូរតាមដងផ្លូវនៅកម្ពុជា ០១ លើក ។
- នៅមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក្នុងសង្កាត់បឹងត្របែក មានរៀបចំកម្មវិធីពិពណ៌គម្រោងសម្លេងដើម្បីយែនឌ័រ និងគម្រោងទិន្នាការភេទ និងអត្តសញ្ញាណយែនឌ័រ ០១ លើក ។
- ក្រុមសហព័ន្ធសហជីពកម្មករសំណង់ ,ព្រៃឈើកម្ពុជា (BWTUC) ,សម្ព័ន្ធការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ដាក់ញត្តិនៅក្រសួងដែនដីនគរូបនីយកម្ម និងសំនង់ សង្កាត់បឹងត្របែក ស្នើសុំរដ្ឋាភិបាលមានវិធានការម៉ឺងម៉ាត់ ជានាគុណភាព សុវត្ថិភាពនៅកន្លែងធ្វើការងារ ០១ លើក ។
- សមាជិកសមាគមផ្គត់ផ្គង់ជ្រូកកម្ពុជា ដឹកនាំដោយឈ្មោះ សាន់ ថាន់ថេត ប្រធានសមាគម បានប្រជុំនៅភោជនីយដ្ឋានទន្លេបាសាក់២ សង្កាត់ទន្លេបាសាក់ ពិភាក្សាអំពីបញ្ហាសាច់ជ្រូកឡើងថ្លៃ ក្នុងប្រទេសកម្ពុជា ០១ លើក ។
- សកម្មជនបរិស្ថានដីធ្លី ,សមាជិកអង្គការស៊ីវិល ,អ្នកសារព័ត៌មាន និងលោកសង្ឃ បានមកគោរពវិញ្ញាណក្ខ័ន្ធលោក កែម ឡី គម្រប់ខួប ០៤ ឆ្នាំ នៅមុខស្ថានីយ៍ប្រេងឥន្ធនៈកាល់តិចបូកគោក សង្កាត់ទន្លេបាសាក់ ០១ លើក ។
- នៅសមាគមន៍ជាងត្នោត ក្នុងសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន មានធ្វើពិធីចែកអំណោយ អង្ករ ,មី ,ខត្រីកំប៉ុង ដល់ប្រជាពលរដ្ឋរស់នៅតំបន់កប់ស្រូវ ខណ្ឌព្រែកព្នៅ ,មានជ័យ ,ផ្លូវរទេះភ្លើង ទួលសង្កែ ,សហគមន៍រីករាយ ០៥ លើក ។
- នៅភោជនីយដ្ឋានទន្លេបាសាក់២ សង្កាត់ទន្លេបាសាក់ មានអង្គការ NGO ,FORUM ,OXFAM ,WORLD ,VISION ធ្វើវេទិកាសាធារណៈ ស្ដីអំពីការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើការនៃការកសាងផែនការថវិកា និងតាមដានលើការចំណាយថវិកាសាធារណៈ (ថវិការជាតិ និងថ្នាក់ក្រោមជាតិ) ០១ លើក ។

៣-ប្រជាពលរដ្ឋទាមទារតវ៉ា ៖ កើតឡើង ៤៥ លើក / ៧៧ លើក

- ប្រជាពលរដ្ឋមកពីខេត្តកោះកុង ,ព្រះសីហនុ ,ក្រចេះ ,កំពង់ចាម ,បន្ទាយមានជ័យ ,ស្វាយរៀង ,ត្បូងឃ្មុំ ,កណ្ដាល ,កំពង់ស្ពឺ ,កំពង់ឆ្នាំង ,កំពង់ធំ ,ស្វាយរៀង និងសង្កាត់ព្រៃវែង ខណ្ឌដង្កោ ស្នួរនាំ-ដាក់ញត្តិសុំអន្តរាគមន៍រឿងទំនាស់ដីធ្លី នៅក្រសួងកសិកម្ម និងវិមានរដ្ឋសភា ០២ លើក និងក្រសួងដែននគរូបនីយកម្ម និងសំណង់ សង្កាត់បឹងត្របែក ៣០ លើក និងមកពីខេត្តព្រះសីហនុ ដាក់ញត្តិសុំអន្តរាគមន៍ដោះស្រាយអាជីករ ឲ្យបន្តលក់ដូរដដែល ០១ លើក
- ប្រជាពលរដ្ឋមកពីខេត្តត្បូងឃ្មុំ ,បុរីសន្តិភាព២ ខណ្ឌពោធិ៍សែនជ័យ សួរនាំ-ដាក់ញត្តិ នៅក្រសួងមហាផ្ទៃ សង្កាត់ទន្លេបាសាក់ ដើម្បីសុំអន្តរាគមន៍ដោះលែងតំណាងពួកគាត់ ដែលអាជ្ញាធរចាប់ខ្លួនកន្លងមក រឿងទំនាស់ដីធ្លី ០២ លើក ។

- ប្រជាពលរដ្ឋមកខេត្តកំពង់ស្ពឺ ប្រមូលផ្តុំមុខក្រសួងមហាផ្ទៃ សង្កាត់ទន្លេបាសាក់ មកគាំទ្រអ្នកភូមិ ៦ នាក់ ដែលត្រូវខាងនាយកដ្ឋានព្រហ្មទណ្ឌកោះហៅមកបំភ្លឺបណ្តឹងឈ្មោះ លឹម ដា ០១ លើក ។
- នៅសាលា PARAGON ស្ថិតក្នុងភូមិ ៨ សង្កាត់ទន្លេបាសាក់ មានអាណាព្យាបាលសិស្សានុសិស្ស ស្នើសុំឲ្យសាលាបញ្ចុះតម្លៃ លើការសិក្សាសម្រាប់វិស្សមកាលថ្មី ៥០% នៃការសិក្សាប្រចាំថ្ងៃ និងសិក្សាតាមអនឡាញ ០១ លើក ។
- សកម្មជនគណបក្សក្រៅច្បាប់ ,មាតាធម្មជាតិ ,ក្រុមថាវរៈ ,SOS យកញត្តិដាក់នៅស្ថានទូត ជប៉ុន , អូស្ត្រាលី សង្កាត់ទន្លេបាសាក់ និងអង្គការ UN សង្កាត់ផ្សារដើមថ្កូវ ទាមទារដោះលែងលោក រ៉ុង ឈុន ពាក់ព័ន្ធបទល្មើសដាក់ស្តែង ញុះញង់ឲ្យមានសភាពវឹកវរដល់សន្តិសុខសង្គម លើបញ្ហាព្រំដែនរវាងកម្ពុជា-វៀតណាម ០៥ លើក ។
- មានប្រជាពលរដ្ឋមកពីខេត្តកោះកុង យកលិខិតបដិសេធ ដាក់នៅក្រសួងកសិកម្ម ,បរិស្ថាន , មហាផ្ទៃ ,រដ្ឋសភា និងព្រឹទ្ធសភា បញ្ហាទំនាស់ដីធ្លី ដែលក្រសួងបានប្រកាសកាលពីថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០២០ ចំនួន ០១ លើក ។
-មានប្រជាពលរដ្ឋមកពីខណ្ឌមានជ័យ ប្រមូលផ្តុំមុខស្នាក់ការសមាគមជាងត្នោត សង្កាត់ផ្សារដើមថ្កូវ ដើម្បីមកសុំអំណោយ (មកដោយខ្លួនឯង) ប៉ុន្តែខាងសមាគមជាងត្នោត ពុំមានលទ្ធភាពចែកអំណោយជូនទេ ០២ លើក ។

៤-<u>គណបក្សនយោបាយ</u> ៖ កើតឡើង ០៥ លើក / ០៤ លើក

- ទីស្តីការក្រសួងមហាផ្ទៃ សង្កាត់ទន្លេបាសាក់ មានក្រុមមន្ត្រីអតីតគណបក្សប្រឆាំង ដឹកនាំដោយ ខឹន ស៊ីនឿន បានមកចុះបញ្ជីស្នើសុំបង្កើតគណបក្សថ្មី ឈ្មោះ ខ្មែរស្រលាញ់ជាតិ ដែលមានស្នាក់ការផ្ទះលេខ ១៧B១០ ផ្លូវ បេតុង សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ០១ លើក ។
-មានក្រុមគ្រួសារអតីតសមាជិកគណបក្សក្រៅច្បាប់ (គណបក្សសង្គ្រោះជាតិ) យកញត្តិដាក់នៅអង្គការសិទ្ធិ សង្កាត់ផ្សារដើមថ្កូវ ០២ លើក និងស្ថានទូតជប៉ុន ,អូស្ត្រាលី សង្កាត់ទន្លេបាសាក់ ០២ លើក ដើម្បីសុំអន្តរាគមន៍សម្រួលសម្រួលជួយប្តីរបស់ពួកគាត់ ដែលត្រូវបានចាប់ខ្លួនកន្លងមក ។

## II.<u>អំពីសភាពការណ៍ ការងារប្រឆាំងបទល្មើស</u> ៖

**ក-<u>សភាពការណ៍បទល្មើសព្រហ្មទណ្ឌ</u>** ៖ កើតឡើង ៣៦ លើក បង្ក្រាបបាន ៣៤ លើក ឃាត់ខ្លួន ៥១ នាក់ ប្រុស ៥០ នាក់ ,ស្លាប់ជនរងគ្រោះប្រុស ០១ នាក់ ខ្មែរ និងរបួសប្រុស ០២ នាក់ (ខ្មែរ ០១ នាក់ -ចិន ០១ នាក់) (សង្កាត់ ទន្លេបាសាក់ .២២លើក ,ទួលទំពូង១.០៦លើក ,ទួលទំពូង២ . ០២លើក ,បឹងត្របែក ០៤លើក ,ផ្សារដើមថ្កូវ ០២លើក)

- ក្នុងសភាពការណ៍បទល្មើសព្រហ្មទណ្ឌទាំង ៣៧ លើក ,បង្ក្រាបបាន ៣៤ លើក ចាប់ជនល្មើស ៥១ នាក់ ប្រុស ៥០ នាក់ កើតឡើងតាមបណ្តាសង្កាត់ រួមមាន ៖

| | | |
|---|---|---|
| -សង្កាត់ទន្លេបាសាក់ | កើតឡើង ២២ លើក | បង្ក្រាបបាន ២១ លើក ជនល្មើស ៣៤ នាក់ |
| -សង្កាត់ទួលទំពូងទី១ | កើតឡើង ០៦ លើក | បង្ក្រាបបាន ០៦ លើក ជនល្មើស ០៨ នាក់ |
| -សង្កាត់ទួលទំពូងទី២ | កើតឡើង ០២ លើក | បង្ក្រាបបាន ០២ លើក ជនល្មើស ០២ នាក់ |
| -សង្កាត់បឹងត្របែក | កើតឡើង ០៤ លើក | បង្ក្រាបបាន ០៣ លើក ជនល្មើស ០៤ នាក់ |
| -សង្កាត់ផ្សារដើមថ្កូវ | កើតឡើង ០២ លើក | បង្ក្រាបបាន ០២ លើក ជនល្មើស ០៣ នាក់ |

១/**<u>បទល្មើសឧក្រិដ្ឋ</u>** ៖ កើតឡើង ០៣ លើក បង្ក្រាបបាន ០២ លើក ឃាត់ខ្លួន ០៨ នាក់ ប្រុស ០៨ នាក់ (សង្កាត់ ទន្លេបាសាក់ ០២ លើក ,បឹងត្របែក ០១ លើក) ៖

-<u>លួចមានស្ថានទម្ងន់ទោស (ប្រើកាំបិតភ្ជង់ប្លន់កាបូបដៃ)</u> ៖ ០១ លើក ,សង្កាត់បឹងត្របែក ០១ លើក

-<u>វាយប្លន់ម៉ូតូ</u> ៖ ០១លើក,សង្កាត់ទន្លេបាសាក់០១លើក បង្ក្រាបបាន០១លើក ឃាត់ខ្លួនប្រុស០៦នាក់

-<u>បង្ខាំងជំរិតទារប្រាក់</u>៖ ០១លើក ,សង្កាត់ទន្លេបាសាក់ ០១លើក បង្ក្រាបបាន ០១លើក ឃាត់ខ្លួនប្រុស ០២នាក់ ចិន

+<u>សម្ភារបាត់បង់</u> ៖ ទូរស័ព្ទ ០១ គ្រឿង ,លុយ ៧៥០ ដុល្លាអាមេរិក និង ១៤,០០០ យ៉េន (របស់ជនរងគ្រោះ) ។

+<u>វត្ថុតាងដកហូត</u>៖ ម៉ូតូ ០១គ្រឿង (របស់ជនរងគ្រោះ ប្រគល់ជូនម្ចាស់វិញ) ,ម៉ូតូ ០៣គ្រឿង(របស់ជនសង្ស័យ)

២/**<u>បទល្មើសមជ្ឈឹម</u>** ៖ កើតឡើង ៣៣ លើក បង្ក្រាបបាន ៣២ លើក ឃាត់ខ្លួន ៤៣ នាក់ ប្រុស ៤២ នាក់ ,ស្លាប់ ជនរងគ្រោះប្រុស ០១ នាក់ ខ្មែរ និងរបួសប្រុស ០២ នាក់ (ខ្មែរ ០១ នាក់ ,ចិន ០១ នាក់) (សង្កាត់ទន្លេបាសាក់ ២០ លើក ,ទួលទំពូង១ .០៦ លើក ,ទួលទំពូង២ .០២ លើក ,បឹងត្របែក ០៣ លើក ,ផ្សារដើមថ្កូវ ០២ លើក) ។

-<u>មនុស្សឃាតដោយអចេតនា</u> ៖ ០១ លើក ,សង្កាត់ទន្លេបាសាក់ ០១ លើក បង្ក្រាបបាន ០១ លើក ឃាត់ខ្លួនប្រុស ០១ នាក់ ,ស្លាប់ជនរងគ្រោះប្រុស ០១ នាក់ និងរបួសប្រុស ០១ នាក់ ខ្មែរ ។

-<u>ឆក់</u> ៖ ១០ លើក ,សង្កាត់ទន្លេបាសាក់ ០៦ លើក បង្ក្រាបបាន ០៦ លើក ឃាត់ខ្លួនប្រុស ០៩ នាក់ , ទួលទំពូង១ ០៤ លើក បង្ក្រាបបាន ០៤ លើក ឃាត់ខ្លួនប្រុស ០៦ នាក់ ។

-<u>លួច</u> ៖ ១៦ លើក ,សង្កាត់ទន្លេបាសាក់ ០៨ លើក បង្ក្រាបបាន ០៨ លើក ឃាត់ខ្លួន ១១ នាក់ ប្រុស ១០ នាក់ ,ទួលទំពូង១ ០២ លើក បង្ក្រាបបាន ០២ លើក ឃាត់ខ្លួនប្រុស ០២ នាក់ ,ទួលទំពូង ២ ០២ លើក បង្ក្រាបបាន ០២ លើក ឃាត់ខ្លួនប្រុស ០២ នាក់ ,បឹងត្របែក ០២ លើក បង្ក្រាបបាន ០២ លើក ឃាត់ខ្លួន ០២ នាក់ ស្រី ០១ នាក់ ,ផ្សារដើមថ្កូវ ០២ លើក បង្ក្រាបបាន ០២ លើក ឃាត់ខ្លួនប្រុស ០៣ នាក់ ។

-<u>ហិង្សាដោយចេតនា</u> ៖ ០១លើក ,សង្កាត់ទន្លេបាសាក់ ០១លើក បង្ក្រាបបាន ០១លើក ឃាត់ខ្លួនប្រុស ០១ នាក់ ។

-<u>ឆបោក</u> ៖ ០២លើក ,សង្កាត់ទន្លេបាសាក់០២លើក បង្ក្រាបបាន ០២ លើក ឃាត់ខ្លួនប្រុស ០៣ នាក់

-<u>ប្រើប្រាស់អាវុធខុសច្បាប់</u>៖ ០៣ លើក ,សង្កាត់ទន្លេបាសាក់ ០២ លើក បង្ក្រាបបាន ០២ លើក ឃាត់ខ្លួនប្រុស ០២ នាក់ ,បឹងត្របែក ០១ លើក បង្ក្រាបបាន ០១ លើក ឃាត់ខ្លួនប្រុស ០២ នាក់ ។

+<u>សម្ភារបាត់បង់</u> ៖ ម៉ូតូ ០២ គ្រឿង ,ទូរស័ព្ទ ០៤ គ្រឿង ,កាត ATM ០២ សន្លឹក ,អត្ត ០១ សន្លឹក ,ម៉ាស៊ីនត្រជាក់ ០៤ គ្រឿង ,ទូរទស្សន៍ ០៤ គ្រឿង ,កុំព្យូទ័រ ០១ គ្រឿង ,ធុងបាស់ ០១ គ្រឿង , ទូរទស្សន៍ ១១ គ្រឿង ,លុយ និងសម្ភារមួយចំនួន (របស់ជនរងគ្រោះ) ។

+<u>វត្ថុតាងដកហូត</u> ៖ រថយន្ត ០២ គ្រឿង ,ម៉ូតូ ០៦ គ្រឿង ,ទូរស័ព្ទ ១០ គ្រឿង ,ទូរស្សន៍ ០៤ គ្រឿង , កាតគ្រីម៉ូតូ ០២ សន្លឹក ,កាតគ្រីឡាន ០១ សន្លឹក ,កាតធនាគារ ០៣ សន្លឹក ,លិខិតឆ្លងដែន ០១ ក្បាល ,លុយ និងសម្ភារមួយចំនួន (របស់ជនរងគ្រោះ ប្រគល់ជូនម្ចាស់វិញ) ,អាវុធខ្លី ០២ ដើម ,រថ

នៅតែ ជាចំណុចក្តៅរបស់អាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋ ដែលត្រូវអនុវត្តជាប្រចាំ។

៤- ដោយសារតែបញ្ហាជំងឺកូវីដ-១៩ ការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន នឹងជួបការខ្វះខាតថវិកាសម្រាប់ ប្រើប្រាស់ក្នុងការអភិវឌ្ឍន៍ ដោយសារតែរដ្ឋបាលខណ្ឌ ត្រូវបានកាត់ប្រាក់មូលនិធិរបស់ខ្លួន។

៥- បញ្ហាគ្រោះអគ្គិភ័យនៅតែជាកង្វល់ដ៏ធំរបស់អាជ្ញាធរខណ្ឌ និងប្រជាជន។

៦- បញ្ហាដីធ្លី លំនៅដ្ឋាន បរិស្ថាន និងការរំលោភទន្រ្ទានកាន់កាប់ក្នុងផ្ទៃបឹងក៏នៅតែចោទ។

៧- បញ្ហាសំរាមក៏នៅតែជាបញ្ហាចោទ ធ្វើអោយប្រជាពលរដ្ឋថ្នាំងថ្នាក់ចំពោះក្រុមហ៊ុនស៊ីនទ្រី។

របាយការណ៍ប្រចាំឆ្នាំ២០២០នេះ ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី១៩ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខណ្ឌចំការមន នាថ្ងៃពុធ ០១រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០។

ថ្ងៃ.ពុធ.....១.រោច..... ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ចំការមន,ថ្ងៃទី ៣០ ខែ....ធ្នូ.... ឆ្នាំ២០២០

**អភិបាលនៃគណៈអភិបាលខណ្ឌចំការមន**

ឧបសម្ព័ន្ធ៖

- ឧបសម្ព័ន្ធទី១ ៖ វឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគខណ្ឌ
- ឧបសម្ព័ន្ធទី២ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣
- ឧបសម្ព័ន្ធទី៣ ៖ ការងាររបស់គណៈអភិបាលខណ្ឌចំការមន